# ទស្សនៈត្រាសម្រាប់ព្រះធម៌



រៀបរៀងដោយ

ភិក្ខុ ចិន្តាវី ឈុន ចន្ថា

ផ្សាយចេញពីក្រុមយុវសមណសាស្ត្រខ្មែរ

➢ ឈ្មោះសៀវភៅ : **រស់ក្រោមម្លប់ព្រះធម៌**

➢ រៀបរៀងដោយ : តិក្ខុចិន្តករី **ទូច ចន្ថា**

➢ រចនាក្របដោយ : តិក្ខុឧបតិស្សោ **គង់ ច័ន្ទសុភ័ក្ត្រ**

➢ ត្រួតពិនិត្យដោយ : សាមណេរ **សា ចាន់រ៉ាត់ & ធី ចាន់ណា**

➢ ទីកន្លែងធ្វើ : វត្តពោធិ៍វាល សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង នៃព្រះរាជាណាចក្រកម្ពុជា។

➢ កាលបរិច្ឆេទធ្វើចប់ : ថ្ងៃសៅរ៍ ១៥កើត ខែពិសាខ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៥ ត្រូវនឹងថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១២។

➢ បោះពុម្ពលើកទី ១ : ចំនួន ២.000 ក្បាល

➢ អស់ទឹកប្រាក់ចំនួន : ៥.000.000 រៀល = ១.២៥0 ដុល្លារ

➢ ចែកផ្សាយក្នុងឱកាស : (បុណ្យធម្មទាន)

➢ ការផ្សាយរបស់ : ក្រុមយុវសមណាអ្នកនិពន្ធ (ខេត្តបាត់ដំបង)

➢ ទាក់ទងផ្សេងៗ : ០១២ ៣៨៥ 0៦៦ / 0៦៩ ៤២ ៤១ ៦២

➢ រក្សាសិទ្ធិដោយ : ក្រុមយុវសមណាអ្នកនិពន្ធ គ្មានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានបោះពុម្ព ឬថតចម្លងហើយផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតពីម្ចាស់សៀវភៅឡើយ។

# នាមអ្នកមានឧបការៈក្នុងការងារធម្មទាន

-លោកម្ចាស់ភិក្ខុ **គង់ ច័ន្ទសុភ័ក្រ្ក** -លោកម្ចាស់ **ធិម ម៉ុនឆា**

-លោកម្ចាស់ **សា ចាន់រ៉ាត់** -លោកម្ចាស់ **ធី ចាន់ណា**

-ឧ.សិ. **ឈឹម វណ្ណៈ** និងបងប្អូន -ឧ.សិ. **កែវ សុគន្ធ** (ផ្សារលើ)

-ឧ.សិ. **ណាក់ ណាស់** (U.S.A) -ឧ.សិ. **ជុង សុជា** (ផ្សារលើ)

-ឧ.សិ. **សំ សានី**(ភ្នំពេញ) -ឧ.សិ. **ម៉ៅ វណ្ណី** (អន្លង់វិល)

-ឧ.ស. **ស៊ឹម កុយ** និងភរិយា(កំរៀង) -បងប្រុស **ម៉ៅ មុនី** និងភរិយា

-ឧ.សិ. **មុំ ស្រីទូច** -ឧ.សិ. **អៀម អៀ**

-ឧ.សិ. **ផាន់ សុវណ្ណា** -ឧ.សិ. **យ៉ាំង សុបិន្ត** និងគ្រួសារ

-ឧ.ស. **ហ៊ុល** ឧ.សិ. **ម៉ៃ** (ថ្មគោល) -ឧ.សិ. **ឡុក សាយគីម**(កំពង់ចាម)

-បងស្រី **ជា លីណា** និងគ្រួសារ (ក.ច) -ឧ.សិ. **យាង ស៊ីផល** (កំពង់ចាម)

-មិត្តធម៌ក្នុងខេត្តបាត់ដំបង កំពង់ចាម បន្ទាយមានជ័យ និងសៀមរាប ព្រមទាំងពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន។

# សម្មោទនីយកថា

ការមានជំងឺផ្លូវកាយ គេអាចចូលទៅរកវេជ្ជបណ្ឌិតដើម្បីឱ្យព្យាបាល ឬស្វែងរកឱសថមកទទួលទាន ដើម្បីកម្ចាត់រោគទាំងនោះយ៉ាងណា កាលបើចិត្តនៃបុគ្គលមានជំងឺ គឺលោភៈ ទោសៈ និងមោហៈ បុគ្គលនោះ ក៏ចាំបាច់ត្រូវចូលទៅរកវេជ្ជបណ្ឌិត គឺព្រះសម្មាសម្ពុទ្ធដោយស្វែងរកឱសថ គឺព្រះធម៌ដើម្បីព្យាបាលផ្លូវចិត្ត ព្រមទាំងចូលទៅសេពគប់នូវសប្បុរស គឺព្រះសង្ឃ ដើម្បីឱ្យលោកជួយប្រាប់ផ្លូវជីវិតក៏យ៉ាងនោះដែរ។

ខ្ញុំបានអាន និងពិនិត្យអត្ថបទនេះទាំងស្រុងយល់ឃើញថា ពិតជាមានខ្លឹមសារដល់ពុទ្ធបរិស័ទ ដូចជាប្រទីបជួយបំភ្លឺផ្លូវជីវិតដូច្នោះឯង។

អាស្រ័យហេតុនេះ ខ្ញុំសូមសរសើរចំពោះការរៀបរៀង និងចងក្រងនូវមាតិកាធម៌ រហូតបានសម្រេចជារូបរាងនេះឡើង។ សូមប្រគេននូវព្រះពុទ្ធពរទាំងឡាយ ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ចូរកើតមានដល់លោកម្ចាស់ភិក្ខុចិន្តករី **ទូច ចន្ថា** កុំបីប្រែក្លាយទៅជាប្រការដទៃឡើយ។

ធ្វើនៅបាត់ដំបង,ថ្ងៃសៅរ៍ ១៥កើត ខែពិសាខ ឆ្នាំរោង ចត្វាស័កព.ស. ២៥៥៥ ត្រូវនឹងថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១២។

តំណាងក្រុមយុវសមណអ្នកនិពន្ធ (ខេត្តបាត់ដំបង)

ខ្ញុំព្រះករុណា សាមណេរ **សា ចាន់រ៉ាត់**

# ពាក្យប្រារព្ធ

មូលហេតុដែលនាំឱ្យកើតសៀវភៅ **រស់ក្រោមម្លប់ព្រះធម៌** ដែលអស់លោកកំពុងកាន់នៅនឹងហត្ថាទាំងទ្វេនេះ គឺកើតឡើងដោយសារ មិត្តធម៌របស់ខ្ញុំ ដែលបានជំរុញលើកទឹកចិត្ត មួយអន្លើដោយមានពេល វេលាខ្លះៗ ក្រៅពីម៉ោងសិក្សានៅឯសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ដែលជាឆ្នាំសិក្សាមូលដ្ឋានរបស់ស្នេរ និងជាកាលដែលខ្ញុំបានរស់ក្រោម ដំបូលវត្តអារាម ព្រមទាំងបានរស់ក្រោមម្លប់ព្រះពុទ្ធសាសនា អស់រយៈ ពេលជិតនឹងពាក់កណ្តាលនៃជីវិតទៅហើយ។

មុននឹងឈានទៅមើលផ្ទៃនៃអត្ថបទ ក្នុងសៀវភៅតូចដែលមានរូបឆោមលោមពណ៌ គួរឱ្យចង់អាន ខ្ញុំសូមអញ្ជើញចក្ខុរបស់មិត្តអ្នកអានមើលខ្សែជីវិតរបស់អ្នកសរសេរសិន កាលពីកុមារភាពជីវិតរបស់ខ្ញុំ ក៏មិននឹកស្មានថាបានប៉ុណ្ណឹងដែរ ហេតុអ្វីបានជាខ្ញុំសរសេរយ៉ាងនេះ? ពីព្រោះតែគ្រួសាររបស់កុមារនេះ ដែលមានអ្នកម្តាយឈ្មោះ **សាំង ម៉ៅ** ឪពុកឈ្មោះ **ទូច ស៊ីម** ស្ថិតនៅភូមិសាលាឃុំ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ក្នុងរវាងក្តីស្នេហាប្រេះឆាចែកវណ្ណៈ ពួកគាត់បែកបាក់គ្នា ធ្វើឱ្យរូបខ្ញុំ កំពុងតែនៅក្នុងផ្ទៃរបស់ម្តាយជាសិករដ៏កម្សត់រហូតមក។

ចំពោះអ្នកម្ដាយដែលមានរូបរាងស្គម គ្រាំគ្រាកំព្រា គឺដោយសារឪពុកមិនបានទទួលស្គាល់ថាកូនដែលនៅក្នុងផ្ទៃ មិនមែនជាកូនរបស់គាត់ ថែមទាំងបាននិយាយថា នេះមិនដឹងជាកូនរបស់នរណានោះទេ?

ដោយសារតែបានឮពាក្យដ៏សែនមានអត្ថន័យនេះហើយ ទើបអ្នកមានគុណរបស់កុមារ ដែលលោកអ្នកកំពុងតែអាននេះ មានចិត្តកែប្រែកើតគំនិតថ្មី ដោយសារអត់ប្ដីទើបចង់សម្លាប់កូនចោល។

ទោះជាមានចិត្តយ៉ាងនេះក្ដីដោយសារបុណ្យបារមី ដែលបានធ្វើទុកជាយូរណាស់មកហើយ មានពេទ្យចិត្តល្អមួយរូបដែលគាត់មិនដាច់ចិត្តសម្លាប់កុមារនេះចោល ថែមទាំងបានចាក់ថ្នាំការពារទារកដ៏កម្សត់ ដែលជិតគ្រប់ខែទៅវិញ តើនេះមិនមែនជាភ័ព្វសំណាងរបស់ខ្ញុំទេឬ?

ពេលដែលមាតាកំពុងតែប្រសូតបុត្រ យើងគ្រប់គ្នាកាលពីដើមមានមាតា ព្រមទាំងបិតាទាំងសងមកជួបជុំគ្នា ចំពោះរូបម្ដាយខ្ញុំវិញ មានសុទ្ធតែអ្នកជិតដែលជួយដុតភ្លើងទម្លាក់ចង្ក្រាន។ មិនយូរប៉ុន្មានមាតាដែលមានចិត្តប្រកបដោយមេត្តា ទឹកចិត្តបរិសុទ្ធងាកអំពីសេចក្ដីស្អប់មកស្រឡាញ់កូនដោយព្រហ្មវិហារធម៌ នេះទឹកចិត្តអ្នកម្ដាយគ្រប់រូប (មិនមែនមានទាំងអស់នោះទេ)។

កាលពីខ្ញុំមានអាយុ ៦ ឆ្នាំ នៅក្នុងកំឡុងឆ្នាំ ១៩៩៦ ជីដូនបានឱ្យចូលរៀននៅសាលាបឋមសិក្សាវត្តថ្មី អាយុបាន ១៣ ឆ្នាំ ម្ដាយរបស់ខ្ញុំបានរៀបមង្គលការថ្មី មានការផ្លាស់ប្ដូរទីលំនៅថ្មីផងដែរ ណាមួយជីវិតរស់នៅជាមួយនឹងឪពុកចុង មានការលំបាកស្ទើរតែទ្រាំមិនបាន។

កាលពីខ្ញុំនៅជាគ្រហស្ថ ពេលចេញពីសាលារៀន ដើរដាក់បង្កៃ ពេលយប់មានមិត្តភក្តិពីរបីនាក់ ដើរចាប់តុកកែតាមព្រៃភ្នំដ៏សែនកម្សត់ ដើម្បីយកលុយរៀនខ្លួនឯងផង និងឱ្យអ្នកម្តាយផង មកពីជីវភាពយ៉ាងហ្នឹងហើយ ទើបបានជាជីវិតខ្ញុំពុំសូវជាមានភាពសប្បាយរីករាយទេ។ មួយវិញទៀត ក្នុងការបួសជាព្រះសង្ឃវិញ កាលខ្ញុំនៅពីតូចមិនដែលនិយាយជាមួយព្រះសង្ឃឡើយ។ សូម្បីតែត្រកូលរបស់ខ្ញុំជាអ្នកកាន់នូវព្រះពុទ្ធសាសនាក៏ដោយ ថ្ងៃមួយដែលនឹកស្មានមិនដល់ស្រាប់តែមានចិត្តចង់បួស ក្នុងការបួសទៀតសោតម្តាយរបស់កុមាររូបនេះ មិនឱ្យបួសទាល់តែសោះ ទោះជាយ៉ាងនេះក្តីកុមាររូបនេះនៅតែជម្នះម្តាយ ដែលជាអ្នកមានគុណទាល់តែបានបួស មកដល់ពេលនេះវិញសូមញោមសឹកវិញគាត់ក៏អត់ឱ្យសឹកទៀត។

ពុទ្ធបរិស័ទប្រាកដជាឆ្ងល់ថា ហេតុអ្វីបានជាសរសេររៀបរាប់យ៉ាងនេះ អាត្មាភាពសរសេរទាំងអស់នេះមិនបានគិតទៅដល់អ្នកអានទេ? តែរាល់អត្ថន័យសាច់រឿងរបស់កុមាររូបនេះ ដែលបានបរិយាយខាងលើសង្ឃឹមថា ប្រាកដជាមានដូចអ្នកកំពុងតែកាន់សៀវភៅគ្រប់គ្នា នេះគ្រាន់តែច្រើន និងតិចឬក៏ស្រដៀងគ្នាតែប៉ុណ្ណោះ (សូមភ័យទោស)។

មូលហេតុដែលសំខាន់ជាងនេះទៅទៀតនោះ គឺពុទ្ធបរិស័ទ និងអ្នកអានអាចចេះដឹងយល់ចូលចិត្ត កាន់តែច្បាស់អំពីថ្ងៃកំណើតសំខាន់ៗមួយចំនួន ដែលពុទ្ធបរិស័ទងាយស្រួលធ្វើការគោរពបូជាធម៌ បដិបត្តិជាប្រយោជន៍ សម្រាប់ជាប្រទីបប្រចាំជីវិតទាំងផ្លូវបច្ចុប្បន្ន ទាំងផ្លូវបរលោក។

ជាចុងក្រោយនេះ ខ្ញុំចង់ប្រាប់ថា ខ្ញុំពិតជាខិតខំប្រឹងប្រែងពិនិត្យ និងផ្ទៀងផ្ទាត់អស់ពីកម្លាំងកាយ ចិត្ត មួយអន្លើដោយបញ្ញាដ៏តិចតួចយ៉ាងណាក៏ដោយ ក៏គង់មានការខុសឆ្គាំឆ្គង រំលងដោយអត្ថន័យ ពាក្យពេចន៍ ព្យញ្ជនៈ អក្ខរៈ ភាសាបាលី សេចក្តីអធិប្បាយ បកស្រាយមិនសមហេតុផល ខុសពីបែបបទ ភ្លាំងភ្លាត់ជាក់ជាមិនខានដោយអចេតនា ជួនដោយចេះមិនដល់យល់មិនជ្រៅ ឬថាមិនយល់តែម្តងក៏ថាបានដែរ។

អាស្រ័យហេតុនេះ ទើបខ្ញុំសូមខន្តីអភ័យនូវទោសានុទោសទាំងប៉ុន្មាន ដែលកើតមានឡើងក្នុងទីនេះ អំពីសំណាក់ទឹកព្រះទ័យ ទឹកចិត្តនៃព្រះថេរានុត្ថេរៈ បណ្ឌិតបញ្ញវន្ត កវីនិពន្ធ សាធុសប្បុរស ជាពិសេសជាងនេះទៅទៀត គឺលោកអ្នកគ្រប់មជ្ឈដ្ឋានគ្រប់គ្នា និងគ្រប់សម័យកាលដែលបានអាននូវកូនសៀវភៅនេះ ឬសៀវភៅក្រោយៗទៀត ដែលចេញផ្សាយដោយ «ក្រុមយុវសមណអ្នកនិពន្ធ»។

វត្តពោធិ៍វាល ក្រុងបាត់ដំបង,ថ្ងៃសៅរ៍ ១៥កើត ខែពិសាខ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៥ ត្រូវនឹងថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១២។

ដោយបំណាច់ល្អពីខ្ញុំព្រះករុណា

ភិក្ខុចិន្តកវី **ទូច ចន្ថា**

# មាតិកា

**លរ. ឈ្មោះអត្ថបទ** **លេខទំព័រ**

១.មុននឹងឈានទៅដល់ការយល់ព្រះធម៌ ......................................១
២.ដំណើរត្រាស់ដឹងរបស់ព្រះពុទ្ធអង្គ ............................................៦
៣.អត្ថន័យមហាសុបិន.........................................................................៨
៤.គុណរបស់ព្រះសម្មាសម្ពុទ្ធ .................................................... ៤៣
៥.ជុំរុំជីវិតប្រព្រឹត្តតាមធម៌.........................................................៤៨
៦.ហេតុសំខាន់ៗក្នុងព្រះពុទ្ធសាសនា ........................................៥៤
៧.គ្រឿងការពារជីវិតប្រចាំថ្ងៃ ...................................................៥៨
៨.អ្នកមានសទ្ធាមិនកំព្រាបុណ្យឡើយ ........................................៦២
៩.ផ្លូវដ៏ប្រសើរសម្រាប់ជីវិត .......................................................៦៨
១០.ថ្នាំរក្សាផ្លូវចិត្ត ..........................................................................៧៣
១១.ជុំវិញរឿងព្រះនិព្វាន ............................................................ ៧៨
១២.សូមឱ្យមានធម៌ទាំង ៤ យ៉ាងនេះគ្រប់ៗគ្នា .........................៨៤
១៣.ឆាកល្ខោនជីវិត ....................................................................៨៦

១៤.កំណាព្យផ្សេងៗ ........................................................ ៨៩

# ១.មុននឹងឈានទៅដល់ការយល់ព្រះធម៌

ដើម្បីងាយស្រួលចំពោះពុទ្ធបរិស័ទ ជាអ្នកសិក្សានូវធម៌ ឬក៏ងាយស្រួលដល់អ្នកស្រាវជ្រាវមួយចំនួន ដែលចង់ដឹងអំពីប្រវត្តិរបស់ព្រះពុទ្ធ មុននឹងអ្នកឈានទៅដល់ការជឿអ្វី ដែលអ្នកធ្លាប់តែឮធ្លាប់តែស្តាប់អំពី បរតោឃោសៈ(អ្នកដទៃ) និយាយយ៉ាងនេះថាជាពុទ្ធដីកា ទុកជាយ៉ាងនោះ ក្តី ព្រះអង្គមិនឱ្យចេះតែជឿនោះឡើយ មុននឹងជឿសូមអ្នកអានទាំងអស់ ត្រូវយល់ដឹងអំពីដីកាព្រះអង្គដែលមានឈ្មោះថា កាលាមសូត្រ ឬហៅថា កង្ខានិយដ្ឋានទាំង ១០ គឺៈ(សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត បិដកលេខ ៤១ ទំព័រ ២២២)

**១.មា អនុស្សវេន** កុំជឿគ្រាន់ ព្រោះតែបានស្តាប់បានឮតគ្នាមក

**២.មា បរម្បរាយ** កុំជឿដោយធ្វើតៗគ្នា ឬបដិបត្តិតាមគ្នាមក

**៣. មា ឥតិកិរាយ** កុំជឿដោយ(បានឮ)គេនិយាយតៗគ្នា

**៤. មា បិដកសម្បទានេន** កុំជឿដោយការពឹងផ្អែកលើតម្រា ឬគម្ពីរ។

**៥. មា តក្កហេតុ** កុំជឿដោយហេតុផលរបស់តក្ក (ការគិតថាពិត)

**៦. មា នយហេតុ** កុំជឿដោយការអនុមានន័យ

**៧.មា អាការបរិវិតក្កេន** កុំជឿដោយត្រឹមតែការត្រិះរិះ ត្រូវតាមហេតុផល

**៨.មា ទិដ្ឋិនិជ្ឈានក្ខន្តិយា** កុំជឿដោយត្រឹមតែ (ហេតុផលនោះ) សមស្របជាមួយនឹងទ្រឹស្តី ដែលបានពិនិត្យទុកហើយ

**៩. មា អព្ភរូបតាយ** កុំជឿព្រោះយល់ថា លក្ខណៈនេះអាចប្រព្រឹត្តទៅបាន

**១០. មា សមណោ នោ គរូតិ** កុំជឿដោយគិតថា សមណអង្គនេះ(ឬថាបុគ្គលនេះ)ជាគ្រូរបស់យើង។

សរសេរខាងលើនេះ ចង់ឱ្យអ្នកអានបានយល់ដឹងអំពីពុទ្ធដីកាមួយចំនួន ដែលអ្នកធ្លាប់តែឮតាមបរតោឃោសៈរបស់អ្នកដទៃ បានពោលថា ជាដីការបស់ព្រះពុទ្ធ ប៉ុន្តែមុននឹងឱ្យជឿសូមវិនិច្ឆ័យផងចុះ ក្រែងមិនមែនជាពុទ្ធវចនៈរបស់ព្រះពុទ្ធ។

## មិនគួរជឿព្រោះតែជំនឿគ្មានហេតុផល

អ្នកនិយាយតាមគំនិតគេយល់ រឿងរ៉ាវអំពល់គឺអ្នកស្ដាប់ទេ
គួររៀនគិតកុំចេះតែជឿគេ គួរតែរិះរេឱ្យបានហ្មត់ចត់។
សម្ដីខុសត្រូវមានជាធម្មតា តាមតែវោហារមិនអាចប្រាកដ
គេថាគេស្ដីត្រូវមានអំណត់ អ្នកថាតែងហត់យើងតែងបានផល។
សម្ដីគ្រាន់តែជាខ្យល់មាត់សោះ អ្នកស្ដាប់ទាំងអស់តែងមានចម្ងល់
អ្នកខ្លះស្ដាប់ហើយក៏គិតមិនដល់ មិនដឹងឫសគល់ថារឿងយ៉ាងណា។
សម្ដីគ្មានពណ៌រូបរាងស្គមធាត់ កើតពីខ្យល់មាត់អ្នកដែលប្រើការ
បើស្ដាប់ដោយល្អតែងកើតប្រាជ្ញា ស្ដាប់មិនពិចារណ៍ពិតលង់គំនិត។
អ្នកខ្លះជឿគេបានឮតគ្នា ចុងក្រោយគ្រាំគ្រាព្រោះរឿងមិនពិត
ខ្លួនមិនដែលឃើញឬបានទៅជិត ប្រកាន់ថាមិត្តក៏គួរជឿបាន។

ការជឿតគ្នាពីមួយទៅពីរ ជាប្រពៃណីមានពីបុរាណ
រឿងខ្លះក៏ល្អគួរកាន់យកបាន រឿងយល់ស្មានៗគួរតែលះបង់។
សម្ដីជនពាលគេតែងតែពោល បញ្ចុះបញ្ចូលទៅទីគ្មានប្លង់
ដូច្នេះអ្នកស្ដាប់គួរតែផ្ចិតផ្ចង់ ព្រះពុទ្ធគ្រប់អង្គទ្រង់ឱ្យពិចារណា។
អ្នកខ្លះជឿគ្រូយ៉ាងមាំស៊ប់សួន អាងលើគ្រូខ្លួនអាងក្បួនតម្រា
ពេលទុក្ខកើតឡើងខំរត់ឆ្លេឆ្លា ទុក្ខកើតដោយសារជឿអរូបី។
ព្រះពុទ្ធសម្ដែងព្រះធម៌យ៉ាងល្អិត បង្ហាញការពិតនៅក្នុងលោកិយ
អ្នកគ្មានសទ្ធាស្ដាប់ហើយធ្វើហី ព្រោះគ្មាននិស្ស័យអត់បុណ្យបារមី។
ជំនឿសាសនាមានជាច្រើនផ្នែក តាមការបែងចែកនៃមនុស្សប្រុសស្រី
គោរពបូជានៅក្នុងលោកិយ ទៅតាមស្មារតីដែលខ្លួនបានយល់។
ចំណែកនៅក្នុងព្រះពុទ្ធសាសនា ប្រាប់ឱ្យសិក្សាអំពីឫសគល់
មិនចេះតែជឿព្រោះនាំអំពល់ ពេលស្ដាប់បានយល់សឹមជឿរហូត។
ព្រះពុទ្ធសម្ដែងធម៌វិនិច្ឆ័យ ច្បាស់គ្មានសង្ស័យកាលាមសូត្រ។
ប្រាប់ឱ្យមនុស្សលោកធ្វើការពិសោធ ហេតុដប់នោះសោតគឺជួយគ្រប់គ្នា
ទីមួយ **មា អនុស្សវេន** កុំជឿអាងជាក់ព្រោះឮតគ្នា
ហើយចេះតែជឿវាទៈនានា ដឹងគ្រប់អង្គាហើយប្រុងស្មារតី។
ទីពីរ **មា បរម្បរាយ** កុំជឿស្ទើរស្ទាក់ពាក្យអ្នកដទៃ
អាងថាត្រឹមត្រូវមិនខុសអត្ថន័យ មិនគិតរំពៃស្វែងរកផ្លូវល្អ។
ទីបី **មា ឥតិកិរាយ** កុំជឿលើអ្នកនិទានថាល្អ
ឃើញឱ្យបានជាក់សង្កេតបន្ត កុំជឿតៗតាមប្រពៃណី។
បួន **មា បិដក សម្បទា-** **នេន** គ្រប់គ្នាកុំអាងគម្ពីរ

ប្រកាន់ថាត្រូវមិនខំសំភី ជឿស្លុងគ្មានពីរនៅក្នុងសាសនា។
ទីប្រាំគឺ **មា តក្កហេតុ** កុំជឿផ្ដាប់មុខត្រូវពិចារណា
រៀនស្ដាប់ឱ្យច្បាស់អំពីហេតុការណ៍ កុំប្រកាន់ថាហេតុនោះវាសម។
ទីប្រាំមួយ **មា នយហេតុ** ពួកជនគ្រប់ស្រុកកុំជឿផ្សេងផ្សំ
កាត់តាមដំរុយប្រកាន់បន្លំ ហេតុនោះមិនសមគួរកាន់យកបាន។
**មា អាការបរិវិត**- **ក្កេន** កុំដាក់ជឿតាមការស្មាន
ដោយអាការៈតាមអនុមាណ ជឿតាមសន្ដានបងប្អូនញាតិមិត្ត។
ប្រាំបីនោះ **មា ទិដ្ឋិនិជ្ឈា**- **នក្ខន្តិយា** កុំជឿគំនិត
តាមការយល់ឃើញថាសមពិតៗ ដោយការពេញចិត្តក្នុងរឿងនោះផង។
ប្រាំបួននោះគឺ **មា ភព្វ រូ**- **បតាយ** គ្រូប្រកាន់ទ្វេដង
បើបានស្ដាប់ហើយជឿស៊ប់តែម្ដង ហេតុនោះឯងហោងមិនគួរជឿឡើយ។
ដប់ **មា សមណោ នោ គរូតិ** ត្រូវមានសតិកុំបីកន្ដើយ
ប្រកាន់មាំថាសមណនេះហើយ អាចនាំដល់ត្រើយផុតក្ដីកង្វល់។
សេចក្ដីប្រកាន់ដោយមិនបានគិត បានត្រឹមខកចិត្តព្រោះគិតមិនដល់
ប្រាជ្ញាទន់ខ្សោយមិនបានតម្កល់ រៀនពីហេតុផលថាវាយ៉ាងហ្នឹង។
ព្រះពុទ្ធទ្រង់ត្រាស់ពន្យល់សេចក្ដី ប្រាប់ជនប្រុសស្រីឱ្យអ្នកបានដឹង
នេះជាកុសលអ្នកត្រូវខំប្រឹង អកុសលហ្នឹងអ្នកត្រូវខំលះ។
ព្រះធម៌ទាំងឡាយអ្នកប្រាជ្ញសរសើរ ទៅតាមដំណើរប្រញាប់រូតរះ
ព្រោះមានប្រយោជន៍ដូចបានជួបព្រះ រៀនឱ្យជ្រៅជ្រះទើបជួបសុខពិត។
តាមពិតជំនឿជឿក៏ជឿចុះ តែសូមស្រីប្រុសឱ្យច្បាស់ក្នុងចិត្ត
ប្រយ័ត្នជឿហើយនាំទុក្ខវិបរិត ព្រោះតែគំនិតគិតខ្វះប្រាជ្ញា។
ខ្ញុំពោលប៉ុណ្ណេះហាក់ដូចជាធ្ងន់ សូមអស់មហាជនអភ័យទោសា

បើមានកំហុសសូមទានមេត្តា ជួយប្រាប់ផងណាខ្ញុំនឹងកែប្រែ។
ការពោលយ៉ាងនេះព្រោះចង់ឱ្យល្អ ខ្មៅទៅជាសទេណាពុកម៉ែ
បើស្តាប់រួចហើយសូមឱ្យបានល្អែ កូនជូនបុណ្យម៉ែនិងលោកឪពុក។
ដោយអំណាចបុណ្យកូនទាំងប៉ុន្មាន ដែលរូបកូនបានធ្វើហើយសព្វមុខ
សូមជូនបងប្អូនជាតិខ្មែរចាំទុក តទៅជាតិមុខដល់និព្វានហោង។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ២.ដំណើរត្រាស់ដឹងរបស់ព្រះពុទ្ធអង្គ

ព្រះពោធិសត្វខំប្រឹងប្រព្រឹត្តនូវតបកម្ម ជាទុក្ករកិរិយា ដែលសត្វលោកធ្វើបានដោយលំបាក នាដងភ្នំដង្កេស្វារី។ បញ្ចវគ្គិយតាបសទាំង ៥ រូបមានកោណ្ឌញ្ញៈ ភទ្ទិយ វប្បៈ មហានាម អស្សជិ ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចប្រព្រឹត្តតបកម្ម ដោយយល់ឃើញថា ការប្រព្រឹត្តធ្វើយ៉ាងនេះ នឹងបានសម្រេចនូវមោក្ខធម៌ ជាទីក្សេម រួចផុតចាកកិលេសទាំងពួងមិនខាន។ តែអត្តកិលមថានុយោគនោះ ដែលព្រះពោធិសត្វខំប្រឹងប្រព្រឹត្តអស់ ៦ ឆ្នាំ មិនបានសម្រេចជាប្រយោជន៍អ្វីទាំងអស់ ក្រៅពីប្រព្រឹត្តខ្លួនឱ្យជាទុក្ខនោះឡើយ។ ថ្ងៃមួយព្រះពោធិសត្វពិចារណាថា ជនអ្នកបំពេញទុក្ករកិរិយាក្នុងលោកនេះ ប្រាកដស្មើដោយយើងមិនមានឡើយ ជនដែលអាចបំពេញ ទុក្ករកិរិយាឱ្យក្រៃលែងជាងនេះក៏មិនមានដែរ នេះមិនមែនជាផ្លូវត្រាស់ដឹង កាលយើងអង្គុយបំពេញសមាធិក្រោមដើមព្រីងនោះ ជាផ្លូវត្រាស់ដឹងទេដឹង? យើងមានរាងកាយចុះខ្សោយទ្រុឌទ្រោមយ៉ាងនេះ មិនអាចចម្រើនបសមាធិនោះបានឡើយ បើដូច្នោះ មានតែអាត្មាអញទំនុកបម្រុងរាងកាយដោយការបរិភោគអាហារ ទើបអាចចម្រើនសមាធិបាន។ ពេលនោះព្រះពោធិសត្វកាន់បាត្រ ចូលទៅបិណ្ឌបាតក្នុងសេនានិគម ហើយឆាន់ចង្ហាន់ត្រឹមពីរបីថ្ងៃ ព្រះវរកាយដ៏មានកម្លាំងប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ មានពណ៌សម្បុរដូចជាមាសជាប្រក្រតីឡើងវិញ។

គ្រានោះ ពួកបញ្ចវគ្គិយតាបសនាំគ្នាគិតថា មហាបុរសនេះ បំពេញទុក្ករកិរិយាដល់ទៅ ៦ ឆ្នាំ ក៏នៅតែមិនអាចធ្វើឱ្យជាក់ច្បាស់នូវសព្វញ្ញុត-ញ្ញាណឥឡូវនេះត្រាច់ទៅបិណ្ឌបាត្រក្នុងស្រុក និងនិគមជាដើម សោយ

អាហារ តើនឹងអាចត្រាស់ដឹងបានដូចម្ដេចទៅ? មហាបុរសនេះ ជាអ្នកប្រាថ្នាលាមកឃ្លៀងឃ្លាតចាកព្យាយាម តើមានប្រយោជន៍អ្វី ដែលពួកយើងនៅជាមួយ មហាបុរសនេះទៀត។ កាលពួកបញ្ចវគ្គិយតាបស ទាំងនោះគិតគ្នាយ៉ាងនេះហើយ ក៏នាំគ្នាលះបង់ព្រះពោធិសត្វ ទៅនៅក្នុង ព្រៃឥសិបតនមិគទាយ វ័ន ដើម្បីបំពេញទុក្ករកិរិយាបន្តទៀត។

ក្នុងពេលជិតភ្លឺ ថ្ងៃ១៤ កើត ព្រះពោធិសត្វទ្រង់ឃើញមហាសុបិនជាបុព្វនិមិត្ត ៥ ប្រការគឺៈ

**១**.ព្រះពោធិសត្វទ្រង់សុបិនឃើញ ព្រះអង្គសឹងលើមហាប្រឹថពី ស្ដេចភ្នំឈ្មោះហិមវន្តជាខ្នើយ ព្រះហស្ដឆ្វេងសណ្ដូកចុះក្នុង សមុទ្រខាង កើត ព្រះហស្ដស្ដាំសណ្ដូកចុះក្នុងសមុទ្រខាងលិច ព្រះបាទទាំងគូសណ្ដូក ចុះក្នុងសមុទ្រខាងត្បូង។

**២**.ព្រះពោធិសត្វទ្រង់សុបិនឃើញស្មៅចិញ្ចៀន ១ សរសៃ ដុះលេចអំពីផ្ចិតទៅទល់នឹងអាកាស។

**៣**.ព្រះពោធិសត្វទ្រង់សុបិនឃើញ មានពួកសត្វដង្កូវខ្លួនស ក្បាលខ្មៅវារចេញអំពីព្រះបាទទាំងគូ ចាប់ផ្ដើមអំពីចុងក្រចក ចោមរោមជិត ដរាបដល់មណ្ឌលនៃជង្គង់។

**៤**.ព្រះពោធិសត្វទ្រង់សុបិនឃើញមានសត្វបក្សី ៤ ពួក មានសម្បុរផ្សេងៗគ្នា ហើរមកអំពីទិសទាំង ៤ មកក្រាបចុះទៀបបាទមូល ក៏ត្រឡប់ជាមានសម្បុរសទាំងអស់ទៅវិញ។

**៥**.ព្រះពោធិសត្វទ្រង់សុបិនឃើញ ព្រះអង្គចង្រ្កមលើភ្នំលាមកដ៏ធំ មិនបានប្រឡាក់ដោយលាមកឡើយ។

# ៣.អត្ថន័យមហាសុបិន

**១**-ព្រះអង្គពិតជាបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ពិតប្រាកដ។

**២**-មគ្គប្រកបដោយអង្គ ៨ ដែលព្រះអង្គត្រាស់ដឹងហើយមនុស្ស និងទេវតាអាចប្រកាសបានដោយប្រពៃ។

**៣**-ពួកគ្រហស្ថស្លៀកពាក់ស នឹងដល់ព្រះអង្គជាសរណៈស្មើដោយជីវិត។

**៤**-វណ្ណៈទាំង ៤ គឺខត្តិយៈ ព្រហ្មណ៍ វេស្សៈ និងសូទ្រៈ ទាំង ៤ វណ្ណៈនេះ ចេញចាកផ្ទះមកបួសក្នុងធម៌វិន័យ ដែលព្រះអង្គទ្រង់សម្តែង ហើយធ្វើឱ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ។

**៥**-លាភសក្ការៈដែលកើតឡើងចំពោះព្រះអង្គហើយ ព្រះអង្គមិនបានជាប់ ដោយលាភសក្ការៈនោះឡើយ។

មហាបុរសទ្រង់ឃើញមហាសុបិន ៥ យ៉ាងនេះ ទ្រង់កែសុបិន ដោយព្រះអង្គឯងថា ថ្ងៃនេះយើងនឹងបានត្រាស់ដឹង ជាព្រះពុទ្ធពិតប្រាកដ ឥតមានអ្វីគួរឱ្យសង្ស័យឡើយ។ កាលអរុណរះឡើង ក្នុងថ្ងៃ១៥ កើត ពេញបូណ៌មី ព្រះអង្គយាងទៅគង់ក្រោមដើមអជបាលនិគ្រោធ រង់ចាំវេលា ត្រាច់ទៅបិណ្ឌបាត។

គ្រានោះ នាងសុជាតាជាម្តាយយសកុលបុត្រ ដែលជាធីតារបស់លោកសេនានីកុដុម្ពី ក្នុងស្រុកសេនានិគម ត្រង់តំបន់ឧរុវេលា ធ្លាប់បានតាំងសេចក្តីប្រាថ្នាថានូវត្រង់គល់និគ្រោធ(ដើមជ្រៃ)នោះ ហើយមានបំណងយកមធុបាយាសទៅសែន ទើបប្រើនាងបុណ្ណាទាសី ជាមេដោះរបស់ខ្លួន

ទៅសម្អាតក្រោមដើមជ្រៃនោះ។ កាលនាងបុណ្ណាទាសីទៅដល់ទីនោះ បាន ឃើញព្រះពោធិសត្វ កំពុងគង់បែរព្រះភក្ត្រទៅទិសខាងកើត មានព្រះវរ-កាយរុងរឿងដោយពន្លឺ ទើបមានសេចក្តីត្រិះរិះថា ទេវតារបស់ពួកយើង មក រង់ចាំទទួលនូវពលិកម្មរបស់ពួកយើង ហើយត្រឡប់ទៅប្រាប់ នាង សុជាតា តាមអ្វីដែលខ្លួនបានឃើញ។

លំដាប់នោះ នាងសុជាតាកើតសទ្ធាព្រមហើយ បានតាក់តែងនូវ គ្រឿងប្រដាប់គ្រប់យ៉ាង ឱ្យមនុស្សដាក់មធុបាយាសដែលមានរសដ៏ ត្រកាលក្នុងភាជនៈមាស ដែលមានតម្លៃ ១០០.០០០ កហាបណៈ ហើយ យកសជីមាសមកគ្របពីលើ ទូលតម្រង់ទៅគល់ដើមជ្រៃ។

កាលនាងសុជាតាទៅដល់ដើមជ្រៃ ឃើញព្រះពោធិសត្វ មានពន្លឺល្អ ចេញពីព្រះវរកាយ ធ្វើឱ្យដើមឈើទាំងអស់ មានពណ៌ដូចជាមាសក៏មាន ការសម្គាល់ថាជារុក្ខទេវតា។ ពេលនោះនាងសុជាតាក៏បង្អោនមធុបាយាស ទៅក្នុងព្រះហស្តព្រះពោធិសត្វហើយពោលថា **យថា មម មនោរថោ និប្ផន្នោ ឯវំ តុម្ហាកម្បិ មនោរថោ និប្ផជ្ជតុ** មនោរថរបស់ខ្ញុំបាន សម្រេចហើយយ៉ាងណា សូម្បីលោកក៏សូមឱ្យបានសម្រេចតាមមនោរថ យ៉ាងនោះដែរ គ្រាន់តែពោលយ៉ាងនេះ នាងសុជាតាក៏ជៀសចេញទៅ។

លំដាប់នោះព្រះបរមពោធិសត្វទ្រង់កាន់ភាជនៈមាស យាងទៅកាន់ មាត់ស្ទឹងនេរញ្ជរា ព្រះអង្គទ្រង់ដាក់ភាជនៈមាស ត្រង់កំពង់ទឹកឈ្មោះ សុប្ប តិដ្ឋៈហើយនិមន្តចុះ។ កាលព្រះពោធិសត្វយាងចុះ ស្រង់ទឹករួច ហើយទ្រង់ ឡើងមកវិញ យាងទៅគង់ក្រោមម្លប់ឈើមួយ ដ៏សែនត្រជាក់ គួរជាទីសប្បា យ។ ពេលនោះ ព្រះអង្គពូតមធុបាយាសជាដុំៗចំនួន ៤៩ ពំនូត ហើយទ្រង់ ឆាន់មធូកបាយាសនូវត្រង់កំពង់ស្ទឹងនេរញ្ជរានោះឯង។

កាលព្រះអង្គទ្រង់ឆាន់ស្រេចហើយ ទ្រង់លើកភាជន៍មាសឡើង ព្រមជាមួយនឹងការអធិដ្ឋានថា **សចាហំ អជ្ជ ពុទ្ធោ ភវិស្សាមិ អយំ សុវណ្ណបាតិ បដិសោតំ គច្ឆតុ** ប្រសិនបើក្នុងថ្ងៃនេះ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ សូមឱ្យភាជនៈមាសនេះ អណ្តែតបញ្ច្រាសក្រសែទឹក ហើយព្រះអង្គក៏បោះភាជន៍មាសចូលទៅក្នុងស្ទឹងនេរញ្ជរា។ ភាជន៍មាសនោះ ក៏បានអណ្តែតបញ្ច្រាសក្រសែទឹកមែន ហើយក៏បានលិចចុះទៅទីលំនៅរបស់កាលនាគរាជ។

គ្រានោះ ព្រះពោធិសត្វគង់សម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃសាលព្រឹក្សដែលគួរជាទីរីករាយមានពណ៌ខៀវស្រស់ មានក្លិនក្រអូបយ៉ាងក្រៃលែង ជិតមាត់ស្ទឹងនេរញ្ជរា ទ្រង់បំពេញព្យាយាមរហូតកើតសមាបត្តិ ៨ និង អភិញ្ញា ៦ ហើយព្រះអង្គក្រោកពីព្រៃសាលវ័ន យាងទៅតាមផ្លូវ ដែលពួក ទេវតាតាក់តែងហើយ មានព្រះភក្ត្រឆ្ពោះទៅដើមមហាពោធិព្រឹក្ស ពួក ទេវតា នាគ និងគន្ធព្វជាដើមបាននាំគ្នាបូជាព្រះអង្គដោយផ្កាកម្រង និង គ្រឿងក្រអូប។ គ្រានោះសោត្ថិយព្រាហ្មណ៍ជាអ្នករកស្មៅ កាន់ស្បូវស្គា ដើរតាមផ្លូវបញ្ច្រាសទិសរបស់ព្រះអង្គ ដឹងអាការៈរបស់មហាបុរស ទើប បានថ្វាយស្បូវស្គា ៨ ក្តាប់ចំពោះព្រះអង្គ។ ព្រះពោធិសត្វទទួលយក ស្បូវស្គា ហើយស្តេចយាងចូលទៅកាន់គល់អស្សត្ថព្រឹក្ស(ព្រះពោធិព្រឹក្ស) ដែលលជាដើមឈើមានជ័យជម្នះ ដូចកំពូលភ្នំអសិតញ្ជនៈបាំងរស្មីដួង ទិវាករ មានម្លប់ត្រជាក់ជាទីគួរសប្បាយ ដូចព្រះទ័យព្រះអង្គត្រជាក់ទៅ ដោយករុណាប្រាសចាកជំនុំពួកវិហង្គផ្សេងៗ មានស្លឹកត្រសាយត្រសុំ ខ្យល់បក់មកប៉ះរវិចៗ ព្រះអង្គយាងទៅគង់ទិសទក្សិណ។ ស្ថានទីទិស ទក្សិណនោះញាប់

ញ័រ ដូចជាតំណក់ទឹកនៅលើស្លឹកឈូក មហាបុរស ទ្រង់ត្រិះរិះថា ស្ថានទីនេះមិនអាចញុំាងគុណវិសេសឱ្យកើតឡើង ដល់អាត្មា
អញឡើយ ទើបយាងទៅទិសឧត្តរ សូម្បីទិសឧត្តរនោះក៏ញាប់ញ័រដូចគ្នា។ ពេលនោះព្រះអង្គយាង ទៅគង់ទិសបូព៌ ក្នុងទិសបូព៌នេះ មិនញាប់ញ័រអ្វីឡើយ។ មហាបុរសធ្វូន់ក្នុងចិត្តថា ទីនេះជាទីកម្ចាត់កិលេសពិតប្រាកដ ទើបទ្រង់ឈរទិសល្វសានចាប់ចុងស្បូវស្គាអង្រួនដាក់លើដី។ ខណៈពេលនោះស្រាប់តែក្លាយទៅជារតនបល្ល័ង្កប្រមាណ ១៤ ហត្ថ។ ស្បូវស្គាទាំងនោះដូចគេវេញចូលគ្នាដ៏ស្អាតវិចិត្រ។ មហាបុរសគង់ពែនព្រះភ្នែនលើរតនបល្ល័ង្កនោះ ទ្រង់អធិដ្ឋានសេចក្ដីព្យាយាមមានអង្គ៤ ដោយទ្រង់ត្រិះរិះថា សាច់ ស្បែក សរសៃ ឆ្អឹង និងឈាមក្នុងរាងកាយ នឹងរីងស្ងួតទៅក៏ដោយ បើយើងមិនបានចាក់ធ្លុះនូវវត្ថុ ដែលបុគ្គលគប្បីចាក់ធ្លុះដោយកម្លាំងរបស់បុរស ដោយការព្យាយាមនោទ្រង់អធិដ្ឋានបន្តទៀតថា ទោះបីមហាប្រឹថពីនេះក្រឡាប់ក៏ដោយ សូម្បីមានគ្រឿងប្រហារ ១.០០០ ធ្លាក់ចុះមកក៏ដោយទោះផ្លូវក្នុងព្រៃនេះ បែកបាក់ខ្ទេចខ្ទីក៏ដោយ ទោះបីជាដុំគំនរភ្នំធ្លាក់ចុះមកក៏ដោយ បើអាត្មាអញមិនទម្លុះនូវសម្មាសម្ពោធិញ្ញាណទេ អាត្មាអញនឹងមិនឈប់ព្យាយាមឡើយ ហើយព្រះអង្គទ្រង់គង់ក្រោមគល់មហាពោធិ-ព្រឹក្សមានព្រះភក្ត្របែរទៅទិសខាងកើត ព្រះបិដ្ឋិ(ខ្នង)ព្រះអង្គបែរទៅទិសបស្ចិមនាដើមមហាពោធិព្រឹក្ស ដែលមានខ្នាតប្រមាណ ៥០ ហត្ថ ហាក់ដូចជាមាស មានមែកដូចជាឆត្រកែវបាំងពីខាងលើបណ្ដូលពោធិ ធ្លាក់ចុះមកលើចីវរ ដែលមានពណ៌ដូចជាដុំមាស ទីនោះមានពន្លឺរុងរឿងដូចកែវ ប្រពាឡដែលគេដាក់ទុកក្នុងផែនមាស។

គ្រានោះ វសវត្តីមារអ្នកមានអំណាចលើសត្វលោកទាំងអស់ បានលះភាពជាធំលើពួកទេពរបស់ខ្លួនអស់វេលា ៦ ឆ្នាំ ប្រើចិត្តកំណត់ដឹងចិត្តរបស់មហាបុរស ដើម្បីឃ្លាំមើលមិនឃើញសេចក្តីភ្លាំងភ្លាត់អ្វីតិចតួច ទើបគិតថា សិទ្ធត្ថនេះ មកអង្គុយក្រោមដើមពោធិ ដើម្បីត្រាស់ដឹងជាព្រះពុទ្ធត្រូវការកន្លងវិស័យរបស់យើង ពេលនេះយើងមិនឱ្យសិទ្ធត្ថនេះ កន្លងវិស័យយើងបានឡើយ។ កាលណោះ វសវត្តីមារត្រឡប់ទៅកាន់វសត្តីទេវលោក ប្រជុំពលមាររបស់ខ្លួនហើយបញ្ជាថា ពួកលោកចូរនិម្មិតខ្លួនជាភេទប្លែកៗ គួរឱ្យខ្លាចកាន់អាវុធផ្សេងៗក្នុងដៃ ហើយនាំគ្នាចូលទៅរកសិទ្ធត្ថឱ្យដូច រលកហូរចូលទៅ។ ចំណែកវសវត្តីមារខ្លួនឯង ជិះដំរីមេខលា ដែលមានកម្ពស់១៥០ យោជន៍ និម្មិតដៃ ១.០០០ កាន់អាវុធនានា ហើយតម្រង់មករកព្រះពោធិ - សត្វ។ ចំណែកបរិស័ទរបស់ខ្លួនកាន់យកអាវុធផ្សេងៗគ្រប់ដៃមានដាវ កាំបិត ព្រួញ និងលំពែងជាដើម ពាក់ភួងពស់ យកមាត់បៀមពិស ផ្លុំ ភ្លើងចេញពីមាត់ មានកាយអាក្រាត សម្បុរកខ្វក់និម្មិតភេទផ្សេងៗ ដូចជា ប្រេតមានតែគ្រោងឆ្អឹងជាដើម ធ្វើរូបប្លែកៗគួរឱ្យខ្លាចជាច្រើន ឡោមព័ទ្ធ ជុំវិញព្រះពោធិសត្វ។

កាលវសវត្តីមារចូលទៅជិតព្រះបរមពោធិសត្វយ៉ាងនេះ ទេវតាទាំងឡាយ មានសក្កទេវរាជជាដើម សូម្បីត្រឹមមួយអង្គដែលអាចស្ថិតនៅទីនោះមិនមានឡើយ នាំគ្នារត់ចេញទៅទីដទៃៗ។ ចំណែកសក្កទេវរាជបានយកសង្ខវិជយយុត្តដាក់ខាងក្រោយ រត់ទៅរហូតដល់មាត់កណ្តាប់ចក្កវាឡ។ មហាព្រហ្មកាន់ស្វេតច្ឆត្រទៅកាន់ព្រហ្មលោក។ កាលនាគរាជលះបង់ពួកនាគរបាំងទាំងឡាយ ក៏មុជចុះក្នុងផែនដីរហូតដល់ពិភពនាគដែលមានមណ្ឌប ៥០០ យោជន៍ ហើយដេកយកដៃបិទមុខ កាលណោះមានព្រះ

ពោធិសត្វមួយអង្គឯងប៉ុណ្ណោះ មិនមានទេវតាឯណានីមួយ ស្ថិតនៅក្នុង ទីនោះឡើយ ដូចព្រហ្មក្នុងសុញ្ញវិមាន។

ទេវបុត្រមារនោះ ជាឱបបាតិកកំណើតជាទេវបុត្រធំក្នុងកាមាវចរ សួគ៌។ ពេលខ្លះអាចចូលសណ្ឋិត ក្នុងរាងកាយរបស់ពួកព្រហ្មបារិសជ្ជាបាន មារនោះ ទើបសម្គាល់ខ្លួនថា យើងជាអ្នកធំជាងសត្វលោកទាំងពួង យើងជាអ្នកប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ព្រោះហេតុនោះ តិះដៀលព្រះអង្គថា សមណៈនេះកើតក្នុងកលលៈ ពោលគឺគ្រាប់ឈាម របស់មនុស្សស្រី ដូចជាដង្កូវកើតក្នុងសាច់ សមណៈនេះមិនដឹងប្រមាណ របស់ខ្លួន ហ៊ានអង្គុយមុខអញមិនក្រោកចាកទីនេះ។

ក្នុងគ្រានោះ មារបានបណ្ដាលភ្លៀង ៩ ប្រការ ដើម្បីញុំាងភ័យឱ្យកើតឡើង ចំពោះព្រះពោធិសត្វ។

បណ្ដាលឱ្យកើតខ្យល់ព្យុះដែលមានសន្ទុះយ៉ាងខ្លាំង អាចបក់បោកដើមឈើឱ្យរលំ បក់ថ្មឱ្យប្រេីង អាចបណ្ដាលឱ្យរបើកដំបូលផ្ទះបាន តែមិនអាចធ្វើ សូម្បីត្រឹមតែជាយចីវរ ព្រះពោធិសត្វឱ្យកម្រើកបានឡើយ។

បណ្ដាលឱ្យកើតធ្លាក់គ្រាប់ភ្លៀងធំៗ មកលើព្រះពោធិសត្វ តែមិនអាចធ្វើសូម្បីឱ្យទទឹកជាយចីវរ ព្រះពោធិសត្វបានឡើយ។

បណ្ដាលឱ្យកើតភ្លៀងរភ្លើងថ្ម ដែលមានកម្ដៅដ៏ក្ដៅធ្លាក់ចុះមកលើព្រះពោធិសត្វ តែរងើកភ្លើងថ្មនោះក្លាយជាកម្រងផ្កាទៅវិញ។

បណ្ដាលឱ្យកើតភ្លៀងអាវុធមុខមួយ អាវុធមុខពីរ មានសរ លំពែង និងដាវជាដើម ធ្លាក់ចុះពីព្ធដ៏អាកាស មកលើព្រះពោធិសត្វ តែក្លាយទៅជាភួងផ្កាម្លិះជាដើម រោយរាយធ្លាក់ចុះមកវិញ។

បណ្តាលឱ្យកើតភ្លៀងអណ្តាតភ្លើង ធ្លាក់ចុះពីអាកាស មកលើព្រះពោធិសត្វ ស្រាប់តែក្លាយជាលម្អិតខ្លឹមចន្ទន៍ធ្លាក់ចុះមកវិញ។

បណ្តាលឱ្យកើតខ្សាច់ធ្លាក់ចុះមក ភ្លៀងខ្សាច់ដ៏ក្តៅគគុកនោះ ក៏ក្លាយទៅជាកេសរផ្កាធ្លាក់ចុះមកវិញ។

បណ្តាលឱ្យកើតភ្លៀងភក់ធ្លាក់ចុះមក ភ្លៀងភក់នោះមានកម្តៅយ៉ាងខ្លាំងធ្លាក់ចុះមក ស្រាប់តែក្លាយទៅជាភក់មានក្លិនក្រអូបទៅវិញ។

បណ្តាលឱ្យកើតគប់ភ្លើងមានចំនួនច្រើនធ្លាក់ចុះមក កម្ទេចភ្លើង និងផ្សែងភ្លើងពាសពេញអាកាស រន្ទះបាញ់ចំនួនមួយពាន់ឮកក្រើករំពើក ញាប់ញ័រពេញផ្ទៃអាកាសា។

កាលមារាធិរាជមិនអាចធ្វើអ្វីចំពោះព្រះពោធិសត្វបាន មានបំណងចូលទៅកាន់ព្រះសីសៈព្រះមហាបុរស ទើបចាប់ចក្រាវុធ បោះចូលទៅរកព្រះពោធិសត្វ ស្រាប់តែចក្រាវុធនោះធ្លាក់ចុះជិតព្រះបាទ ដូចជាសំពត់ជូតព្រះបាទព្រះអង្គទៅវិញ។ ព្រះពោធិសត្វសម្លឹងមើលមារ និងសេនារបស់មារដោយមេត្តាចិត្ត ប្រៀបដូចបិតាសម្លឹងមើលមុខបុត្រ។

គ្រានោះព្រះពោធិសត្វពោលចំពោះមារថា **ន ជានាតិ សយំ មយ្ហំ ទាសភាវម្បយំ ខលោ** ម្នាលមារល្ងង់អ្នកឯងមិនដឹងខ្លួនឯងជាទាស ៈរបស់យើងសោះ។ អ្នកឯងជិះដំរីមេខលា មានសេនាដ៏ច្រើនមានបំណងឱ្យយើងឃ្លាតចាកទីនេះ អ្នកឯងមិនអាចធ្វើឱ្យយើងឃ្លាតចាកបល្ល័ង្កនេះបានឡើយ។

ពេលនោះ វសវត្តីមារសួរព្រះពោធិសត្វថា នែ៎! សិទ្ធត្ថ ហេតុដូចម្តេចលោកទើបមកអង្គុយលើបល្ល័ង្ករបស់យើង? ព្រះពោធិសត្វសួរអ្នកណាជា

សាក្សីរបស់អ្នក? គ្រានោះ សេនាមារច្រើនសែនកោដិនាំគ្នាពោលព្រមគ្នាថាយើងជាសាក្សីៗ។ ព្រះពោធិសត្វក៏ពោលពីសាក្សីរបស់ព្រះអង្គថាៈ

**បល្លង្កំ មម ភាសាយ ភិមត្ថញ្ញេន សក្ខិនា**
**កម្បិតា មទ្ទិយា ទានា សក្ខិ ហោតិ អយំ មហិ ។**

បល្ល័ង្កនេះជារបស់យើង យើងនឹងអាងសាក្សីដទៃធ្វើអ្វី ផែនដីនេះធ្លាប់ញាប់ញ័រមកហើយ ព្រោះការឱ្យនាងមទ្រី រមែងជាសាក្សីបាន។

អធិប្បាយថា ម្នាលមារមានចិត្តបាប យើងប្រាថ្នាបល្ល័ង្កនេះ ដោយជាអ្នកមិនបានឱ្យទាន មិនបានរក្សាសីល មិនបានធ្វើទុក្ករកិរិយា អស់ច្រើនរាប់ប្រមាណក៏មិនទេ។ កាលយើងឱ្យទាន ៧ ដង រហូតដល់ឱ្យនាង មទ្រីទេវីជាទីចុងក្រោយក្នុងជាតិជាវេស្សន្តរ ផែនដីនេះកក្រើកញាប់ញ័រអស់ ៧ ដង។ ឥឡូវនេះ យើងអង្គុយលើអបរាជិតបល្ល័ង្ក ដើម្បីយកជ័យជម្នះ ដល់សត្វលោកទាំងអស់ ការតបជាមួយមារដែលមានសេនាដ៏ច្រើនយ៉ាងនេះ តើផែនដីដ៏ធំនេះ នឹងនៅស្ងៀមព្រងើយដូចម្ដេចកើត? មារឯងបានឱ្យសេនារបស់ខ្លួនជាសាក្សីកោង ឯផែនដីនេះវិញ ជាអ្នកស្មើដោយយើង និងអ្នក។ ផែនដីនេះ ទោះបីមិនមានចិត្ត ក៏អាចធ្វើជាសាក្សីរបស់យើងទាំងពីរបាន គ្រាតែព្រះបរមពោធិសត្វពោលត្រឹមប៉ុណ្ណោះ ក៏លាសណ្ដូកព្រះហស្តចេញពីជាយចីវរចង្អុលទៅផែនដី។

ខណៈនោះ ផែនដីដ៏ធំនេះក៏កក្រើករំពើកញាប់ញ័រ មានសំឡេងលាន់ឮកឹកកងពេញអាកាស ផ្គរក៏លាន់ឮឡើង ដូចជាគ្រប់សង្កត់ភ្នំទាំង ៧ ។ ផ្ទៃចក្កវាឡទាំងអស់ក៏លាន់ឮឡើង ដូចជាភ្លើងឆេះព្រៃ។

វសវត្តីមានរស្មិតនៅក្នុងរវាងផែនដី និងអាកាសមិនមានអ្វី ជ្រកពួន មិនមានអ្វីជាទីពឹងមិនមានអ្វីជាសរណៈ ក៏គ្រវែងអាវុធ ១.០០០ ចោល ក្នុងទីនោះ សូម្បីដំរីមេខលាក៏មិនសម្លឹងមើលបន្តិច ជៀសចេញទៅបាត់។

កាលមារជៀសចេញទៅបាត់ សេនារបស់មារក៏នាំគ្នាបែកខ្ញែកទៅកាន់ស្ថានទេវលោកជាន់វសវត្តីវិញ។

កាលសេនាមារជៀសចេញពីទីនោះបាត់ទៅ ពួកទេវតាទាំងឡាយជាដើមគិតគ្នាថា **មារស្ស បរាជយោ ជាតោ សិទ្ធត្ថកុមារស្ស ជយោ ជាតោ ជយបូជំ ករិស្សាម** មារប្រាកដជាបរាជ័យ មិនខានទេ សិទ្ធត្ថកុមារប្រាកដជាឈ្នះមារ មកពួកយើងនឹងធ្វើនូវជយបូជា។

ក្នុងកាលណោះទេវតា បានស្រែកថ្វាយជ័យទី ១ ពួកនាគ ទី ២ ពួកគ្រុឌទី ៣ ពួកព្រហ្មទី ៤។ ដូចក្នុងគម្ពីរវិសុទ្ធជន វិលាសិនីអដ្ឋកថា អបទានត្រង់ពុទ្ធវគ្គបញ្ជាក់ថាៈ

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ**
**ឧគ្ឃោសយិំសុ ពោធិមណ្ឌេ បមោទិតា**
**ជយំ តទា នាគគណា មហេសិនោ។**

គ្រានោះ ពួកនាគទាំងឡាយផង មកជួបជុំគ្នាហើយត្រង់ពោធិមណ្ឌល ហើយមានចិត្តត្រេកអររីករាយថ្វាយទិព្វបុប្ផា ថ្វាយព្រះពរជ័យ ដល់ព្រះមហាឫស្សី ដែលព្រះអង្គស្វែងរកគុណដ៏ធំយ៉ាងនេះថា ព្រះពុទ្ធដ៏ មានសិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាបចុះចាញ់ព្រះអង្គហើយ។

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ**

**ឧគ្ឃោសិយុំ ពោធិមណ្ឌេ បមោទិតា**
**ជយំ តទា សុបណ្ណសង្ឃាបិ មហេសិនោ ។**

គ្រានោះ ពួកគ្រុឌទាំងឡាយផង មកជួបជុំគ្នាហើយត្រង់ពោធិមណ្ឌល ហើយមានចិត្តត្រេកអររីករាយ ថ្វាយទិព្វបុប្ផា ថ្វាយព្រះពរជ័យដល់ព្រះមហាឫស្សី ដែលព្រះអង្គស្វែងរកគុណដ៏ធំយ៉ាងនេះថា ព្រះពុទ្ធដ៏មានសិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាបចុះចាញ់ព្រះអង្គហើយ។

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ**
**ឧគ្ឃោសិយុំ ពោធិមណ្ឌេ បមោទិតា**
**ជយំ តទា ទេវគណា មហេសិនោ។**

គ្រានោះ ពួកទេវតាទាំងឡាយផង មកជួបជុំគ្នាហើយត្រង់ពោធិមណ្ឌល ហើយមានចិត្តត្រេកអររីករាយ ថ្វាយទិព្វបុប្ផា ថ្វាយព្រះពរជ័យដល់ព្រះមហាឫស្សី ដែលព្រះអង្គស្វែងរកគុណដ៏ធំយ៉ាងនេះថា ព្រះពុទ្ធដ៏សិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាបចុះចាញ់ព្រះអង្គហើយ។

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ**
**ឧគ្ឃោសិយុំ ពោធិមណ្ឌេ បមោទិតា**
**ជយំ តទា ព្រហ្មគណា មហេសិនោ។**

គ្រានោះ ពួកព្រហ្មទាំងឡាយផង មកជួបជុំគ្នាហើយត្រង់ពោធិមណ្ឌល ហើយមានចិត្តត្រេកអររីករាយ ថ្វាយទិព្វបុប្ផា ថ្វាយព្រះពរជ័យដល់ព្រះមហាឫស្សី ដែលព្រះអង្គស្វែងរកគុណដ៏ធំយ៉ាងនេះថា ព្រះពុទ្ធដ៏មានសិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាបចុះចាញ់ព្រះអង្គហើយ។

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ**
**ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា**
**ជយំ តទា នាគគណា មហេសិនោ។**

គ្រានេះ ពួកយើងខ្ញុំព្រះករុណាទាំងឡាយផង(ទាំងបព្វជិត ទាំងគ្រហស្ថ)បានមកជួបជុំគ្នាហើយត្រង់ពោធិមណ្ឌល(នាអារាម...) ហើយមានចិត្តត្រេកអររីករាយ ថ្វាយនូវគ្រឿងសក្ការបូជាទាំងឡាយ មានទៀនធូប និងផ្កាភ្ញី ព្រមទាំងគ្រឿងក្រអូបផ្សេងៗ ចំពោះព្រះរតនត្រ័យ ហើយថ្វាយព្រះពរជ័យដល់ព្រះមហាឫស្សី ដែលព្រះអង្គស្វែងរកគុណដ៏ធំយ៉ាងនេះថាព្រះពុទ្ធដ៏មានសិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាបចុះចាញ់ព្រះអង្គហើយ។

ក្នុងរាត្រីបឋមយាមថ្ងៃ ១៥ កើតពេញបូណ៌មី ខែពិសាខ ព្រះអង្គទ្រង់សម្រេចនូវបុព្វេនិវាសានុស្សតិញ្ញាណ មជ្ឈិមយាម ទ្រង់សម្រេចបាននូវចុតូបបាតញ្ញាណ គឺទិព្វចក្ខុក្នុងបច្ឆិមយាមនៃរាត្រីព្រះអង្គទ្រង់ពិចារណានូវបច្ចយាការៈ ញ៉ាំងអនាបានចតុត្ថជ្ឈានឱ្យកើតឡើង ធ្វើឈាននោះជាបាទចម្រើនវិបស្សនា ញ៉ាំងកិលេសទាំងពួងឱ្យអស់ទៅដោយមគ្គទី ៤ គឺអរហត្តមគ្គ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណដំណាលគ្នានឹងអរុណរះឡើង។ ក្នុង ខណៈដែលព្រះអង្គទ្រង់សម្រេចនូវសព្វញ្ញុតញ្ញាណ ក៏ទ្រង់ព្រះនាមថាសម្មាសម្ពុទ្ធក្នុងលោកនេះ។

ក្នុងកាលណោះ លោកធាតុមួយម៉ឺន ក៏មានពន្លឺភ្លឺព្រោងព្រាតផែនដីកម្រើកញាប់ញ័រ រហូតដល់ទឹកជាទីទ្រផែនដីបុព្វនិមិត្ត ៣២ ប្រការ ក៏បានកើតឡើង។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រិះរិះថាយើងរួចផុតចាកសង្សារ

វដ្តដ៏ធំហើយហ្ន៎ ពុទ្ធភូមិដ៏ក្រៃលែងនេះ យើងបានសម្រេចហើយ ជ័យជម្នះដ៏ធំយើងបានធ្វើហើយ ធម្មចក្កដ៏ធំក្រៃលែងយើងបានហើយ។

ម្យ៉ាងទៀត យើងជាអ្នកសមគួរសម្ដែងធម៌ដល់មហាជន ហើយអាចរំដោះមហាជនឱ្យរួចផុតចាកពន្ធនាគារគឺភព។ កាលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រិះរិះយ៉ាងនេះហើយ បីតិយ៉ាងក្រៃលែងក៏បានកើតឡើង ព្រះអង្គក៏ទ្រង់បន្លឺឧទានដោយបីតិថា:

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ។**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា។**

កាលតថាគត មិនទាន់បានជួបប្រទះ(ពោធិញ្ញាណរវល់តែ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហាអ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ដមានជាតិដ៏ច្រើន សេចក្ដីកើតជាទុក្ខរឿយៗ។ នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាពតថាគត ឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀតមិន បានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដម្បូលផ្ទះគឺ អវិជ្ជា តថាគតកម្ទាត់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ។

### សប្ដាហ៍ ១ បន្ទាប់ពីត្រាស់ដឹង

បន្ទាប់មកព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បន្លឺព្រះឧទានហើយ ព្រះអង្គទ្រង់គង់ពែនព្រះភ្នែនចូលសមាបត្តិ សោយវិមុត្តិសុខលើបល្ល័ង្ក ក្រោមដើម

សិរីមហាពោធិព្រឹក្សអស់ចំនួន ៧ ថ្ងៃ ដោយព្រះទ័យថា យើងបំពេញបារមីមកអស់ចំនួន ៤ អសង្ខេយ្យ ១ សែនកប្ប ព្រោះអាស្រ័យបល័ង្កនេះ បល្ល័ង្កនេះ ជាវិជយបល្ល័ង្ក ជាមង្គលបល្ល័ង្ករបស់យើង។

## សប្តាហ៍ទី ២ បន្ទាប់ពីត្រាស់ដឹង

កាលព្រះសម្មាសម្ពុទ្ធ ព្រះអង្គគង់ស្ងៀមក្រោមសិរីមហាពោធិព្រឹក្សអស់មួយសប្តាហ៍យ៉ាងនេះ។ ពួកទេវតាទាំងឡាយគិតគ្នាថា សិទ្ធត្ថ ទំនងមានកិច្ចដែលត្រូវធ្វើទៀត ទេដឹង! បានជាមិនលះបង់នូវសេចក្តីអាល័យក្នុងបល្ល័ង្កនេះ។ គ្រានោះ ព្រះសាស្តាដើម្បីនិមន្តកម្ចាត់បង់នូវមន្ទិលសង្ស័យរបស់ទេវតាទាំងឡាយ ទ្រង់ហោះឡើងអាកាស សម្តែងនូវយមកប្បាដិ-ហារិយ៍ ដូចថ្ងៃព្រះអង្គសម្តែងយមកប្បាដិហារិយ៍ក្នុងក្រុងសាវត្ថី។

ពេលនោះ ទេវតា ទាំងឡាយក៏ប្រាកដក្នុងចិត្តថា ព្រះសិទ្ធត្ថបានត្រាស់ដឹងជាព្រះពុទ្ធពិតប្រាកដហើយ។

បន្ទាប់ពីព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងនូវយមកបាដិហារ្យហើយ ព្រះអង្គទ្រង់យាងចុះទិសខាងជើង ឈរសម្លឹងមើលបល្ល័ង្គ និងសិរីមហាពោធិព្រឹក្ស ដែលជាទីសម្រេចនូវផលនៃបារមីអស់ចំនួន ៤ អសង្ខេយ្យ ១ សែនកប្ប ដោយព្រះទ័យថា យើងបានសម្រេចហើយនូវសព្វញ្ញុតញ្ញាណ លើ បល្ល័ង្កនេះហ្ន៎។ ព្រះអង្គទ្រង់ឈរសម្លឹងមើល មិនពព្រិចព្រះនេត្រអស់ ចំនួន ៧ ថ្ងៃ។ ទីនោះមានឈ្មោះថា អនិមិសកចេតិយ ។

## សប្តាហ៍ទី ៣ បន្ទាប់ពីត្រាស់ដឹង

បន្ទាប់ពីព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ចង្រ្កមជិតដើមមហាពោធិព្រឹក្ស ពីទិសខាងកើត ទៅទិសខាងលិចអស់ចំនួន ៧ ថ្ងៃ។ ទីនោះមានឈ្មោះថា រតនចង្កមចេតិយ។

សប្តាហ៍ទី ៤ បន្ទាប់ពីត្រាស់ដឹង

ក្នុងសប្តាហ៍ទី ៤ ពួកទេវតាបាននិម្មិតនូវផ្ទះកែវក្នុងទិសពាយព្យ ថ្វាយចំពោះព្រះអង្គ ។ កាលណោះ ព្រះសម្មាសម្ពុទ្ធទ្រង់និមន្តគង់ពែនភ្នែន ពិចារណានូវគម្ពីរព្រះត្រៃបិដក គឺ វិនយបិដក សុត្តន្តបិដក អភិធម្មបិដក ។ កាលព្រះអង្គទ្រង់ពិចារណារហូតដល់មហាបដ្ឋាន ក៏មានពន្លឺដ៏ខ្លាំងក្លាចេញពីព្រះវរកាយព្រះអង្គ ភ្លឺព្រោងព្រាតចាក់ផ្លុះរហូតពេញមួយម៉ឺនលោកធាតុ។

សប្តាហ៍ទី ៥ បន្ទាប់ពីត្រាស់ដឹង

ក្នុងសប្តាហ៍ទី ៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់និមន្តទៅគង់ក្រោមដើមអជបាលនិគ្រោធជាស្ថានទី ដែលព្រះអង្គទ្រង់ទទួលចង្ហាន់នាងសុជាតាកាលនៅជាព្រះពោធិសត្វ។

គ្រានោះឯងមានព្រាហ្មណ៍ម្នាក់ឈ្មោះហុំហុំកជាតិកៈ (មានជាតិជាអ្នកធ្វើសំឡេងគម្រាមថា ហុំហុំ ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះធ្វើពាក្យគួរជាទីរីករាយ គួរជាទីរឭកឱ្យសម្រេចហើយក៏ឋិតនៅ ក្នុង កន្លែងដ៏សមគួរ។ លុះព្រាហ្មណ៍នោះឋិតនៅកន្លែងដ៏សមគួរហើយទើប និយាយពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន បុគ្គលដែលបានឈ្មោះថា ព្រាហ្មណ៍ដោយហេតុប៉ុន្មានយ៉ាង ម្យ៉ាងទៀត ធម៌អ្វីខ្លះសម្រាប់ធ្វើបុគ្គលឱ្យជាព្រាហ្មណ៍។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយក៏បន្លឺនូវឧទាន គាថានេះក្នុងវេលា នោះថាៈ

**យោ ព្រាហ្មណោ ពាហិតបាបធម្មោ**
**នីហុំហុកោ និក្កសាវោ និក្កសាវោ យតត្តោ**
**វេទន្តគូ វុសិតព្រហ្មចរិយោ**
**ធម្មេន សោ ព្រហ្មវាទំ វទេយ្យ**
**យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេ។**

ព្រាហ្មណ៍ណា មានបាបធម៌បណ្ដេតចោលហើយ មានសំឡេង គម្រាមថា ហុំ ហុំ លះចោលហើយ មានទឹកអម្ចត់ គឺរាគាទិក្កិលេសលះ ចោលហើយមានចិត្តសង្រួមហើយ ចេះចប់នូវវេទ (គឺមគ្គញ្ញាណទាំង ៤) មានមគ្គព្រហ្មចរិយៈ នៅរួចហើយ ម្យ៉ាងទៀត ព្រាហ្មណ៍ណាមិនមានគំនរ គឺរាគាទិក្កិលេសក្នុងអារម្មណ៍បន្តិចបន្តួចក្នុងលោកសន្និវាស ព្រាហ្មណ៍នោះ គួរនឹងហៅខ្លួនថា ជាព្រាហ្មណ៍ដោយធម៌បាន។

## សប្ដាហ៍ទី ៦ បន្ទាប់ពីត្រាស់ដឹង

លុះ ៧ ថ្ងៃកន្លងហើយ ព្រះដ៏មានព្រះភាគទ្រង់ក្រោកពីម្លប់អជបាលនិគ្រោធព្រឹក្ស យាងចូលទៅកាន់ដើមរាំងអន្លក់ លុះចូលទៅដល់ហើយទ្រង់គង់ដោយព្រះភ្នែនតែមួយអស់ ៧ ថ្ងៃក្រោមម្លប់រាំងអន្លក់ សោយវិមុត្តិសុខ(គឺសុខក្នុងផលសមាបត្តិ)។

សម័យនោះឯង មហាមេឃពុំជួនកាល ក៏បណ្ដាលឡើងជាភ្លៀង មានភ្លៀងរលឹមអស់ ៧ ថ្ងៃ បណ្ដាលឱ្យអាប់ពន្លឺព្រះអាទិត្យដោយអំណាច ខ្យល់ត្រជាក់។ គ្រានោះ មុចលិន្ទនាគរាជចេញអំពីលំនៅរបស់ខ្លួនហើយ ពេនព័ន្ធព្រះកាយព្រះមានព្រះភាគ ៧ ជុំដោយភ្នែន(របស់ខ្លួន) ហើយលើកពពារដ៏ធំបាំងពីខាងលើព្រះសីសៈព្រះដ៏មានព្រះភាគ ហើយឋិតនៅដោយគិតថា រងាកុំគប្បីតបៀតបៀនព្រះដ៏មានព្រះភាគ ក្ដៅកុំគប្បី បៀតបៀន

ព្រះដ៏មានព្រះភាគ សម្ងស្សរបោមមូសខ្យល់កម្តៅថ្ងៃពស់ តូចពស់ធំ ក៏គប្បី បៀតបៀនព្រះដ៏មានព្រះភាគ។ លុះថ្ងៃ ៧ កន្លងទៅ ហើយ លំដាប់នោះ មុច្ចលិន្ទនាគរាជដឹងថា ភ្លៀងរាំងហើយ មេឃស្រឡះ ហើយ ក៏រំសាយភ្នែន ចេញចាកព្រះដ៏មានព្រះភាគ ហើយប្រែភេទរបស់ខ្លួននិម្មិត ជាភេទមាណព ឈរប្រណម្យអញ្ជលីនមស្ការព្រះមានព្រះភាគ ទ្រង់ជ្រាប សេចក្តីនោះ ហើយ ក៏បន្លឺនូវឧទានគាថាក្នុងវេលានោះថា:

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ**
**អព្យាបជ្ជំ សុខំ លោកេ បាណភូតេសុ សញ្ញមោ ។**
**សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ**
**អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ ។**

សេចក្តីស្ងាត់ចាកកិលេស របស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គ-ញាណ) មានធម៌ប្រាកដហើយ បានឃើញធម៌ (ដោយញាណចក្ខុ) ជាគុណឱ្យកើតសេចក្តីសុខ សេចក្តីមិនព្យាបាទនិងសេចក្តីសង្រួម មិនបៀតបៀនសត្វទាំងឡាយ ក៏ជាគុណឱ្យកើតសេក្តីសុខក្នុងលោក សេចក្តីណាយចាករាគៈ និងការប្រព្រឹត្តកន្លងកាមទាំងឡាយ ជាគុណឱ្យកើតសេចក្តីសុខ ក្នុងលោក កិរិយាកម្ចាត់បង់នូវអស្មិមានះ កិរិយាកម្ចាត់បង់នូវអស្មិមានះនុ៎ះ ជាសុខយ៉ាងក្រៃលែង។

### សប្តាហ៍ទី ៧ បន្ទាប់ពីត្រាស់ដឹង

លុះ ៧ ថ្ងៃកន្លងទៅហើយ ព្រះដ៏មានជោគទ្រង់ក្រោកចេញចាក សមាធិនោះហើយ យាងចេញពីម្លប់ដើមរាំងអន្លក់ ហើយយាងចូលទៅកាន់ដើមរាជាយតនៈគឺដើមកេះ។ លុះចូលទៅដល់ហើយទ្រង់គង់ដោយ ព្រះ

ភ្នែនតែមួយអស់ ៧ ថ្ងៃក្រោមម្លប់ដើររាជាយតនៈ ទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងសមាបត្តិ) ។

សម័យនោះឯង មានពាណិជពីរនាក់ (ជាបងប្អូនបង្កើត) ឈ្មោះ តបុស្សៈ ១ ភល្លិកៈ ១ ជាអ្នកដើរផ្លូវឆ្ងាយ ចេញអំពីឧក្កលជនបទ សំដៅ ទៅកាន់ប្រទេសនោះ។ គ្រានោះ មានទេវតាជាញាតិសាលោហិតរបស់ តបុស្សៈ និងភល្លិកៈ ជាពាណិជបាននិយាយពាក្យនេះ នឹងតបុស្សៈ ភល្លិកៈពាណិជថា ម្នាលគ្នាយើង ព្រះដ៏មានព្រះភាគអង្គនេះ ទើបនឹងបានត្រាស់ជាដំបូង ឥឡូវព្រះអង្គគង់នៅក្រោមម្លប់រាជាយតនៈ(ឯណោះ)អ្នកទាំងឡាយគួរទៅ បូជាព្រះដ៏មានព្រះភាគអង្គនោះដោយសដូវផង់ នឹងសដូវដុំ ចុះការបូជានោះ នឹងបានជាប្រយោជន៍ នឹងសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលយូរអង្វែង។ គ្រានោះ តបុស្សៈ និងភល្លិកៈពាណិជ ក៏នាំយកនូវសដូវផង់ និងសដូវដុំចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងកន្លែងដ៏សមគួរ។ លុះ តបុស្សៈ និងភល្លិកៈពាណិជឋិតនៅក្នុងកន្លែងដ៏សមគួរហើយ ទើបពោលពាក្យនេះ និងព្រះដ៏មានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទទួលនូវសដូវផង់ និងសដូវដុំរបស់យើងខ្ញុំ ព្រោះថាការទទួល នឹងបានជាប្រយោជន៍ និងសេចក្តីសុខដល់យើងខ្ញុំទាំងឡាយអស់កាល យូរអង្វែង។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះថា ធម្មតាព្រះតថាគតទាំងឡាយ មិនដែលទទួល(អាមិសៈ)ផ្ទាល់នឹងដៃឡើយ បើដូច្នោះតើតថាគតគួរទទួលនូវសដូវផង់ និងសដូវដុំដោយវត្ថុអ្វីហ្ន៎។ គ្រានោះ មហារាជទាំង ៤ ទ្រង់ជ្រាបព្រះតម្រិះរបស់ព្រះដ៏មានព្រះភាគ (ដោយចិត្ត របស់ខ្លួន) ទើបនាំនូវបាត្រថ្មកែវទាំងឡាយ ៤ អំពីទិសទាំង ៤ បង្អោនចូល មក

ថ្វាយព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន សូម ព្រះដ៏មានព្រះភាគទទួលនូវសដូវផង់ និងសដូវដុំដោយបាត្រនេះចុះ។

ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលនូវសដូផង និងសដូវដុំដោយបាត្រថ្មកែវទាំងឡាយ ដ៏មានតម្លៃច្រើន លុះទទួលនូវសដូវផង និងសដូវដុំដោយបាត្រថ្មកែវទាំងឡាយ ដ៏មានតម្លៃច្រើន លុះទទួលស្រេចហើយក៏ទ្រង់សោយ(ក្នុងពេលនោះ)។ គ្រានោះឯង តបុស្សៈ និងភល្លិកៈពាណិជបាននិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយនេះសូមដល់នូវព្រះដ៏មានព្រះភាគ និងព្រះធម៌ជាទីរឭក សូមព្រះអង្គទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថា ជាឧបាសកបានដល់នូវព្រះ ពុទ្ធ និងព្រះធម៌ជាទីរឭកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមតរៀងទៅ។ ក៏ឯពាណិជទាំងឡាយនោះបាននាម បញ្ញត្តិថា ទ្វេវាចិកឧបាសក ជាដំបូងក្នុងលោក ។

## សហម្បតីព្រហ្ម អារាធនាព្រះពុទ្ធសម្តែងធម៌

លុះ ៧ កន្លងទៅហើយ ព្រះមានជោគទ្រង់ក្រោកចាកសមាធិនោះហើយយាងចេញអំពីក្រោមម្លប់រាជាយតនៈ ហើយយាងចូលទៅកាន់ដើម អជបាលនិគ្រោធវិញ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់សម្ងំក្នុងទី ស្ងាត់តែមួយព្រះអង្គទើបទ្រង់ព្រះតម្រិះយ៉ាងនេះថា ក៏ធម៌ដែលតថាគត បានត្រាស់ដឹងហើយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌គឺសត្វឃើញបាន ដោយកម្រ ជាធម៌គឺសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌រម្ងាប់ទុក្ខជាធម៌ ដ៏ល្អិតជាធម៌លុះតែអ្នកប្រាជ្ញទើបត្រាស់ដឹងបាន ក៏ឯពពួកសត្វនេះ សុទ្ធ តែកំពុងរីករាយក្នុងសេចក្តីអាល័យ កំពុងត្រេកត្រអាលក្នុងសេចក្តីអាល័យ កំពុងស្រើបស្រាលក្នុងសេចក្តីអាល័យ (ចំពោះកាមទាំងឡាយ) ក៏បដិច្ច-សមុ

ប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានិងគ្នាណា បដិច្ចសមុប្បាទធម៌នោះជា ហេតុនាំពពួកសត្វនៅរីករាយក្នុងសេចក្ដីអាល័យ នៅស្រើបស្រាលក្នុង សេចក្ដីអាល័យ ឃើញបានដោយកម្រ ម្យ៉ាងទៀតធម៌ណាសម្រាប់រម្ងាប់ បង់នូវសង្ខារទាំងពួង សម្រាប់លះចោលនូវឧបធិគឺខន្ធនិងកិលេសទាំង អស់ជាទីអស់ទៅនៃតណ្ហា ជាទីណាយចាករាគៈ ជាទីរលត់នៃទុក្ខ គឺនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុដែលពពួកសត្វឃើញបានដោយកម្រក្រៃពេក បើទុកជាតថាគតសម្ដែងធម៌ទៅក៏គង់សត្វទាំងឡាយដទៃ មិនអាចនឹង ត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ ព្រោះហេតុនោះ សេចក្ដីលំបាក សេចក្ដីនឿយព្រួយមុខជានឹងមានដល់តថាគតមិនខាន។ ម្យ៉ាងទៀត ព្រះគាថាទាំងឡាយជាហេតុអស្ចារ្យសមគួរនេះ ព្រះដ៏មានព្រះភាគមិនបាន ឮក្នុងកាលមុនឡើយ ក៏កើតប្រាកដដល់ព្រះអង្គថាៈ

**កិច្ឆេន មេ អធិគតំ ហលន្ទានិ បកាសិតុំ។**
**រាគទោសបរេតេហិ នាយំ ធម្មោ សុសម្ពុធោ។**
**បដិសោតគាមី និបុណំ គម្ភីរំ ទុទ្ទសំ អណុំ**
**រាគរត្តា ន ទក្ខន្តិ តមោក្ខន្ធេន អាវុដា។**

ឥឡូវនេះ តថាគតគួរសម្ដែងនូវធម៌ ដែលតថាគតបានត្រាស់ដឹងហើយដោយកម្រ (ន៎ុះទៅចុះ)។ ប៉ុន្តែសត្វទាំងឡាយ ដែលរាគៈ ទោសៈគ្របសង្កត់ ក៏មិនអាចនឹងត្រាស់ដឹងនូវធម៌នេះបានដោយងាយទេ។ សត្វទាំងឡាយ ដែលកំពុងត្រេកអរដោយរាគៈ ដែលគំនរងងឹត (គឺអវិជ្ជា) កំពុងបិទបាំង(យ៉ាងនេះ) មុខជានឹងមិនឃើញនូវធម៌ ដែលនាំសត្វឱ្យដល់ នូវព្រះនិព្វាន ជាធម៌ល្អិតឆ្មារជ្រាលជ្រៅ សត្វឃើញបានដោយកម្រ (ន៎ុះទេ)។

កាលដែលព្រះដ៏មានព្រះភាគពិចារណាឃើញ ដោយន័យថា ត្រិះរិះដូច្នេះហើយ ព្រះហឫទ័យដ៏ឱនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសម្តែងធម៌ឡើយ។

លំដាប់នោះ សហម្បតីព្រហ្ម ដែលធ្លាប់បួសជាព្រះភិក្ខុ នាមសហកៈ ក្នុងសាសនាព្រះពុទ្ធកស្សបទសពល បានសម្រេចនូវបឋមជ្ឈាន បដិសន្ធិក្នុងព្រហ្មលោក ជាន់បឋមជ្ឈានភូមិ ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះ ហឫទ័យរបស់ព្រះដ៏មានព្រះភាគដោយចិត្តរបស់ខ្លួនហើយ ទើបរំពឹងត្រិះ រិះដូច្នេះថា អើហ្ន៎! ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធមានព្រះហឫទ័យឱន ទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសម្តែងធម៌ (យ៉ាងនេះ) ឱ!សត្វលោកវិនាសតើហ្ន៎។

គ្រានោះ សហម្បតីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ (ដោយឆាប់ភ្លាម) ប្រៀបដូចបុរសអ្នកមានកម្លាំងលាចេញនូវដើមដៃ ដែលខ្លួនបត់ចូល ឬបត់ចូលនូវដើមដៃដែលខ្លួនលាចេញ។

លំដាប់នោះ សហម្បតីព្រហ្មធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ហើយលុតចុះនូវមណ្ឌលជង្គង់ខាងស្តាំលើផែនដី ផ្គុំម្រាមទាំង ១០ ប្រណម្យ អញ្ជលី ថ្វាយបង្គំចំពោះត្រង់ព្រះដ៏មានព្រះភាគ ទើបពោលពាក្យនេះនឹង ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្តែងធម៌ សូមព្រះសុគតសម្តែងធម៌ (ដ្បិត) សត្វទាំងឡាយ ដែលមាន ធូលី គឺរាគាទិក្កិលេសដ៏ស្រាលស្តើងក្នុងភ្នែក គឺបញ្ញា តែខានស្តាប់ធម៌ក៏ មុខជា នឹងសាបសូន្យមិនខាន សត្វទាំងឡាយអ្នកបម្រុងនឹងត្រាស់ដឹងនូវ ធម៌ក៏គង់មានដែរ។ សហម្បតីព្រហ្មបានពោលពាក្យនេះ(ប៉ុណ្ណោះ) លុះ ពោលពាក្យនេះហើយ ក៏ពោលពាក្យដទៃទៀតថាៈ

**បាតុរហោសិ មគធេសុ បុព្វេ**
**ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ។**
**អបាបុរេតំ អមតស្ស ទ្វារំ**
**សុណន្តុ ធម្មំ វិសមលេនានុពុទ្ធំ។**

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយអ្នកប្រកបដោយមន្ទិលតែងគិតជាធម៌មិនបរិសុទ្ធទេ កើតប្រាកដហើយក្នុងដែនមគធៈ។ សូមព្រះអង្គបើកនូវទ្វារនៃព្រះនិព្វាននុ៎ះ សត្វទាំងឡាយប្រុងចាំស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិល ទ្រង់ត្រាស់ដឹងតាម(លំអានព្រះពុទ្ធអំពីបូរាណ)។

**សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ**
**យថាបិ បស្សេ ជនតំ សមន្តតោ**
**តថូបមំ ធម្មមយំ សុមេធ**
**បាសាទមារុយ្ហ សមន្តចក្ខុ**
**សោកាវតិណ្ណំ ជនតំ អបេតសោកោ**
**អវេក្ខស្សុ ជាតិជរាភិភូតំ ។**

ប្រៀបដូចជាបុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំដ៏ហើយដោយ ថ្មសុទ្ធ ក្រឡេកមើលឃើញប្រជុំជនដោយជុំវិញ យ៉ាងណាមិញបពិត្រព្រះអង្គមានបញ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គជាអ្នកមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទដ៏ហើយដោយធម៌ ពិចារណាមើលនូវប្រជុំជនអ្នកច្រឡំដោយសេចក្តីសោក ដែលជាតិជរាកំពុងគ្របសង្កត់មានឧបមាដូច្នោះដែរ។

**ឧដ្ឋេហិ វីរ វិជិតសង្គាម**
**សត្ថវាហ អនណ វិចរ លោកេ។**

**ទេសស្សុ ភគវា ធម្មំ**
**អញ្ញាតារោ ភវិស្សន្តិ។**

បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាម ហើយជានាយកនៃពួកសត្វ អ្នកមិនជាប់ជំពាក់បំណុលគឺកាម សូមព្រះអង្គក្រោកឡើង សូមទ្រង់ស្តេចទៅក្នុងលោក។ សូមព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ សត្វទាំងឡាយអ្នកបម្រុងនឹងត្រាស់ដឹងនូវធម៌ក៏គង់មានដែរ។

**ទេសេតុ សុគតោ ធម្មំ ទេសេតុ អមតំ អបទំ**
**លោកានមនុកម្បាយ ធម្មំ ទេសេតុ នាយក ។**

សូមព្រះសុគតសម្តែងធម៌ សូមសម្តែងព្រះនិព្វានឈ្មោះអមតៈ បពិត្រព្រះនាយក សូមព្រះមានព្រះភាគសម្តែងធម៌ ដើម្បីអនុគ្រោះដល់ សត្វលោកទាំងឡាយ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្តីអារាធនារបស់សហម្បតីព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណា ចំពោះសត្វទាំងឡាយផង ទើបទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ។

ព្រះដ៏មានព្រះភាគ កាលទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយមានធូលី គឺរាគាទិក្កិលេសច្រើនក្នុងភ្នែកខ្លះ មានឥន្ទ្រិយរឹងខ្លះ មានឥន្ទ្រិយទន់ខ្លះមានអាការៈល្អខ្លះ មានអាការៈអាក្រក់ខ្លះ ជាសត្វដែលព្រះអង្គគួរឱ្យត្រាស់ដឹងបានដោយងាយខ្លះ ឱ្យត្រាស់ដឹងដោយកម្រខ្លះ ជាអ្នកឃើញបរលោកនឹងទោសដោយសភាពគួរខ្លាចខ្លះ។

សេចក្តីប្រៀបថា មានផ្កាជលជាតិពួកខ្លះគឺផ្កាព្រលឹតក្តីផ្កា ឈូកសក្តី ក្នុងគុម្ពនៃព្រលឹតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅក្នុងទឹក

នៅឡើយ មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលឹតក្តី ផ្កាឈូក្រហមក្តី ផ្កាឈូក សក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាជលជាតិពួកខ្លះគឺផ្កាព្រលឹតក្តី ផ្កាឈូកក្តី ក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ដុះខ្ពស់ឡើងជាងទឹក មិនជាប់ជំពាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ព្រះដ៏មានព្រះភាគកាលទ្រង់រមិលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយមានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកខ្លះ មានធូលីគឺរាគាក្កិលេសច្រើនក្នុងភ្នែកខ្លះ មានឥន្ទ្រិយរឹងខ្លះ មានឥន្ទ្រិយទន់ខ្លះ មានអាការល្អខ្លះ មានអាការមិនល្អខ្លះជាសត្វដែលព្រះអង្គគួរឱ្យត្រាស់ដឹងបានដោយងាយខ្លះ ឱ្យត្រាស់ដឹងបានដោយកម្រខ្លះ សត្វជំពូកខ្លះឃើញបរលោកនិងទោសដោយសភាព គួរខ្លាច មានឧបមេយ្យដូច្នោះឯង។ លុះទ្រង់ឃើញហើយ ទើបទ្រង់សម្តែង ជាបទគាថានឹងសហម្បតីព្រហ្មថាៈ

**អបារុតា តេ អមតស្ស ទ្វារា យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ**
**វិហឹសសញ្ញី បគុណំ នភាសឹ ធម្មំ បណីតំ មនុជេសុ ព្រហ្មេ។**

ទ្វារនៃព្រះនិព្វានទាំងនោះ បើកហើយ សត្វទាំងឡាយណាមានសោតប្បសាទសត្វទាំងឡាយនោះ ចូរបញ្ចេញនូវសទ្ធាចុះ។

ម្នាលមហាព្រហ្ម តថាគតមានសេចក្តីសម្គាល់ក្នុងការលំបាក បានជាមិនសម្តែងធម៌ដ៏ឧត្តម ដែលស្ទាត់ក្នុងសំណាក់មនុស្សទាំងឡាយ។

គ្រានោះ សហម្បតីព្រហ្មគិតថា ខ្លួនអញជាបុគ្គល គឺព្រះដ៏មានព្រះភាគទ្រង់យល់ព្រមដើម្បីនឹងសម្តែងធម៌ហើយ លុះគិតដូច្នេះហើយ ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយក៏បាត់អំពីទីនោះមួយ រំពេចទៅ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថាតថាគតគួរ សម្តែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណាអាចត្រាស់ដឹងធម៌នេះឆាប់រហ័សបាន។លំដាប់នោះ ព្រះដ៏មានភាគទ្រង់ត្រិះរិះយ៉ាងនេះទៀតថា អាឡារតាបសកាលាមគោត្រនេះជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាសវាងវៃជាអ្នកមានបញ្ញា មានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកយូរមកហើយ បើដូច្នោះ គួរតថាគតសម្តែងធម៌ដល់អាឡារតាបសកាលាមគោត្រជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន។

គ្រានោះមានទេវតាអង្គមួយ មានរូបមិនប្រាកដ ក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន អាឡារតាបសកាលាមគោត្រធ្វើកាលកិរិយាស្លាប់ទៅ ៧ ថ្ងៃហើយ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ជ្រាបថា អាឡារតាបសកាលាមគោត្រធ្វើកាលកិរិយាស្លាប់ទៅ ៧ ថ្ងៃ ហើយ។ គ្រានោះព្រះដ៏ព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា អាឡារតាបស កាលាមគោត្រនុ៎ះមានសេចក្តីសាបសូន្យធំ ប្រសិនបើតាបសនោះបាន ស្តាប់ធម៌នេះក៏គប្បីត្រាស់ដឹងធម៌បានមួយរំពេច។ គ្រានោះ ព្រះដ៏មានព្រះ ភាគទ្រង់ព្រះតម្រិះដូច្នេះថា តថាគតសម្តែងធម៌ដល់អ្នកណាជាមុនអេះ អ្នកណានឹងត្រាស់ដឹងធម៌នេះ ឆាប់រហ័សបាន។ ព្រះដ៏មានព្រះភាគក៏ទ្រង់ ព្រះតម្រិះក្នុងលំដាប់នោះទៀតថាឧទកតាបសរាមបុត្រនេះឯងជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាសវាងវៃ . ជាអ្នកមានបញ្ញា មានធូលីគឺរាគាទិក្កិលេសតិច ក្នុងភ្នែកយូរណាស់មកហើយ បើដូច្នោះ គួរតថាគតសម្តែងធម៌ដល់ ឧទក តាបសរាមបុត្រនេះជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌ នេះឆាប់រហ័ស បាន។ គ្រានោះមានទេវតាអង្គមួយ មានរូបមិនប្រាកដក្រាបទូលព្រះដ៏មាន ព្រះ

ភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ឧទកតាបសរាមបុត្រធ្វើកាលកិរិយាស្លាប់អំពីពេលព្រលប់ទៅហើយ។

គ្រានោះព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា ឧទកតាបសរាមបុត្រមានសេចក្តីសាបសូន្យធំ ប្រសិនបើតាបសនោះ បានស្តាប់ធម៌នេះគប្បីត្រាស់ដឹងធម៌បានមួយរំពេច។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា តថាគតគួរសម្តែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន។ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះដូច្នេះ ក្នុងលំដាប់នោះថា បញ្ចវគ្គិយភិក្ខុទាំងឡាយ មានឧបការៈច្រើន ដល់តថាគត ព្រោះថាបើតថាគតកាលដែលកំពុងបញ្ជូនចិត្តទៅក្នុង ព្យាយាម បើដូច្នោះគួរតថាគត សម្តែងដល់បញ្ចវគ្គិយភិក្ខុទាំងឡាយជាមុន ចុះ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះដូច្នេះថា ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងឡាយនៅឯណា។លុះព្រះដ៏មានព្រះភាគ ទ្រង់ឃើញ បញ្ចវគ្គិភិក្ខុទាំងឡាយ នៅក្នុងឥសិបនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធស្អាតកន្លងលើសចក្ខុរបស់មនុស្ស។

គ្រានោះព្រះដ៏មានព្រះភាគគង់នៅក្នុងឧរុវេលាប្រទេស តាមសមគួរដល់ព្រះអធ្យាស្រ័យ ទើបទ្រង់យាងទៅកាន់ចារិកសំដៅទៅរកក្រុង ពារាណសី។

មានអាជីវកម្នាក់ ឈ្មោះឧបកៈ បានឃើញព្រះដ៏មានព្រះភាគស្តេចទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃគយាប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង លុះឃើញហើយក៏ពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នកជ្រះថ្លាណាស់ ឆវិវណ្ណ របស់អ្នកក៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្ត

នឹងធម៌របស់គ្រូណា។ កាលឧបកាជីវកសួរយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគទ្រង់ឆ្លើយតបដោយពាក្យជាគាថា ទៅរកឧបកាជីវកថា

**សព្វាភិភូ សព្វវិទូហមស្មិ**
**សព្វេសុ ធម្មេសុ អនូបលិត្តោ**
**សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ**
**សយំអភិញ្ញាយ កមុទ្ទិសេយ្យំ។**

តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវ ចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់ បានលះចោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯង (ចាំបាច់) ចំពោះបុគ្គលណា។

**ន មេ អាចរិយោ អត្ថិ សទិសោ មេ ន វិជ្ជតិ**
**សទេវកស្មឹ លោកស្មឹ នត្ថិ មេ បដិបុគ្គលោ ។**

តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹងតថាគតឡើយក្នុងលោកនេះព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ។

**អហញ្ហិ អរហា លោកេ អហំ សត្ថា អនុត្តរោ**
**ឯកោម្ហិ សម្មាសម្ពុទ្ធោ សីតិភូតោស្មិ និព្វុតោ ។**

ព្រោះថា តថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់បំផុត ជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះខ្លួនឯង តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរត់ហើយ។

**ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសិនំ បុរំ**

**ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសិនំ បុរំ**
**អន្ធីភូតស្មឹ លោកស្មឹ អាហញ្ញឹ អមតទុន្ទុភិ ។**

ឥឡូវតថាគតទៅកាន់ក្រុងនៃពួកជនអ្នកកាសី ដើម្បីសម្ដែងធម្មចក្ក (ដោយបំណងថា) តថាគតនឹងទូងនូវស្គរ គឺអមតនិញ្វន ចំពោះសត្វលោក ដែលលងងឹត គឺអវិជ្ជាកំពុងគ្របសង្កត់។

ឧបកាជីវកក៏តបថា ម្នាលអាវុសោ អ្នកប្ដេជ្ញាខ្លួនអ្នកថាយ៉ាងណាអ្នក (គួរដើម្បីបាននូវឈ្មោះ) ថា អនន្តជិនៈ(យ៉ាងនោះឯង)។ ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះពុទ្ធដីកាទៀតថាៈ

**មាទិសា វេ ជិនា ហោន្តិ យេ បត្តា អាសវក្ខយំ**
**ជិតា មេ បាបកា ធម្មា តស្មាហមុបក ជិនោតិ។**

ជនទាំងឡាយណា បានដល់នូវធម៌ សម្រាប់ធ្វើអាសវៈ ឱ្យអស់ទៅ ជនទាំងឡាយនោះឈ្មោះថា ជិនៈ (ជាអ្នកឈ្នះកិលេស) ប្រាកដដូចជាតថាគតដែរ។ តថាគតបានឈ្នះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគតបាននូវឈ្មោះថា ជិនៈ(ជាអ្នកឈ្នះបាបធម៌)។

កាលព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ឧបកាជីវកពោលពាក្យថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹង ពិតមែនហើយ(ថាហើយ) ក៏ងក់ក្បាលហើយកាន់ក្បាលហើយកាន់យកផ្លូវខុស (គឺដើរបែកផ្លូវគ្នា)ជៀសចេញទៅ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ហើយក៏យាងចូលទៅក្រុងពារាណសី រួចហើយទ្រង់យាងទៅឯឥសិបតនមិគទាយវន សំដៅទៅរកកន្លងដែលបញ្ចវគ្គិយភិក្ខុនៅ។ បញ្ចវគ្គិយភិក្ខុបានឃើញព្រះដ៏មានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយក៏ធ្វើប្ដេជ្ញាគ្នាថា ម្នាលអាវុសោ សមណគោតមនេះជាអ្នកប្រតិបត្តិដើម្បីល្មោភឃ្លាត

ចាកព្យាយាមហើយ វិលត្រឡប់ដើម្បីភាវៈល្មោភឥឡូវនេះលោកនិមន្តមក យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលយកបាត្រចីវររបស់លោកឡើយ ប៉ុន្តែយើងត្រូវក្រាសអាសនៈ បម្រុងទុក បើលោនឹងចង់គង់ក៏គងចុះ។ ព្រះដ៏មានព្រះភាគយាងចូលទៅរកបញ្ចវគ្គិយភិក្ខុដោយប្រការណាៗ បញ្ចវគ្គិយភិក្ខុទាំងនោះក៏មិនអាចដើម្បីឋិតនៅក្នុងពាក្យប្តេជ្ញារបស់ខ្លួន ដោយប្រការនោះៗ បានឡើយ ក៏ស្រាប់តែក្រោកទទួលព្រះដ៏មានព្រះភាគ ខ្លះទទួលយកបាត្រចីវររបស់ព្រះអង្គ ខ្លះក្រាលអាសនៈថ្វាយ ខ្លះតម្កល់ទឹកលាងព្រះបាទ យកតាំងសម្រាប់រងព្រះបាទ និងឈ្នាន់រងព្រះបាទមកថ្វាយ។

ព្រះដ៏មានព្រះភាគគង់លើអាសនៈ ដែលបញ្ចវគ្គិយភិក្ខុទាំងឡាយរៀបចំទុកហើយ។ លុះព្រះដ៏មានព្រះភាគគង់ហើយក៏ទ្រង់លាងព្រះបាទទាំងពីរ ទើបបញ្ចវគ្គិយភិក្ខុហៅព្រះដ៏មានព្រះភាគដោយចំព្រះនាមផង ដោយពាក្យថា អាវុសោផង។ កាលបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យហៅយ៉ាងនេះហើយ ព្រះភគវន្តមុនីទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះ នឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នា កុំហៅតថាគតដោយចំឈ្មោះ និងពាក្យថាអាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ ឥឡូវតថាគតនឹងប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះហើយ បួសក្នុងភាពនៃបុគ្គលគ្មានការងារជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិតាមពាក្យប្រដៅរបស់ថាគតហើយ ពុំយូរ

ឡើយមុខជានឹងបានធ្វើឱ្យជាក់ច្បាស់ ដោយបញ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹង សម្រេចសម្រាន្ត នៅដោយឥរិយាបថទាំង ៤។

កាលព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ បញ្ចវគ្គិយភិក្ខុក៏ពោលពាក្យនេះ នឹងព្រះដ៏មានភាគថា បពិត្រព្រះគោតមដ៏មានអាយុព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម្ម ជាធម៌វិសេសដោយញាណ និងទស្សនៈដ៏ឧត្តមអាចកម្ចាត់បង់នូវកិលេសដោយការប្រព្រឹត្តនោះផង ដោយការប្រតិបត្តិនោះផង ដោយអំពើដែលអ្នកដទៃធ្វើតាមបានដោយកម្រផង ឥឡូវនេះព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីល្មោភច្រើនហើយ ក៏នឹងបានត្រាស់ដឹងឧត្តរិសមនុស្សធម្ម ដ៏វិសេសដោយញាណ និងទស្សនៈដ៏ឧត្តមអាចកម្ចាត់បង់នូវលេសដូចម្តេចបាន។ លុះបញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យយ៉ាងនេះហើយ ទើបព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលយ៉ាងនេះនឹងបញ្ចវគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិដើម្បីល្មោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់ដើម្បីល្មោភច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយតថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្ប-សាទចុះ តថាគតនឹង ប្រៀនប្រដៅនូវព្រះនិព្វាន ដែលតថាគតបានត្រាស់ ដឹងហើយ ឥឡូវ តថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយចេញចាក ផ្ទះហើយបួសក្នុង ភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះ ដោយប្រពៃ ដើម្បីជាប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយកាលបើ បានប្រតិបត្តិគួរដល់ពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយមុខជានឹង បាន

ធ្វើឱ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌ នោះជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅដោតរិយាបថ ទាំង ៤។

បញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគជាគម្រប់ពីរដងផង។បេ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះ នឹងបញ្ចគ្គិយភិក្ខុកទាំងឡាយពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគជាគម្រប់ពីរដងទៀតថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម្ម ជាធម៌វិសេសដោយញាណ និងទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់នូវកិលេសដោយការប្រព្រឹត្តនោះផង ដោយសេចក្តីប្រតិបត្តិ នោះផង ដោយអំពើដែលជនដទៃធ្វើតាមបានដោយកម្រនោះផង ឥឡូវ នេះព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើន ឃ្លាតចាកព្យាយាមហើយវិល ត្រឡប់ដើម្បីល្មោភច្រើន នឹងបានត្រាស់ដឹងឧត្តមអាចកម្ចាត់បង់នូវកិលេស ដូចម្តេចបាន។

កាលបើបញ្ចគ្គិយភិក្ខុទាំងឡាយ ពោលពាក្យយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះ នឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរពិចារណាមើលនូវពាក្យរបស់តថាគតឥឡូវនេះ ដូចគ្នានឹងកាលមុនអំពីកាលឥឡូវនេះដែរឬទេ។

បញ្ចវគ្គិយភិក្ខុទាំងឡាយតបថា បពិត្រព្រះអង្គដ៏ចម្រើនពាក្យហ្នឹងព្រះអង្គមិនដែលពោលទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយតថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ តថាគតនឹងប្រៀនប្រដៅព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយ

ចេញចាកផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយ ប្រតិបត្តិគួរតាមពាក្យប្រដៅរបស់តថាគត ពុំយូរទ្បើយមុខជានឹងបានធ្វើឱ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

ព្រះដ៏មានព្រះភាគបានអាចញ៉ាំងបញ្ចវគ្គិយភិក្ខុទាំងឡាយ ឱ្យយល់ច្បាស់ច្បាស់ក្នុងពេលនោះ។ លុះគ្រាជាខាងក្រោយ បញ្ចវគ្គិយទាំងឡាយតាំងចិត្តស្តាប់ព្រះដ៏មានព្រះភាគ ផ្ទៀងនូវសោតប្បសាទហើយ ផ្ទង់ចិត្តដើម្បីដឹងច្បាស់។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុទាំងឡាយមកហើយត្រាស់ថា:..............................................(មានពិស្តារនៅក្នុងវិនយបិដក មហាវគ្គ បឋមភាគ បិដកលេខ ៦ ទំព័រ ២៨)។

## គុណនៃព្រះពុទ្ធទ្រង់សម្តែងធម៌

ព្រះពុទ្ធគ្រប់អង្គត្រាស់ដឹងក្នុងលោក មានជ័យមានជោគសែនប្រសើរក្រៃ
ពិតជាកម្រនៅក្នុងភពបី ក្រព្រះជិនស្រីសម្តែងទេសនា។

គ្រាត្រាស់ដំបូងនៅពុទ្ធគយា អង្គព្រះភគវាទ្រង់ព្រះសង្កា
គិតមិនសម្ដែងធម៌ដល់សត្វណា ក្ដៅដល់ទេវតាពួកព្រហ្មនានា។
ព្រហ្មចុះជួបព្រះសំពះទូលថា សូមព្រះសាស្ដាទ្រង់អារាធនា
សម្ដែងសច្ចៈគឺព្រះធម្មា ដល់សត្វនានាដែលមាននិស្ស័យ។
ព្រះពុទ្ធទទួលដោយតុណ្ហីភាព ទៅតាមសភាពនៃពុទ្ធវិស័យ
ធ្វើឱ្យសត្វលោកនៅក្នុងភពត្រៃ បានស្ដាប់ធម៌ថ្លៃរួចផុតទុក្ខា។
ដោយសារព្រះពុទ្ធទ្រង់បានត្រាស់ដឹង ទើបតឡូវហ្នឹងយើងបានសិក្សា
បរិស័ទម៉ឺនសែនមានចិត្តជ្រះថ្លា ខ្ពស់ទាបថ្នាក់ណាស្ដាប់បានគ្រប់គ្នា។
អន្លង់ទាំងបួនជ្រៅហួសការស្មាន សត្វឆ្លងទៅបានដោយសារសទ្ធា
ម្យ៉ាងមិនប្រមាទរាល់កិច្ចការងារ ព្យាយាមគ្រប់គ្រាព្រមដោយបញ្ញា។
ធម៌ព្រះអរហន្តត្រាស់ដឹងក្នុងលោក បុគ្គលចូលមកធ្វើការសិក្សា
ស្ដាប់ហើយត្រិះរិះគិតពិចារណា តែងបានប្រាជ្ញាព្រោះស្ដាប់ដោយល្អ។
យើងរៀនបិដកធម៌ព្រះសម្ពុទ្ធ ខ្ពង់ខ្ពស់បំផុតហៅសែនកម្រ
កំណើតជាមនុស្សបានដោយផលល្អ គួរសិក្សាធម៌ព្រះពុទ្ធសាសនា។
បុគ្គលណាល្ងង់លង់ក្នុងគំនិត កិលេសរួបរឹតគ្មានថ្ងៃភ្លឺថ្លា
ពេលស្ដាប់ធម៌ព្រះតែមួយគាថា កាត់វដ្ដសង្សារឃ្លាងពីអបាយ។
វិជ្ជាក្នុងលោកមានច្រើនអនេក តាមការបែងចែកពួកគ្រូទាំងឡាយ
មានមន្ដអាគមស្ដោះផ្លុំរូបកាយ ព្រះពុទ្ធទាំងឡាយត្រាស់ថាធម៌ថោក។
ធម៌ទាំងឡាយណារបស់អ្នកស្រុក សិក្សាគ្រប់មុខមិនផុតទុក្ខសោក

មិនមានប្រយោជន៍អ្នកប្រញាប់ក្រោក វិជ្ជានោះថោកត្រូវគិតរិះរេ។
នៅក្នុងលោកនេះមានជនពួកខ្លះ ខ្លួនយល់មិនច្បាស់ខំដឹកនាំគេ
ធម៌ព្រះមិនរៀនខ្ជិលដេកលើគ្រែ អាគមមន្តស្នេហ៍ខំរៀនឆ្លេឆ្លា។
ចំណែកមនុស្សខ្លះគេមាននិស្ស័យ គំនិតថ្លាថ្លៃរៀនត្រៃសិក្ខា
វិជ្ជាខ្ពង់ខ្ពស់នៅក្នុងលោកា សីលនិងបញ្ញាសមាធិថ្លៃ។
ឯជនពួកខ្លះសទ្ធាខ្ជាប់ខ្ជួន ប្រាជ្ញាមាំមួនក្នុងធម៌វិន័យ
ខិតខំចម្រើនភាវនារាល់ថ្ងៃ តាមព្រះជិនស្រីទ្រង់បង្ហាញផ្លូវ។
ធម៌ជាត្រៃលក្ខណ៍មានគ្រប់រូបា ទាំងមនុស្សទេវតាតែងតែត្រាច់ទៅ
សរីរៈនេះជាស្ថានដង្កូវ ក្លិនស្អុយអាស្រូវគួរឱ្យភ័យខ្លាច។
ក្នុងខ្លួនគ្មានខ្លឹមដៃជើងគ្មានន័យ ឆ្អឹងសាច់សរសៃក៏គ្មានអំណាច
ចុងក្រោយបែកធ្លាយពិតជាមិនអាច មច្ចុកំណាចពិតមកប្រហារ។
រូបកាយទាំងមូលផ្គុំឡើងយ៉ាងហ្នឹង គួរតែជញ្ជឹងសង្វេគចិន្តា
មិនគួរជាប់ស្អិតព្រោះគ្មានបានការ ឈាមក្រហមថ្លាក៏គ្មានតម្លៃ។
កាយសត្វគ្រប់រូបចាស់ទៅៗ ពិតជាគ្មានផ្លូវធ្វើការកែច្នៃ
ចុងក្រោយគង់ក្លាយទៅជាចំណី ភ្លើងខ្យល់ទឹកដីរូបធាតុទាំងឡាយ។
សង្ខារទាំងឡាយកើតហើយវិនាស បើរៀនធម៌ព្រះទើបខ្ពើមជិនណាយ
ខំធ្វើកុសលទើបសុខសប្បាយ កាយស្លាប់ខ្ចាត់ខ្ចាយតែបុណ្យរក្សា។
រីអស់ស្រីប្រុសអ្នកទាំងឡាយអើយ ព្រះធម៌មានហើយគួរតែសិក្សា
គឺសំណាងណាស់កើតទាន់សាសនា វិន័យធម៌មានអ្នកសម្តែង។

វិន័យព្រះសូត្រព្រះពុទ្ធផ្សំផ្គុំ ឯអភិធម្មភ្លឺល្អចិញ្ចែង
ពេលសិក្សាយល់ឃើញច្បាស់ខ្លួនឯង មិនបាច់ថ្លាថ្លែងរៀបរាប់សេចក្តី។
បើសិនមិនរៀនចម្រើនប្រាជ្ញា រស់រយវស្សាពិតជាគ្មានន័យ
អាយុត្រូវអស់គុណធម៌ត្រូវក្ស័យ គេរស់មួយថ្ងៃមានជ័យជម្នះ។
ឈ្មោះថាប្រសើរដោយសារប្រាជ្ញា ធ្លាប់បានសិក្សាអប់រំជម្រះ
យើងដឹងបរមត្ថដូចបានជួបព្រះ យើងលែងសំពះបួងសួងខាងក្រៅ។
គួររកទីពឹងលំនឹងក្នុងចិត្ត មិនគួរនែបនិត្យពឹងលើញាតិផៅ
អាងទ្រព្យសម្បត្តិពឹងលើកូនចៅ អ្នកប្រាជ្ញលោកហៅទីពឹងនោះខុស។
ជនជាសប្បុរសគេមិនស៊ុយស៊ុន គេខំធ្វើបុណ្យសីលទានចម្រុះ
គេទៅវត្តអារាមទាំងស្រីទាំងប្រុស គេខំដាំដុះសន្សំផលា។
ចំណែកជនពាលទានសីលមិនសាង អង្គុយក្អេងក្អាងអួតផឹកតែស្រា
មើលងាយគេឯងស្អប់អ្នកធម៌អាថ៌ ព្រះសង្ឃទេសនាពួកគេមិនស្តាប់។
បើរក្សាសីលថាសីលអំបី ឃើញក្បួនគម្ពីរពួកគេមិនចាប់
ថាលំបាកណាស់បាលីសារសព្ទ តោះយើងប្រញាប់ទៅផឹកឱ្យឆ្ងាយ។
ការពោលយ៉ាងនេះមិនមានចេតនា បៀតបៀនផ្លែផ្កាអស់លោករាល់កាយ
គឺចង់ឱ្យល្អគ្មានក្តីអន្តរាយ មិនបាច់បកស្រាយខ្ចីប៉ុណ្ណឹងចុះ។
បុណ្យទាំងប៉ុន្មានខ្ញុំបានធ្វើហើយ ខ្ញុំមិនកន្តើយសូមជូនស្រីប្រុស
ញាតិមិត្តបងប្អូនអស់លោកសប្បុរស ក្មេងចាស់ទាំងអស់សូមបានគ្រប់គ្នា។
ទោះនៅឆ្ងាយជិតមិនស្គាល់យ៉ាងណា សត្វក្នុងសង្សារមិនអាចគណនា

ពេលបានដឹងហើយសូមរួចចាកពៀរ ដោយសារសទ្ធាជឿលើកម្មផល។
បើសិនបានកើតទោះមនុស្សទេវតា ខ្ពស់ទាបថ្នាក់ណាសូមឱ្យបានដល់
សូមសុខសប្បាយកុំមានកង្វល់ មានតែតម្កល់ចិត្តក្នុងព្រះធម៌។

**ដោយសាមណេរ សា ចាន់រ៉ាត់**

## ៤.គុណរបស់ព្រះសម្មាសម្ពុទ្ធ

ព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ កាលប្រមូលសរុបមក មានត្រឹមតែ ៣ ប៉ុណ្ណោះ តែបើពោលដោយពិស្តារ មិនមានអ្នកណានឹងអាចរាប់បាន អាចប្រមាណបានឡើយ ព្រោះព្រះអង្គតាំងបណិធានប្រាថ្នានឹង

ជួយសត្វទាំងឡាយ ឱ្យផុតសង្សារទុក្ខដោយផ្ដើមតាំងព្រះទ័យថា: **ពុទ្ធោ ពោធេយ្យំ មុត្តោ មោចេយ្យំ តិណ្ណោ តារេយ្យំ** យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹងផង យើងរួចផុតហើយនឹងឱ្យអ្នកដទៃរួចផុតផង យើងឆ្លងហើយនឹងឱ្យអ្នកដទៃឆ្លងផង យ៉ាងនេះអស់រយៈពេល ៧ អសង្ខេយ្យ។ ប្រាថ្នាជាព្រះពុទ្ធដោយថ្លែងវាចាតាមចិត្តដែលគិតថា នឹងជួយសត្វ (ដូចខាងលើ) អស់ ៩ អសង្ខេយ្យ។ ទ្រង់ប្រាថ្នានឹងបំពេញបារមីដោយកាយ វាចា ចិត្ត តាំងពីបានទទួលការព្យាករណ៍ពីព្រះពុទ្ធទីបង្ករថា នឹងបានត្រាស់ជាព្រះពុទ្ធអស់រយៈពេល ៤ អសង្ខេយ្យ និង ១ សែនមហាកប្បទៀត។ ទ្រង់បំពេញបារមីរួមទាំងអស់ ២០ អសង្ខេយ្យ និង ១ សែនមហាកប្ប។

ព្រះសព្វញ្ញូពោធិសត្វរបស់យើងទាំងឡាយ ទ្រង់បានតាំងប្រាថ្នាជាព្រះពុទ្ធក្នុងខណៈចិត្តជាលើកដំបូង ដែលមិនទាន់បានធ្លាប់ជួបព្រះពុទ្ធអង្គណាៗឡើយ រាប់មិនអស់មានរឿងពោលទុកថា:

រាប់តាំងពីភទ្ទកប្បនេះ ថយក្រោយទៅ ២០ អសង្ខេយ្យ និង ១ សែនមហាកប្ប ព្រះពោធិសត្វកើតជាមនុស្សក្រីក្រនៅក្នុងដែនគន្ធារៈ កាប់ឧស បេះបន្លែអំពីព្រៃយកទៅលក់បានប្រាក់ចិញ្ចឹមមាតា។ ថ្ងៃមួយ កំពុងរែករបស់ធ្ងន់ដើរមកហាលក្ដៅផង ស្រេកទឹកផង ក៏ចូលសម្រាកនៅ ក្រោមដើមជ្រៃពិចារណាថា ពេលនេះអាត្មាអញនៅមានកម្លាំង អាចអត់ ធន់ចំពោះសេក្ដីទុក្ខព្រោះក្ដៅជាដើមបាន តែកាលយើងចាស់ ឬឈឺ ប្រាកដជាមិនអាចអត់ធន់ នឹងសេចក្ដីទុក្ខយ៉ាងនេះបានឡើយ ណ្ហើយ យើងនឹងទៅកាន់សុវណ្ណភូមិ ជីកយកមាសមក ចិញ្ចឹមមាតាឱ្យមានសេចក្ដី សុខចុះ។ កាលគិតដូច្នោះហើយ ក៏បាននាំមាតាចុះសំពៅទៅកាន់ សុវណ្ណភូមិ

ជាមួយនឹងពួកឈ្មួញ ដោយសូមបម្រើជាកូនឈ្មួញប្រចាំសំពៅ កាលសំពៅចេញទៅបាន ៧ ថ្ងៃ ក៏បែកលិចលង់ទៅ ពួកឈ្មួញក៏ដល់នូវ សេចក្តីវិនាសទាំងអស់គ្នា ចំណែកព្រះពោធិសត្វលីមាតាផង ហែលទឹកឆ្លង មហាសមុទ្រទៅ ផង។

គ្រានោះ ស្តេចមហាព្រហ្មជាន់សុទ្ធាវាស រំពឹងមើលសត្វលោកទូទៅ ដោយគិតថា កន្លងទៅ ១ អសង្ខេយ្យមហាកប្បហើយ មិនមានបុរសណាមួយ ដែលត្រាស់ជាព្រះពុទ្ធឡើយ ចុះអ្នកដែលនឹងបានត្រាស់ដឹងជាព្រះពុទ្ធមានឬទេហ្ន៎? ទើបមើលឃើញព្រះពោធិសត្វដែលកំពុងលះបង់ជីវិត នាំមាតារបស់ខ្លួនហែល ឆ្លងមហាសមុទ្រដ៏ធំល្វឹងល្វើយ ក៏ជ្រាបបានថា មហាបុរសនេះ មានសេចក្តីព្យាយាមខ្លាំងក្លាណាស់ នឹងមានអធ្យាស្រ័យ ជួយអ្នកទៃ ព្រះពោធិសត្វនោះដោយអានុភាពមហាព្រហ្មបណ្តាលចិត្ត ក៏កើតសេចក្តីគិតឡើងថា យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹង ផង យើងរួចផុតហើយនឹងឱ្យអ្នកដទៃឆ្លងផង ដូច្នេះហែលមហាសមុទ្រ ២-៣ ថ្ងៃ ក៏បានដល់ត្រើយព្រមនឹងមាតា។ តាំងពីនោះមក ព្រះពោធិសត្វ ចិញ្ចឹមមាតារហូតដល់អស់ជីវិត ហើយទៅកើតក្នុងទេវលោក ចំណែក មាតាក៏ទៅតាមយថាកម្ម នេះគឺជាកាលវេលាដែលទ្រង់តាំងសេចក្តីប្រាថ្នា ជាព្រះពុទ្ធឡើងក្នុងចិត្តជាគ្រាដំបូងហៅថា បឋមចិត្តុប្បាទកាល។

ចាប់ផ្តើមពីនោះមក ទ្រង់សន្សំបារមី រហូតដល់ភពចុងបំផុតបានតាំងសេចក្តីព្យាយាមប្រកបដោយអង្គ ៤ ដែលហៅថា ចតុរង្គប្បធាន កាលដូចដែលទ្រង់ត្រាស់ថាៈ

**កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យំ តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសប-**

**ភគ្គមេន បត្តព្វំ ន តំ អបាបុណិត្វា បុរិសស្ស វីរិយស្ស សណ្ឋានំ ភវិស្សតិ។** ស្បែក ១ សរសៃ ១ ឆ្អឹង ១ ចូរសល់នៅចុះ ឯសាច់ ឈាម ក្នុងសរីរៈចូររីងស្ងួតចុះ គុណជាតណា ដែលបុគ្គលគប្បី ដល់ ដោយកម្លាំង របស់បុរស ដោយសេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដី ប្រឹងប្រែង របស់បុរស បើមិនទាន់ដល់គុណជាតនោះទេ នឹងមិនបញ្ឈប់នូវ សេចក្ដី ព្យាយាមរបស់បុរសឡើង។

ព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ដែលព្រះអង្គទ្រង់បានមកនោះ រាប់ថា ជាការបានមកដោយសេចក្ដីលំបាកយ៉ាងក្រៃលែង ក្នុងព្រះជាតិចុង ក្រោយបំផុតដោយហេតុនេះឯង ទើបព្រះអដ្ឋកថាចារ្យបានប្រព័ន្ធបណាម គាថា ដើម្បីឱ្យរឭកដល់ព្រះគុណដ៏ធំក្រៃលែង រាប់ប្រមាណមិនបានរបស់ ព្រះសម្មាសម្ពុទ្ធ ដែលទ្រទ្រង់ទុកនូវព្រះគុណទាំង ៣ គឺព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ និងករុណាគុណ ដែលមិនមានអ្នកណាប្រៀបផ្ទឹមបាន។

កាលបើបុគ្គលមានចិត្តជ្រះថ្លា ពោលពាក្យនមស្ការដោយដោយ រឭកដល់ព្រះគុណទាំងនោះជានិច្ច ក៏នឹងធ្វើឱ្យចិត្ត ស្អាតផូរផង់ប្រាសចាក ភ័យ និងអន្តរាយ សូម្បីកិច្ចការដែលធ្វើក៏សម្រេចតាមសេចក្ដីប្រាថ្នានោះ ឯងហោង។

## គុណនៃព្រះធម៌

ផ្ទៃមេឃស្រឡះពីងងឹត    មានព្រះអាទិត្យបំភ្លឺដី
ខិតខំបញ្ចេញដួងរស្មី    ជួយឱ្យប្រុសស្រីធ្វើការងារ។

នៅពេលរាត្រីមានដួងចន្ទ រះខ្ពស់ឡើងកាន់ផ្ទៃមេឃា
ធ្វើឱ្យលោកនេះល្អសោភា តារានានារះលម្អ។
ពន្លឺក្នុងលោកមានច្រើនណាស់ ប្រុសស្រីឃើញច្បាស់ទើបត្រាច់ចរ
កាន់ទីឆ្ងាយជិតធ្វើរបរ បានដោយផលល្អពន្លឺគ្រប់។
ព្រះអាទិត្យបំភ្លឺពេលថ្ងៃ ឯដួងចន្ទថ្ងៃភ្លឺពេលយប់
ក៏គង់ពេលខ្លះមិនអាចសព្វ មានប្រុសស្រីស្អប់ជាធម្មតា។
អ្វីៗក្នុងលោកមិនអាចផ្គាប់ នេះជាទម្លាប់នៃអ្នកថា
កុំថាឡើយមនុស្សទោះទេវតា ធ្វើល្អយ៉ាងណាតែងនិន្ទា។
ចំណែកព្រះធម៌ព្រះសម្តែង ភ្លឺល្អចិញ្ចែងសព្វវេលា
គង់តែទាស់ចិត្តជនពាលា អ្នកមានសទ្ធាតែងជ្រះថ្លា
អ្នកណាស្តាប់ធម៌ដោយផ្ចិតផ្ចង់ បានអានិសង្សប្រាំប្រការ
បុគ្គលតាំងចិត្តប្រុងសោតា ស្តាប់យកធម៌អាថ៌មិនធ្លាប់ឮ។
ធម៌ណាស្តាប់ហើយមិនចូលចិត្ត ខិតខំរិះគិតរឹតតែភ្លឺ
កម្ចាត់សង្ស័យដូចជំងឺ ប្រែមានពន្លឺថ្លាត្រចង់។
អ្នកណាស្តាប់ធម៌ដោយគោរព ត្រិះរិះសព្វគ្រប់ទិដ្ឋិត្រង់
បុគ្គលញ៉ាំងចិត្តល្អផូរផង់ ផលានិសង្សជួយបំភ្លឺ។
ព្រះពុទ្ធប្រៀបដូចព្រះអាទិត្យ ឯព្រះធម៌ពិតល្បីរន្ទឺ
ប្រៀបដូចឱសថជួយអ្នកឈឺ ព្យាបាលជំងឺជនប្រុសស្រី។
រីឯសត្វលោកដូចអ្នកឈឺ ជាពីជំងឺផុតទុក្ខភ័យ

ដោយសារមានថ្នាំព្រះជិនស្រី ត្រាស់ព្រះធម៌ថ្លៃផុតវិយោគ។
ចំណែកព្រះសង្ឃអង្គសាវក បួសតាមឥតអាក់ព្រះមានជោគ
សិក្សាសង្រួមបាតិមោក្ខ ពិតផុតទុក្ខសោកជាស្រែបុណ្យ។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## ៥.ជំរុំជីវិតប្រព្រឹត្តតាមធម៌

ជីវិតក្នុងការរស់នៅប្រចាំថ្ងៃ រមែងមានការជួបប្រទះរឿងរ៉ាវជាច្រើន មិនអាចពណ៌នាបាន ជួនកាលបានជួបប្រទះសុខ ឬក៏ទុក្ខជាធម្មតាមនុស្ស

យើងមិនអាចគេចផុតបានឡើយ ហើយយើងមិនអាចដឹងអំពីដំណើរនៃជីវិតដែលកំពុងតែប្រឈមមុខជាមួយនឹងបញ្ហាផ្សេងៗ។

ក្នុងឆាកជីវិតរបស់មនុស្សយើង មិនអាចនឹងមើលឃើញបានទេ ថាវាទៅជាយ៉ាងណានោះ តែប្រសិនបើបានដឹងវិញគ្រាន់តែបានដឹងត្រឹមថា មនុស្សណាដែលខំប្រឹងធ្វើការ ឬខំប្រឹងរៀនសូត្រព្យាយាមធ្វើអ្វីៗ គ្រប់ បែប យ៉ាងទាំងអស់ នឹងដើម្បីប្រយោជន៍ខ្លួនតែប៉ុណ្ណោះ។

ប្រសិនវិទ្យាសាស្ត្រគេព្យាករណ៍នូវហេតុការណ៍វិញ បានដឹងត្រឹមតែមានការរញ្ជួយដី ទឹកជំនន់ មានផ្ទុះភ្នំភ្លើង ឬក៏ខ្យល់ព្យុះជាដើមទាំងអស់នេះ អាចព្យាករណ៍បានត្រឹមខាងក្រៅ តែមិនអាចហ៊ានធានាថាត្រូវទាំងអស់បានឡើយ មានពាក្យនិយាយខ្លះទៀតថាឱ្យតែបានរៀនខ្ពស់ វារមែងរស់នៅបានដោយប្រសើរមិនមានភ័យក្នុងខ្លួន...។

តើទាំងអស់នេះ អ្នកនិយាយអាចហ៊ានធានាបានទេថា វាមិនកើតទុក្ខដូចដែលយើងបាននិយាយខាងលើ? ធម្មតាការកើតឡើងរបស់ក្នុងលោករមែងមានការតាំងនៅ និងវិនាសទៅវិញជាធម្មតា បើបានដឹងដូច្នេះហើយ មិនមានបុគ្គលណា ដែលជាសត្រូវនឹងខ្លួនឯងនោះឡើយ រឿងដែលថាគេជាសត្រូវរបស់ខ្លួននោះ គឺគ្រាន់តែយើងគិតដោយខ្លួនឯងនោះទេ តាមសច្ចធម៌មិនមានដូច្នោះទេ សមដូចរឿងដែលព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងគង់នៅក្នុងព្រៃស្វាយ របស់ពេទ្យជីវក ទ្រង់ប្រារព្ធបញ្ហាដែលពេទ្យជីវកទូលសួរ ទើបព្រះដ៏មានបុណ្យត្រាស់សម្ដែងទេសនានេះថា (គតទ្ធិនោ)នៅក្នុង ខន្ធកៈយ៉ាងពិស្ដារ សម័យនោះឯងទេវទត្តរួមគំនិតជាមួយនឹងព្រះរាជា ព្រះនាម អជាតសត្រូវ ជាអ្នកមានចិត្តត្រូវទោសប្រទូស្តហើយឡើងកាន់ភ្នំ គិជ្ឈ

កូដ ដោយគិតថាយើងនឹងផ្តាច់ព្រះជន្មព្រះសាស្តា ទើបប្រមៀលដុំថ្ម ទម្លាក់ចុះ។

កំពូលភ្នំទាំងពីរ ទទួលដុំថ្មនោះមិនឱ្យធ្លាក់ចុះមក ចំណែកថ្មដែលបែកចេញអំពីដុំថ្មនោះ ខ្ទាតទៅប៉ះព្រះបាទរបស់ព្រះមានព្រះភាគ ញុំាងព្រះលោហិតឱ្យពុះពងឡើង វេទនាដ៏ខ្លាំងក្លា ក៏បានកើតឡើងដល់ព្រះតថាគត ទើបពេទ្យជីវកធ្វើការព្យាបាលដំបៅថ្វាយព្រះសម្ពុទ្ធ ភិក្ខុទាំងឡាយនាំព្រះសាស្តាទៅកាន់សួនមទ្ទកុច្ឆិ ព្រះសាស្តាមានបំណង នឹងស្តេចចេញចាកសួនមទ្ទកុច្ឆិនោះទៅកាន់ជីវកម្ពវ័នរបស់ពេទ្យជីវក ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរនាំតថាគតទៅកាន់ជីវកម្ពវ័នរបស់ពេទ្យជីវក។

ពួកភិក្ខុ ក៏បាននាំព្រះមានព្រះភាគ ទៅកាន់ជីវកម្ពវ័ន របស់ពេទ្យជីវក ពេទ្យជីវកដឹងរឿងនោះហើយ ក៏ទៅកាន់សំណាក់ព្រះសាស្តាថ្វាយភេសជ្ជៈដ៏ខ្លាំង (ថ្នាំខ្លាំង) ដើម្បីប្រយោជន៍ដល់ការព្យាបាលដំបៅ រុំដំបៅស្រេចហើយបានក្រាបទូលពាក្យនេះនឹងព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រូវផ្សំថ្នាំឱ្យដល់មនុស្សម្នាក់ខាងក្នុងនគរ ខ្ញុំព្រះអង្គនឹងទៅកាន់សំណាក់របស់មនុស្សនោះហើយនឹង (ត្រឡប់)មកគាល់ព្រះអង្គវិញ ការរុំដំបៅនេះ ចូរតាំងនៅតាមនិយាយ ដែលខ្ញុំព្រះអង្គធ្លាប់រុំទុកចុះ ទម្រាំខ្ញុំ ព្រះព្រះអង្គនឹងត្រឡប់មកវិញ។ ពេទ្យជីវកទៅធ្វើកិច្ច ដែលគួរធ្វើដល់បុរសនោះហើយត្រឡប់មកវិញ មិនមានឱកាសបានចូលទៅគាល់ព្រះអង្គ ព្រោះមកក្នុងវេលាគេបិទទ្វារនគរ។

គ្រានោះ សេចក្តីត្រិះរិះយ៉ាងនេះ បានកើតឡើងដល់ពេទ្យជីវកនោះថា ឱ!ស្លាប់ហើយអញៗបានធ្វើកម្មដ៏ធ្ងន់ហើយ អាត្មាអញបានប្រគេនថ្នាំដ៏ខ្លាំងរុំដំបៅឰដ៏ព្រះបាទរបស់ព្រះតថាគត ដូចជាបុរសសាមញ្ញ វេលានេះ ជា

វេលាស្រាយនូវដំបៅនោះ កាលដំបៅនោះដែលអញមិនទាន់ស្រាយ សេចក្ដីក្ដៅក្រហាយក្នុងព្រះសរីរៈរបស់ព្រះមានព្រះភាគ នឹងកើតរហូតមួយ យប់ទាល់ភ្លឺ។

មុខដំបៅរបស់ព្រះសាស្ដាបានជាសះស្បើយ ខណៈនោះ ព្រះសាស្ដាត្រាស់ហៅព្រះអានន្ទមកហើយ ត្រាស់ប្រាប់ថា ម្នាលអានន្ទ ពេទ្យជីវកមកក្នុងវេលាល្ងាច មិនបានឱកាសចូលមកគាល់តថាគត ក៏គិតថា វេលានេះជាវេលាស្រាយសំពត់រុំដំបៅ អ្នកចូរស្រាយសំពត់រុំដំបៅនោះចុះ ព្រះថេរៈក៏ស្រាយសំពត់រុំដំបៅនោះតាមពាក្យព្រះពុទ្ធដីកា មុខដំបៅក៏ជា សះស្បើយ ដូចក្រមរឈើរបើកចេញអំពីដើមឈើ។

(ព្រះអរហន្តមិនមានសេចក្ដីក្ដៅក្រហាយចិត្ត)

ព្រឹកឡើង ពេទ្យជីវកទៅកាន់សំណាក់ព្រះសាស្ដាយ៉ាងប្រញាប់ លុះទៅដល់ហើយ ក៏ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីក្ដៅក្រហាយកើតឡើង ក្នុងព្រះសរីរៈរបស់ព្រះអង្គដែរឬទេ? ព្រះសាស្ដាត្រាស់ថា ម្នាលជីវក សេចក្ដីក្ដៅក្រហាយទាំងពួងរបស់តថាគតគង់នៅក្នុងមណ្ឌលពោធិព្រឹក្សម្ល៉េះ ដូច្នេះហើយកាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងព្រះធម៌ បានត្រាស់ព្រះគាថានេះ (អរហន្តវគ្គទី ៧ បិដកលេខ ៥២ ទំព័រ ៤០)ថាៈ

**គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ**
**សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ។**

សេចក្ដីក្ដៅក្រហាយ រមែងមិនមានដល់លោកអ្នក មានផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្ដីសោក រួចស្រឡះចាកធម៌ទាំងពួង (មានខន្ធជាដើម) មានកិលេសជាគ្រឿងចាក់ស្រេះទាំងពួងលះបង់ហើយ។

ចំពោះអំណាចដែលទេវទត្ត ធ្វើអំពើអាក្រក់ ដើម្បីខ្លួនឯងគិតថាបានសេចក្ដីសុខ ទីបំផុតក៏ត្រូវក្ដៅក្រហាយនៅមិនសុខ មានការលំបាកទាំងផ្លូវកាយ ទាំងផ្លូវចិត្តទីបំផុតត្រូវព្រះធរណីស្រូប។

ចំពោះសេចក្ដីក្ដៅក្រហាយ ដែលព្រះដ៏មានព្រះភាគទ្រង់ទទួលអកុសលវិបាក កាលពីជាតិមុនមិនមានឱ្យព្រះអង្គក្ដៅក្រហាយបានឡើយ ដោយអំណាចដែលព្រះអង្គបានកម្ចាត់បង់ មានខ្លួនជាទីពឹងដោយខ្លួនឯង ពោលគឺមានធម៌ជាទីជុំរុំត្រជាក់ត្រជុំនៃចិត្ត ដូច្នេះហើយបានជាមិនក្ដៅក្រហាយដូចទេវទត្ត។

ទេព្យជីវកទូលសួរសំដៅដល់ការក្ដៅក្រហាយកាយ ប៉ុន្តែព្រះសាស្ដាទ្រង់ផ្លាស់ប្ដូរព្រះធម៌ទេសនា ដោយអំណាចនៃការក្ដៅក្រហាយ ដែលប្រព្រឹត្តទៅក្នុងចិត្ត ព្រោះព្រះអង្គឈ្លាសវៃក្នុងពិធីទេសនា ព្រោះព្រះអង្គជាធម្មរាជា ទើបត្រាស់ថាម្នាលជីវក សេចក្ដីក្ដៅក្រហាយ រមែងមិនមានដល់ព្រះខីណាស្រព។

យ៉ាងណាមិញ ចំពោះបុគ្គលដែលមានធម៌ជាទីជុំរុំនៃចិត្តរឿយៗ រមែងមិនក្ដៅក្រហាយដូចជា ពួកជននៅក្នុងវាលស្មៅ ក្ដៅយ៉ាងខ្លាំងហើយពេលក្រឡេកឃើញម្លប់ឈើ បានទៅជ្រកក្រោមម្លប់នោះមានខ្យល់បក់ រមែងមានកាយជាសុខយ៉ាងណាមិញ បុគ្គលមានជុំរុំ ពោលគឺយកព្រះធម៌ជាម្លប់ហើយ រមែងបាននៅជាសុខអស់កាលដ៏យូរអង្វែង។

## **បំណុលជីវិត**

អ្នកក្រុងហ៊ីហាទិញចូលលក់ចេញ ជនបទនោះវិញធ្វើស្រែចម្ការ
ពីរដូវប្រាំងទល់ខែវស្សា ខិតខំឧស្សាហ៍សន្សំទ្រព្យធន។

ជីវិតកម្មករធ្វើការជូនគេ ពុំសូវទំនេរការងារស្រាលធ្ងន់
ធ្វើទាំងយប់ថ្ងៃមិនដែលទម្រន់ មិនដែលលួចប្លន់គំនិតស្មោះសរ។
ទាហានកងទ័ពការពារទឹកដី ឯពួកមន្ត្រីជួយជាតិបន្ត
ធ្វើគ្រូបង្រៀនចង់ឱ្យសិស្សល្អ អ្នកភ័យខ្លាចក្រទើបខំធ្វើការ។
យប់ហើយនិងថ្ងៃខ្លួនកាន់តែចាស់ ម្នាក់ៗខំណាស់លើកស្ទួយអាត្មា
ចង់ឱ្យខ្លួនល្អរស់បានសុខា លំបាកម្ដេចម្ដាឱ្យតែបានរស់។
ពេលខ្លះខ្លួនមានភ្លេចគិតដល់ក្រ មិនសាងធម៌សធ្វើតែបាបគ្រោះ
ស្រវឹងនឹងទ្រព្យជាប់គ្រឿងសក្តិយស ខ្លួនជិតធ្លាក់ជ្រោះទើបភ្ញាក់ស្មារតី។
ធម្មតាមានទ្រព្យក៏មានទៅចុះ កុំភ្លេចស្រីប្រុសសាងទានបារមី
បើអត់សីលទេរិះរេឃ្មាតខ្មី សីលប្រាំប្រាំបីកាន់យកឱ្យបាន។
ជីវិតប្រៀបដូចជាការដើរផ្លូវ ជួបទឹកសែនជ្រៅឆ្ងាយហួសពីស្មាន
បើសិនគ្មានទូកពិតជាខកប្រាណ ឆ្លងទៅមិនបានដល់ត្រើយនាយឡើយ។
ម្យ៉ាងជីវិតនេះដូចខ្ចីពីគេ នៅមិនយូរទេគេទារវិញហើយ
គួរខំប្រញាប់កុំបីកន្តើយ សាងគុណឱ្យហើយទុកជាទីពឹង។
សុខភាពរឹងប៉ឹងរូបកាយស្គមធាត់ ពិតមិនទៀងទាត់រឿងនេះត្រូវដឹង
មិនយូរប៉ុន្មានដេកស្លាប់ស្ដូកស្ដឹង កាយនេះឯងរឹងដូចអង្កត់ឧស។
មែនហើយបានរស់គួររៀនធម៌អាថ៌ ទើបមានប្រាជ្ញាគេចផុតពីខុស
ដោយសារយល់ត្រូវចេះគិតសន្ដោស ទានសីលចម្រុះសងបំណុលចាស់។
ដូច្នេះសប្បុរសដែលបានដឹងហើយ ចូរកុំកន្តើយគិតឱ្យបានច្បាស់
ធ្វើការរកស៊ីឆ្លៀតស្ដាប់ធម៌ខ្លះ កុំប្រែក្រឡាស់ពីបុណ្យកុសល។
គួរតែរិះរេទៅវត្តទៅវ៉ា កុំជាប់ស្រីស្រាគ្រឿងនាំខ្វាយខ្វល់
គួររៀនធម៌ព្រះចម្រើនកុសល កម្ចាត់ចម្ងល់សម្អាតចិន្ដា។

គួរសាងបុណ្យថ្មីប្រល័យបាបចាស់ គំនិតផ្តេសផ្តាសកុំមានឡើយណា
ដុសខាត់ភាពខ្ជិលខិតខំឧស្សាហ៍ សាងធម៌មេត្តាកុំបីរួញរា។
ម្យ៉ាងទៀតរស់នៅជួបជុំញាតិមិត្ត ត្រូវតែអាណិតកុំបៀតបៀនគ្នា
ចង់ឱ្យខ្លួនល្អចូរកុំនិន្ទា នាំពៀរវេរាទុក្ខសោកវែងឆ្ងាយ។
ប៉ុណ្ណឹងសិនចុះអស់លោកប្រុសស្រី សូមបញ្ចប់ខ្ចីឃ្លាតទាំងសោកស្តាយ
សូមជូនបុណ្យអ្នកកុំមានអន្តរាយ ជួបតែសប្បាយនៅក្នុងគ្រួសារ។
ម្យ៉ាងទៀតបើមានភពជាតិកំណើត សូមឱ្យបានកើតជួបនឹងសាសនា
នៃព្រះសម្ពុទ្ធបរិសុទ្ធអស្ចារ្យ ឆ្លងវដ្តសង្សារលុះនិព្វានហោង។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## ៦.ហេតុសំខាន់ៗក្នុងព្រះពុទ្ធសាសនា

ហេតុសំខាន់ៗ ដែលពុទ្ធបរិស័ទជាអ្នកកាន់សាសាព្រះពុទ្ធ ត្រូវតែដឹងអំពីកំណើតនៃការគោរពបូជាគុណ ដែលព្រះអង្គបានបន្សល់ទុកជានិមិត្តរូប សម្រាប់ឱ្យអ្នកក្រោយធ្វើតាម និងជាហេតុសំខាន់បំផុតក្នុងថ្ងៃដែលព្រះមុនីបានត្រាស់ដឹងជាដើម។

ពុទ្ធបរិស័ទភាគច្រើន នៅប្រទេសកម្ពុជរដ្ឋស្ទើរតែទាំងអស់ ជាអ្នកកាន់គោរពបូជា ចំពោះគុណព្រះអង្គ គឺយកទំនៀមទម្លាប់តាមប្រពៃណីគោរពមាតាបិតា ជីដូនជីតា គ្រូកូលរៀមច្បង និងមានការដឹងគុណជាដើម ដូច្នេះទើបបានជាអ្នកជ្រះថ្លា ក្នុងការធ្វើបុណ្យនោះលះវត្ថុដ៏មានតម្លៃ ធ្វើជាទានឥតមានរួញរាឡើយ។ ទុកជាបានធ្វើបុណ្យជាច្រើនយ៉ាងនេះ ក៏ដោយមានមនុស្សមិនតិចអ្នកទេ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនាមិនបានដឹងនូវប្រវត្តិសំខាន់ៗ ដែលគួរប្រារព្ធធ្វើកម្មវិធីបុណ្យ។ មិនមែនអ្នកសរសេរនេះចង់និយាយថា ឱ្យអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់គ្នានោះជាអ្នកមិនចេះដឹងក្នុងប្រវត្តិរបស់ព្រះអង្គនោះទេ តែក្នុងសេចក្ដីនេះ ចង់បង្ហាញឱ្យបានយល់អំពីហេតុការណ៍សំខាន់ៗ ក្នុងថ្ងៃដែលពុទ្ធបរិស័ទចងចាំគ្រប់ៗគ្នាងាយស្រួលក្នុងកិច្ចប្រារព្ធបូជាគុណព្រះអង្គក្នុងថ្ងៃនីមួយៗ។

ពុទ្ធកិច្ចដែលមានហេតុការណ៍សំខាន់ ចំពោះព្រះមុនីបានធ្វើទុកអស់រយៈកាលប្រមាណ ៨០ ព្រះវស្សា ក៏ត្រូវយើងគោរពបូជាសំខាន់។ មានហេតុការណ៍សំខាន់ៗ ៣ ដែលត្រូវប្រារព្ធបូជាក្នុងព្រះពុទ្ធសាសនា គឺថ្ងៃ ១៥ កើត ខែអាសាឍ ថ្ងៃ ១៥ កើត ខែមាឃ ថ្ងៃ ១៥ កើត ពិសាខ។

នេះសុទ្ធតែមានសារៈសំខាន់ដូចៗគ្នាទាំងអស់ ថ្ងៃ ១៥ កើតខែអាសាឍមានចំណុចសំខាន់ៗ ៥ យ៉ាង ដែលយើងត្រូវធ្វើការបូជាជាថ្ងៃដែលព្រះអង្គយាងចុះចាប់បដិសន្ធិ ជាថ្ងៃដែលព្រះអង្គយាងសាងព្រះផ្នួស ជាថ្ងៃ ដែលព្រះអង្គទ្រង់សម្ដែងធម្មទេសសនាដំបូង ជាថ្ងៃដែលព្រះអង្គទ្រង់ស្ថាបនាឱ្យមានភិក្ខុសង្ឃក្នុងសាសនា និងជាថ្ងៃដែលព្រះអង្គទ្រង់សម្ដែងនូវយមកប្បាដិហារិយ៍។

ចំពោះថ្ងៃ ១៥ កើត ខែមាឃ វិញមានចំណុច ៥ យ៉ាង ដែលយើងត្រូវចងចាំកុំបីភ្លេច ថ្ងៃមាឃនក្ខត្តឫក្ស គឺព្រះចន្ទភ្លឺច្បាស់ល្អ។

ជាថ្ងៃដែលភិក្ខុសង្ឃចំនួន ១២៥០ អង្គមកជួបជុំគ្នាដោយឥតបានណាត់ទុក (ព្រះភិក្ខុសង្ឃទាំងអស់នោះ សុទ្ធតែជាព្រះអរហន្តខីណាស្រពទាំងអស់ព្រះអង្គ) ជាថ្ងៃដែលព្រះពុទ្ធគ្រប់ៗព្រះអង្គទ្រង់សម្តែងនូវឱវាទបាតិមោក្ខ និងដាក់ព្រះជន្មាយុសង្ខារ។

ជាថ្ងៃដែលព្រះសារីបុត្រ ជាអគ្គសាវកខាងស្តាំបានសម្រេចធម៌ ជាន់ខ្ពស់។

ជាថ្ងៃដែលព្រះអង្គទ្រង់ ស្ថាបនាអគ្គសាវកទាំងពីរព្រះអង្គ គឺ (សារីបុត្ត និងព្រះមោគ្គល្លាន)។

ថ្ងៃ ១៥ កើត ខែពិសាខ មានចំណុចសំខាន់ៗ ៧ យ៉ាង ដែលយើងត្រូវធ្វើកាគោរពបូជា គឺជាថ្ងៃដែលព្រះអង្គទទួលការព្យាករណ៍ថានឹងបានត្រាស់ដឹងជាព្រះពុទ្ធ ក្នុងពេលដែលព្រះអង្គនៅជាព្រះពោធិសត្វឈ្មោះ (សុមេធបណ្ឌិត)។

ជាថ្ងៃដែលព្រះអង្គប្រសូត ជាថ្ងៃដែលព្រះពោធិព្រឹក្សដុះឡើង ជាថ្ងៃដែលព្រះពោធិសត្វបានត្រាស់ដឹងជាព្រះពុទ្ធ ជាថ្ងៃដែលព្រះអង្គទ្រង់សម្តែងនូវឱវាទចុងក្រោយបង្អស់ជាថ្ងៃ ដែលធាតុបរិនិព្វាន (និងមានក្នុងអនាគត) ទាំងនេះហើយបានជាយើង ត្រូវធ្វើការសិក្សាឱ្យបានយល់ច្បាស់ទើបជាការល្អ ក្នុងនាមយើងជាអ្នកកាន់ព្រះពុទ្ធសាសនា។

ក្នុងការលើកយកមកនេះ មិនបានជាពិស្តារសម្រាប់អត្ថាធិប្បាយ ឱ្យបានច្បាស់គ្រប់គ្រាន់ទេ ដោយសារសៀវភៅនេះមានរូបរាងតូចពេកដូច្នេះ ហើយសូមអស់លោកអធ្យាស្រ័យផងចុះ។

# តេជះព្រះពុទ្ធសាសនា

ជីវិតកំព្រាអនាថា ក្រោមពុទ្ធសាសនាព្រះជិនស្រី
ស្នាក់នៅសុខស្រួលរៀនបាលី ដឹងអត្ថសេចក្ដីព្រះធម្មា។
ឱះឱតេជះពុទ្ធសាសនា ប្រសើរអស្ចារ្យហួសគណនា
គឺពិតជាក់ច្បាស់រាល់វេលា ជនណាបូជាសុខឥតហ្មង។
មើលចុះបរិស័ទដ៏ច្រើនគ្នា ចូលមកបព្វជ្ជាទាំងប្អូនបង
សន្សំកុសលទានសីលផង ក្នុងចិត្តគិតផ្សងរកក្ដីសុខ។
ព្រះសង្ឃសាវកគួរជ្រះថ្លា បួសកាត់តណ្ហាគ្រឿងស្មាញស្មុគ
ជាទីគោរពជនគ្រប់ស្រុក សាងធម៌រកសុខសួគ៌និព្វាន។
ធម៌ជាមាគ៌ាដ៏ច្បាស់ច្បង ប្រសើរកន្លងប្រដូចគ្មាន
ជនណាប្រព្រឹត្តស្មើសាងស្ពាន តាមព្រះទូន្មានផុតទុក្ខា។
ការចូលមកបួសសែនកម្រ មិនងាយត្រេកអរនឹងសាសនា
ឃើញខុសឆ្គងម្ដងគួរមេត្តា មិនគួរស្ដីថាពោលឡែបខាយ។
បុគ្គលមួយខុសក្នុងសាសនា មិនគួរឡូឡាព័ត៌មានផ្សាយ
បង្ហាញទោសទណ្ឌអធិប្បាយ បំភ្លឺបកស្រាយរឿងអាស្រូវ។
គេឯងធ្វើល្អរាប់រយដឹង ម្ដេចមិនផ្សាយផងឱ្យហើយទៅ
ឃើញតែមួយជ្រុងដូចមិនត្រូវ ជួយស្ដាប់ម៉ែឪក្រែងថាខុស។
តាមពិតពាក្យថាពុទ្ធសាសនា មិនមែនយាយតាស្រីឬប្រុស
មិនមែនវិហារកុដិចម្រុះ សូមកុំយល់ខុសគិតឱ្យច្បាស់។
សាសនាមិនមែនជាព្រះសង្ឃ ដូនជីរយអង្គមានក្មេងចាស់
ចេតិយសួនច្បារមីរដេរដាស អណ្ដូងទឹកស្រះឈើហូរហែ។
តាមពិតពាក្យថាពុទ្ធសាសនា គឺជាធម៌អាថ៌វិន័យដែរ

សូមកុំច្រឡំខុសហើយកែ គិតរាល់ថ្ងៃខែដោយស្មគ្រស្មោះ។
ព្រះពុទ្ធសាសនាល្អប្រសើរ បុគ្គលទេតើដែលឡេះឡោះ
សូមជម្រាបលោកអ្នកទាំងអស់ គិតគ្រប់ចន្លោះទោះយប់ថ្ងៃ។

ដោយសាមណេរ សា ចាន់រ៉ាត់

## ៧.គ្រឿងការពារជីវិតប្រចាំថ្ងៃ

ក្នុងសេចក្តីនេះផងដែរ យើងធ្លាប់តែមានការរស់នៅដោយសេចក្តីសំអាងជឿជាក់ទៅលើខ្លួនឯងថា អាត្មាអញមានជីវិតរស់នៅបានយូរ មានទ្រព្យសម្បត្តិច្រើន មានបរិវារ មានអំណាចមិនសូវជាមានរោគ ដូច្នេះហើយបានជាមានសេចក្តីប្រមាទ មិនសូវគិតទៅដល់សេចក្តីស្លាប់ប៉ុនណាទេ។

ទុកជាយ៉ាងនេះក្តី មានមនុស្សមិនតិចនាក់ទេ ដែលមានជីវិតដូចជាបាននិយាយខាងលើ ហើយរមែងមានរឿងអាស្រូវត្រូវបាន សេចក្តីទុក្ខចូលមកជំនួសការសប្បាយ បែរជាបាត់អស់គ្មានសល់ សូម្បីតែស្នាមញញឹមមួយដែលធ្លាប់តែអ្នកដទៃនិយាយលេងជាមួយ កាលពីមុនធ្លាប់តែសើច ប៉ុន្តែពេលនេះបាត់អស់គ្មានសល់។ ប្រភពនៃសេចក្តីទុក្ខនេះមានច្រើនណាស់ វាកើតស្ទើរតែគ្រប់ពេលវេលាទាំងអស់ ប៉ុន្តែយើងមិនបានគិតទៅដល់ថ្នាក់ហ្នឹងទេ ប្រសិនបើយើងគិតវិញ គិតថាខ្ញុំពិបាកចិត្តខ្លាំង តើនេះមកពីមូលហេតុអ្វី? មានមនុស្សខ្លះ កើតទុក្ខហើយតែងតែនិយាយថា ខ្ញុំពិបាកចិត្តជាងគេ គេធ្វើបាបចិត្ត គេមិនឱ្យតម្លៃ គេមិននិយាយរក គេមិនពេញចិត្តក្នុងការងារ ដែលខ្លួនបានធ្វើ...។

បើចំពោះអ្នកដែលមានគ្រួសារវិញ និយាយតែពីរឿងរបស់គាត់ថាប្តីរមែងមិនយល់ចិត្ត កូនមិនស្តាប់តាមពាក្យទូន្មានរបស់គាត់ រមែងកើតទុក្ខយ៉ាងក្រៃលែង យើងថាមនុស្សក្មេងនោះ វាយ៉ាងហ្នឹងទៅហើយចុះមនុស្សចាស់ ដែលរូបគាត់មានសេចក្តីទុក្ខមកដល់វិញ តើយើងត្រូវបន្ទោសនរណាឱ្យសម ចំពោះលោកយាយលោកតាវិញ គាត់មានការពិបាកចិត្ត ដូចតែក្មេងដែរព្រោះអ្វីបានជានិយាយយ៉ាងហ្នឹង? ដោយសារតែសេចក្តីទុក្ខវាកើតបានគ្រប់មនុស្សទាំងអស់សេចក្តីទុក្ខទាំងអស់នេះ វាកើតតែអំពីចិត្តរបស់ អ្នកគិតទាំងអស់ សមដូចពុទ្ធឱវាទបានសម្តែង(បិដកលេខ ៥២ ទំព័រ ២១)ថា:

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ។**

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត មានចិត្តជាធំ សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅដូច កង់រទេះវិលទៅតាមដានជើងគោ ដែលកំពុងអូសទៅ។

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**
**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី។**

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត មានចិត្តជាធំ សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅដូច ជាស្រមោលអន្ទោលតាមប្រាណ។

ដូច្នេះហើយ បានជាមានសត្វលោកប្រព្រឹត្តអំពើទាំងល្អ ទាំងអាក្រក់ ហើយអ្នកដែលធ្វើល្អ រមែងសប្បាយចិត្តនៅជាសុខ តែចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើទុច្ចរិតមានការនៅមិនសុខកាយ រស់បានដោយភាពភ័យខ្លាចទៀតផង។ យើងយកធម៌របស់ព្រះពុទ្ធមកពិចារណា ក្នុងការរស់នៅប្រចាំថ្ងៃ ដើម្បីការពារនូវមេរោគ ដែលចូលមកតាមខ្លួនទាំងល្អិត និងគ្រោតគ្រាតមានស្នឹងទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដែលមានការប្រជុំចុះចូលទន្លេមានរាគៈជាទឹក ការមិនចេះពេញទៅដោយកិលេស។

ដើម្បីការពារនូវសត្រូវ គឺកិលេសមានស្នឹងដែលហូរមិនចេះពេញ ទៅដោយទឹក គឺរាគៈ ទោស មោហៈជាដើម។ ម្យ៉ាងទៀតសម្រាប់ការពារ នូវប្រភពមេរោគខាងក្រៅ ទុកតែមិនបានល្អយ៉ាងណាក៏ដោយ ក៏គង់បានសម្រេចដល់ជនភាគច្រើន ដែលមាននូវមេរោគដូចបានរៀបរាប់ខាងលើ

សូមសាកល្បងប្រតិបត្តិគោលធម៌ទាំង ១០ នេះសិនមើល៍ក្រែងមានប្រសិទ្ធិភាព។ **កាយសុចរិត** ប្រព្រឹត្តល្អដោយកាយ **វចីសុចរិត** ប្រព្រឹត្តល្អដោយវាចា **មនោសុចរិត** ប្រព្រឹត្តល្អដោយចិត្តវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យអ្នកដទៃ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកការនិយាយញុះញង់ វៀរចាក ការនិយាយចាក់ដោត វៀរចាកការនិយាយពាក្យឥតប្រយោជន៍ មិនសម្លឹងរំពៃចង់បានទ្រព្យរបស់អ្នកដទៃ មិនចង់ចិត្តប្រទូស្តរាយ គេឃើញតាមគន្លងធម៌។ ទាំងនេះមិនមែនងាយ សម្រាប់ធ្វើចំពោះអ្នកដែលមានជំងឺនោះទេ តែវាមិនហួសវិស័យរបស់យើងទេ ឱ្យតែយកមកប្រតិបត្តិតាមកាល។

## រស់ហើយសាងល្អ

ជីវិតបានរស់គួរសាងកុសល ប្រឹងប្រែងឱ្យដល់កិច្ចការបុណ្យទាន
ឆ្លៀតស្តាប់ធម៌ខ្លះតាមព្រះទូន្មាន នោះគឺសាងស្ពានទៅទីសុខសាន្ត។
រស់ដាក់មានះកុំអួតអាត្មា ត្រូវមានមេត្តាសត្វគ្រប់ទីឋាន
កុំសម្លាប់មនុស្សទោះសត្វតិរច្ឆាន សំខាន់គឺបានអប់រំកាយចិត្ត។

រស់ស្តាប់គេខ្លះកុំបីរឹងត្អឹង ចេះគិតថ្លែងថ្លឹងកុំពោលប្រឌិត
ឃើញគេខុសឆ្គងគួរតែអាណិត សង្គ្រោះពិតៗដោយចិត្តភក្តី។
រស់ចេះសាងគុណគ្រប់ពេលវេលា កុំសាងវេរានាំធ្លាក់អវិចី
រស់សាងធម៌អាថ៌ទើបឈ្មោះប្រពៃ ដូច្នេះលកលៃសាងអំពើល្អ។
រស់គោរពច្បាប់កុំបីគេចកែ ចេះស្តាប់ឪម៉ែទើបបានបវរ
ពិសេសរៀនធម៌ព្រះថាកម្រ ទើបបានត្រាច់ចរដល់ទីថ្លៃថ្លា។
សម័យឥឡូវព្រះធម៌មានហើយ គួរកុំកន្តើយស្តាប់គិតពិចារណ៍
ធ្វើទុកក្នុងចិត្តតាមន័យប្រាជ្ញា ប្រុងកាយវាចាស្ងៀមស្ងាត់កុំខាន។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## ៨.អ្នកមានសទ្ធាមិនភាំព្រាបុណ្យឡើយ

សទ្ធាសេចក្តីជឿបុណ្យ ជឿបាប ជឿកម្ម ជឿផលរបស់កម្ម ថាអ្នកណាធ្វើ អ្នកនោះទទួលបានសទ្ធាមុតមាំប្រកបដោយបញ្ញា មិនភ្ញាក់ផ្អើលជាមួយនឹងមង្គលផ្សេងៗ ដែលគេនិយាយតៗគ្នាថា យ៉ាងនេះយ៉ាងនោះ

ប៉ុន្តែយើងជាអ្នកស្ដាំក្នុងការជឿ សូមឱ្យជឿមានហេតុផលផង ដើម្បីងាយស្រួលមិនមានទោសជាដើម។

មនុស្សយើងភាគច្រើន តែងតែជឿដោយគ្មានហេតុផល សូម្បីតែបុគ្គលភាគខ្លះឮគេនិយាយរឿង ថាអ្នកនេះពូកែ បុគ្គលនោះអស្ចារ្យក្នុងលោកមិនទាន់ទាំងបានឃើញផង ស្រាប់តែជឿទៅហើយ មានមួយចំនួនទៀត ក្នុងការជឿនោះមានអ្នកខ្លះត្រូវបានចាញ់បោកគេក៏មានដែរ ទាំងនេះមិនអាចបន្ទោសបានឡើយ ដោយសារពួកគាត់មិនបានសិក្សា...។

ហើយរឿងនេះទៀតសោត មិនមែនមានតែបច្ចុប្បន្ននេះទេ គឺ មានតាំងតែពីយូរយាណាស់មកហើយ ក្នុងកាលដែលព្រះដ៏មានព្រះភាគ ព្រះអង្គគង់មានព្រះជន្មនៅឡើយ មានពេលខ្លះបរិស័ទមិនជឿព្រះអង្គក៏ មានដែរ ដូចជារឿងនាងចិញ្ចាមកថា នាងមានផ្ទៃពោះជាមួយព្រះអង្គ ពួកបរិស័ទដែលជាអ្នកស្ដាប់ធម៌ក្នុងវត្តជេតពន មានការងើ្មលឆោឡោ អ្នក ខ្លះថា ព្រះអង្គប្រព្រឹត្តនូវអំពើហ្នឹងមែន។

តែក្នុងអ្នកដែលជឿនាងចិញ្ចា ពេលនោះសុទ្ធតែពួកបុថុជ្ជន ទាំងនេះហើយ បានជាយើងមិនងាយទាញឱ្យគេជឿយើង បានដោយងាយៗនោះទេ ប៉ុន្តែចំពោះព្រះអរិយបុគ្គលវិញ រមែងមិនមានការកក្រើក ចំពោះព្រះអង្គឡើយ ក្នុងការប្រព្រឹត្តអំពើមិនល្អ ដូចជានាងចិញ្ចាបាននិយាយពេលនោះ ទីបំផុតនាងក៏ត្រូវព្រះធរណីស្រូបបាត់ទៅ ដោយអំណាចកម្មរបស់នាង ដែលបានធ្វើចំពោះព្រះអង្គ។

ក្នុងការនិយាយខាងលើ មិនបានថាឱ្យតែបុថុជ្ជនសុទ្ធតែអញ្ចឹងទាំងអស់នោះទេ តែចង់និយាយវិស័យជាបុថុជ្ជន ដូចជាយើងទាំងអស់គ្នាមិន

សូវជាមានបញ្ញា មុននឹងជឿអ្វីៗត្រូវពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយសិន ដើម្បីការពារមិនឱ្យមានការសោកស្តាយជាខាងក្រោយ។

ដូចមានរឿងនិទានមួយ ក្នុងសម័យពុទ្ធកាលនាយសុមនមាលាការ តែងតែទំនុកបម្រុងព្រះបាទពិម្ពិសារ ដោយផ្កាម្លិះ ៨ នាឡិរាល់ៗព្រឹកហើយ បានប្រាក់ ៨ កហាបណៈរាល់ៗថ្ងៃផងដែរ។

ថ្ងៃមួយសុមនមាលាការ បានជួបនឹងព្រះសម្មាសម្ពុទ្ធតាមផ្លូវបាន គិតថា យើងបានអ្វីបូជាព្រះអង្គហ្ន៎។ កាលបើមិនមានវត្ថុ អ្វីក្រៅអំពីផ្កាម្លិះក៏ គិតបូជាដោយផ្កាម្លិះ ចំពោះព្រះដ៏មានព្រះភាគបានគិតទៀតថា ផ្កានេះ សម្រាប់ថ្វាយដល់ព្រះរាជា គឺតែងតែទំនុកបម្រុងរាល់ថ្ងៃ កាលណាបើមិន មានផ្កាថ្វាយទេនោះ យើងនឹងត្រូវទទួលទោស ប៉ុន្តែទោះជាយ៉ាងណា ក៏ ដោយត្រូវសម្លាប់ ឬត្រូវដើម្បីប្រយោជន៍សុខដ៏ក្រៃលែង។ សុមនមាលាការ គិតដល់ថ្នាក់ព្រមលះបង់ជីវិត ចំពោះព្រះតថាគត មានចិត្តមិនប្រែប្រួលពី សេចក្តីជ្រះថ្លា ថែមទាំងមានបីតិសោមនស្ស រីករាយខ្លាំងក្លាជាមហាកុសល ចិត្តទី ១ បានកើតឡើង ហើយក៏បានបូជាផ្កាថ្វាយចំពោះព្រះបរមសាស្តា ក្នុងពេលនោះឯង។

សេចក្តីអស្ចារ្យបានកើតឡើង ដោយផ្កាដែលសុមនមាលាការបាន ថ្វាយទៅនោះ បានអណ្តែតតាមព្រះដ៏មានព្រះភាគ ដែលកំពុងតែយាង ចូលក្រុងដើម្បីបិណ្ឌបាតនោះឯង។ ផ្កាបាំងដូចជាវាំងនន ពីឆ្វេងផង ពីស្តាំ ផង ពីក្រោយផង និងពីលើផង មហាជនច្រើន អ៊ូអរក្រៃលែងស្រែក សាធុ ការក្នុងពេលនោះ ព្រះរាជាមិនត្រឹមតែមិនយកទោសប៉ុណ្ណោះ ថែម ទាំង ប្រទានរង្វាន់យ៉ាងច្រើន ដល់នាយសុមនមាលាការជាការបូជាគុណ ទៀត ផង។ ព្រះបរមសាស្តា ព្រះអង្គទ្រង់ត្រាស់ចំពោះព្រះអានន្ទត្ថេរក្នុង

កាលនោះថា ម្នាលអានន្ទ អ្នកកុំគប្បីកំណត់ថា កម្មមានប្រមាណតិចតួច ដែល សុមនមាលាការនេះបានធ្វើហើយនោះ ព្រោះសុមនមាលាការបាន លះបង់នូវជីវិត ធ្វើការបូជាចំពោះតថាគត គេញ៉ាំងចិត្តឱ្យជ្រះថ្លា ក្នុងការ បូជាបែបនេះ នឹងមិនទៅកាន់ទុគ្គតិ រហូតអស់មួយសែនកប្ប។

ពេលនោះព្រះអង្គបានត្រាស់ព្យាករណ៍ដូច្នេះថា នាយសុមនមាលា ការ នឹងតាំងនៅក្នុងកំណើតទេវតា និងមនុស្សទាំងឡាយ រមែងមិនទៅកាន់ ទុគ្គតិអស់សែនកប្បនេះ ជាផលនៃកម្មនោះ ក្រោយមកគេនឹងបានត្រាស់ ជាព្រះបច្ចេកពុទ្ធមានព្រះនាមថា សុមនៈ។ ក្នុងពេលដែលព្រះបរមសាស្ដា ស្ដេចយាងទៅដល់វេឡុវ័ន មហាវិហារ ហើយទ្រង់យាងចូលទៅកាន់ព្រះ គន្ធកុដិ ផ្កាម្លិះទាំងនោះបានធ្លាក់ចុះនៅត្រង់ខ្លោងទ្វារនាព្រះគន្ធកុដិនោះ ឯង។

ក្នុងវេលាល្ងាចថ្ងៃនោះ ភិក្ខុទាំងឡាយបានសន្ទនាគ្នា និងពោល សរសើរគុណរបស់សុមនមាលាការ ព្រះបរមសាស្ដាទ្រង់យាងចេញអំពី ព្រះគន្ធកុដិមក ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយនោះថា ម្នាលភិក្ខុទាំងឡាយ មានតែសោមនស្សរីករាយប៉ុណ្ណោះ នៅពេលដែលឃើញនូវអំពើដែលខ្លួន បានធ្វើនោះ កម្មនោះឯងដែលបុគ្គលគួរធ្វើ។ ព្រះអង្គទ្រង់សម្ដែងគាថា:

**តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ**
**យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្ដៅក្រហាយ ឬដល់នូវសេចក្ដី ពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ។

ចំណែកនាងដែលជាភរិយា គ្រាន់តែបានឮស្វាមីរបស់ខ្លួន បានថ្វាយផ្កា ចំពោះព្រះសម្មាសម្ពុទ្ធស្រាប់តែមានការភ័យខ្លាច ដោយសារតែផ្កានោះ ធ្លាប់តែយកទៅថ្វាយចំពោះព្រះរាជា ក៏លែងទទួលស្គាល់សុមន-មាការ ថាជាប្ដីនាងទៀតហើយ។ ព្រោះខ្លាចព្រះរាជាសម្លាប់ចោលជាមួយនឹងប្ដី ទើបធ្វើដូច្នោះ ទីបំផុតបានឮដំណឹងទៅដល់ព្រះរាជា ទើបព្រះរាជាដាក់ទោសភរិយារបស់សុមនមាលាការ និរទេសចេញពីនគរ ចំណែកសុមនមាលាការរស់នៅក្នុងទីដ៏សមគួរអស់ការជាអង្វែង។

សរុបសេចក្ដីមក ទុកជាយ៉ាងណាក៏ដោយសូមឱ្យការប្រព្រឹត្តរបស់យើងរាល់ថ្ងៃប្រកបដោយបញ្ញា ទើបមិនកំព្រាបុណ្យឡើយ ទីបំផុតចំពោះបុគ្គលណា ដែលមានសទ្ធាតាំងមាំហើយនោះ រមែងដូចជាសុមនមាលាការមិនខាន។ **សទ្ធា ទុតិយា បុរិសស្ស ហោតិ** សទ្ធាជាគូកនគម្រប់ពីររបស់បុរស **សទ្ធា សាធុ បតិដ្ឋិតា** សទ្ធាតាំងខ្ជាប់ខ្ជួនហើយ រមែងញុំាងប្រយោជន៍ឱ្យសម្រេចបាន។ **សទ្ធាធ វិត្តំ បុរិសស្ស សេដ្ឋំ** សទ្ធាជាទ្រព្យដ៏ប្រសើររបស់ក្នុងលោកនេះ។ **សទ្ធា ពន្ធតិ បាថេយ្យំ** សទ្ធារមែងប្រមូលទុកនូវស្បៀង គឺកុសល។

## កុំចេះតែចង់

អ្វីៗកើតឡើងមានហេតុបច្ច័យ មិនមែនស្រមៃហើយបានដូចចិត្ត

គឺត្រូវព្យាយាមតស៊ូយ៉ាងពិត ទើបបាននៃបនិត្យដូចក្តីប្រាថ្នា។
ផលល្អទាំងឡាយកើតពីការសាង មិនមែនសំអាងលើព្រេងវាសនា
គឺកើតពីហេតុប្រាំមួយប្រការ គ្រប់ជនខេមរាចូរអ្នកចងចាំ។
សំណាងទីមួយកើតពីព្យាយាម ធ្វើល្អកុំស្ងៀមអ្នកប្រាជ្ញលោកផ្តាំ
កុំដាក់ភារៈធ្វើរាល់ខែឆ្នាំ គឺកុសលកម្មគ្រប់ទ្វារទាំងបី។
រីឯទីពីរសេចក្តីអង់អាច មោះមុតមិនខ្លាចពុះពារឃ្មាតខ្មី
ចំពោះឧបសគ្គតូចធំចាស់ថ្មី គឺមានស្មារតីគ្រប់ពេលវេលា។
សំណាងទីបីគឺភាពក្លាហាន ជឿជាក់អង្គប្រាណចិត្តមានវិជ្ជា
យល់ហេតុត្រឹមត្រូវតាមព្រះធម្មា មិនខ្លាចរួញរាស្ទុះស្ទាត់តអាក់។
សំណាងទីបួនគឺមានបញ្ញា បានពីសិក្សាខំឱ្យប្រចក្ស
បានឃើញក្តីពិតដូចរួចពីខ្វាក់ មិនជាប់ច្រវាក់គឺវដ្តសង្សារ។
សំណាងទីប្រាំគឺមានអំណាច អ្វីៗអ្នកអាចធ្វើរាល់កិច្ចការ
ជឿលើធម៌ព្រះលះកាត់តណ្ហា គ្រប់គ្រងចិន្តាឱ្យឆ្ងាយបាបកម្ម។
សំណាងប្រាំមួយគឺការប្រឹងប្រែង កាប់គាស់លីសែងនោះជាប្រចាំ
មិនចាយខ្ជះខ្ជាយខំរករាល់ឆ្នាំ នេះគឺបណ្តាំទីកើតសំណាង។
ចំណង់ចង់បានមានរាល់វេលា លទ្ធផលខុសគ្នាកើតពីការសាង
អាក្រក់ឬល្អនោះជាភស្តុតាង ដែលជាតំណាងនៃកម្មទាំងឡាយ។
គិតទៅមនុស្សសត្វគ្រប់អស់យើងគេ ពុំសូវទំនេរនាំគ្នាខ្វល់ខ្វាយ
ប្រកបការងារកាប់គាស់កកាយ កុំឱ្យសោកស្តាយគឺគិតឱ្យច្បាស់។

បើបានដឹងហេតុមិនសូវជាចង់ ទៅទីគ្មានប្លង់ពិតជាទុក្ខក្រាស់
សក់ខ្មៅដល់ស្កូវពីក្មេងដល់ចាស់ គឺពិតខ្លាំងណាស់រកព្រេងវាសនា។
ចង់ជួបសុខពិតគួរស្តាប់ធម៌ព្រះ បើសិនចង់ឈ្នះគឺឈ្នះមោហា
ចង់រួចស្រឡះគឺផ្តាច់តណ្ហា នោះព្រេងវាសនាប្រាកដដល់អ្នក។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## ៩.ផ្លូវដ៏ប្រសើរសម្រាប់ជីវិត

ក្នុងការដើរផ្លូវវាសំខាន់ខ្លាំងណាស់ សម្រាប់មនុស្សលោកដែលប្រាថ្នាដើរស្វែងរកផលប្រយោជន៍ ទាំងបច្ចុប្បន្ន ដើម្បីទុកផលទៅដល់អនាគតនេះហើយ ជាសេចក្តីប្រាថ្នាគ្រប់ៗគ្នា។

ចំពោះអ្នកដើរផ្លូវ រមែងមានគ្រោះថ្នាក់ជាច្រើន ដែលយើងនឹកមិនដល់ ស្មានមិនត្រូវ ទាំងនេះតើមកពីមូលហេតុអ្វី? យើងមិនសូវជាបានគិតប៉ុន្មានទេ ដោយសារតែយើងគិតថាវាស្រួល ឬមួយក៏មានសេចក្តីប្រមាទការភ្លេចស្មារតីធ្វេសប្រហែស។ ដូច្នេះហើយបានជាត្រូវជួបនូវឧបសគ្គ ជាច្រើនដែលរាប់មិនអស់ ក្នុងការដើរទៀតសោតរមែងជួបនូវរឿងរ៉ាវ ជាច្រើនរាប់មិនអស់ ទាំងនេះហើយគ្មាននរណាហ៊ានធានារ៉ាប់រងនូវជីវិត របស់យើងបានឡើយ។ បើសិនជាធានាវិញ បានត្រឹមតែមួយភាគតូចតែប៉ុណ្ណោះតែសូមចាំថា ជីវិតយើងរមែងជួបនូវវិប្បដិសារៈអស់មួយជីវិត តើយើងធ្លាប់បានសាកល្បងហើយឬនៅ ចំពោះការដើររបៀបនេះ ទុកជាបានដើរក្តី មិនទាន់បានដើរក្តី សូមចាំថាមានកន្លែងមួយ ដែលយើងទាំងអស់គ្នាត្រូវសាកល្បងមើលសិន ព្រោះអ្វីបានជាយើងត្រូវសាកវាមើល ដោយសារកន្លែងនេះ មានគេនិយាយថា បើសិនជានរជនណាបានដើរ តាមផ្លូវនេះហើយ រមែងជួបនូវលាភដ៏ប្រសើរលើសលប់ ម្យ៉ាងទៀត បើសិនជាយើងបាន ដើរតាមមាគ៌ានេះហើយ រមែងមានការធានារ៉ាប់រងគ្រប់បែប យ៉ាងចំពោះជីវិតយើង។

មិនដឹងថាផ្លូវនោះជាផ្លូវអ្វីឡើយ ប៉ុន្តែគ្រាន់តែបានដឹងថាផ្លូវនោះមានគេបានដើរពីមុនខ្លះហើយ ចំពោះអ្នកដែលបានដើរតាមមាគ៌ានោះ រមែងទទួលបានថា មានសុវត្ថិភាពខ្លាំងណាស់ និងបានជោគជ័យគ្រប់បែបយ៉ាងទៀតផង។ បើអញ្ចឹងយើងដើរសាកលោមើល៍ ក្រែងបានដូចគេ

និយាយតៗគ្នាថាល្អ ប៉ុន្តែផ្លូវនោះមិនដឹងទៅរកនៅទីកន្លែងណាទេ? បើតាមខ្ញុំគិតមើល បែបជាមិនសូវពិបាករកទេមើលទៅ ដោយសារកន្លែងនោះមានអ្នកចាំណែនាំ ចំពោះមនុស្សណាដែលប្រាថ្នានឹងដើរស្រាប់ទៅហើយ។ តើនេះពិតមែនឬ បើអញ្ចឹងយើងទៅតែម្តងទៅកុំឱ្យហួសពេល។ តែសូមប្រាប់ថាកន្លែងដែលត្រូវទៅ យើងជាអ្នកប្រាថ្នា និងដើរត្រូវតែមានការជឿសេចក្តី បរិសុទ្ធតាមផ្លូវកាយ វាចា ចិត្តជាដើម មានការទ្រាំចំពោះភាពលំបាកគ្រប់យ៉ាង បានអាចដើរទៅដល់ទីតាំង យើងត្រូវដើរតាមដំណាក់កាលរបស់វា ក្នុងការដើរតាមដំណាក់កាលនោះ គឺមានតែ ៨ ចំណុចប៉ុណ្ណោះ **សម្មាទិដ្ឋិ** បញ្ញាបានយល់ឃើញត្រឹមត្រូវ គឺបានស្គាល់ច្បាស់នូវសេចក្តីចម្រើន ហេតុនៃសេចក្តីវិនាស ស្គាល់ធម៌ដែលគួរលះ និងធម៌ដែលគួរចម្រើនដើម្បីជាប្រយោជន៍។ **សម្មាសង្កប្បោ** ការត្រិះរិះត្រឹមត្រូវបានគិតគួរត្រិះរិះក្នុងរឿង ដែលមិននាំឱ្យជាប់ជំពាក់ គិតត្រូវក្នុងរឿង ដែលមិននាំឱ្យកើតការគុំកួន ចងអាឃាតព្យាបាទអ្នកដទៃ គិតក្នុងរឿង ដែលមិនឱ្យកើតការបៀត បៀនធ្វើទុកក្នុងចិត្តចំពោះអ្នកដទៃ។ **សម្មាវាចា** និយាយត្រឹមត្រូវ គឺនិយាយពាក្យពិត ពាក្យមានប្រយោជន៍ មិនបៀតបៀអ្នកដទៃមិនឱ្យអ្នកដទៃរងទុក្ខ និយាយពាក្យនាំឱ្យមានការព្រមព្រៀងគ្នា និយាយពាក្យពីរោះទន់ភ្លន់។ **សម្មាកម្មន្តោ** ធ្វើការងារត្រឹមត្រូវ គឺមិនទៅ សម្លាប់ជីវិតរបស់អ្នកដទៃ មិនធ្វើការងារលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។ **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រឹមត្រូវ គឺចិញ្ចឹមជីវិតដោយវៀរចាកទោសកម្មផ្សេៗ ក្នុងផ្លូវលោកផ្លូវធម៌។

បើពោលទៅដល់ការរកស៊ីចិញ្ចឹមជីវិតវិញ គឺត្រូវវៀរចាកអំពើ ឬក៏ជំនួញខុសទាំង ៥ យ៉ាងគឺៈ

**១.សត្ថវណិជ្ជា** ជួញដូរគ្រឿងសាស្ត្រាវុធ

**២.សត្តវណិជ្ជា** ជួញដូរមនុស្ស

**៣. មំសវណិជ្ជា** ជួញដូរសត្វដែលគេត្រូវសម្លាប់

**៤. មជ្ជវណិជ្ជា** ជួញដូរគ្រឿងស្រវឹង

**៥. វិសវណិជ្ជា** ជួញដូរគ្រឿងពុលសម្លាប់សត្វ។

**សម្មាវាយាមោ** ព្យាយាមត្រូវ គឺព្យាយាមអប់រំចិត្តក្នុងគោលធម៌ទាំង ៤ យ៉ាងគឺៈ

**១.សំវរប្បធាន** ព្យាយាមប្រយ័ត្ន មិនឱ្យបាបកើតឡើង

**២. បហានប្បធាន** ព្យាយាមលះបាប ដែលកើតឡើងហើយ មិនឱ្យកើតមានទៅទៀតបាន

**៣. ភាវនាបធាន** ព្យាយាមញ៉ាំងកុសលឱ្យកើតឡើងក្នុងសន្តាន

**៤. អនុរក្ខនាបធាន** ព្យាយាមរក្សាកុសលធម៌ ដែលធ្លាប់បានធ្វើហើយកាលពីមុន មិនឱ្យសាបសូន្យទៅវិញ។

**សម្មាសតិ** រឭកត្រឹមត្រូវ គឺរឭកក្នុងសតិប្បដ្ឋាន ៤ យ៉ាងគឺៈ

**១.កាយានុបស្សនាតិប្បដ្ឋាន** រឭករឿយៗដល់កាយឱ្យឃើញថា គ្រាន់តែជាកាយប៉ុណ្ណោះ។

**២.វេទនានុបស្សនាសតិប្បដ្ឋាន** រឭករឿយៗដល់វេទនាឱ្យឃើញថា គ្រាន់តែជាវេទនាប៉ុណ្ណោះ

**៣.ចិត្តានុបស្សនាសតិប្បដ្ឋាន** រឭករឿយៗដល់ចិត្តឱ្យឃើញថា គ្រាន់តែជាចិត្តប៉ុណ្ណោះ។

**៤.ធម្មានុបស្សនាសតិប្បដ្ឋាន** រឭករឿយៗដល់ធម៌ ឱ្យឃើញថា គ្រាន់តែជាធម៌ប៉ុណ្ណោះ។

**សម្មាសមាធិ** តម្កល់ចិត្តត្រូវ គឺចិត្តដែលតាំងមាំល្អ ក្នុងកុសលធម៌ មិនប្រព្រឹត្តទៅក្នុងនីវរណធម៌។

ផ្លូវទាំង ៨ ប្រការនេះ ឈ្មោះថា អរិយមគ្គ ព្រោះជាផ្លូវដ៏ប្រសើរ ជាផ្លូវត្រង់ ផ្លូវមិនមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់មនុស្ស សត្វទូទៅ ម្យ៉ាងទៀតជាផ្លូវមិនមានភ័យ ព្រោះកម្ចាត់បង់នូវកិលេសជាគ្រឿងឱ្យភ័យដល់សត្វលោកជាផ្លូវដ៏ត្រជាក់ ព្រោះរម្ងាប់បង់នូវកិលេស ដែលជាគ្រឿងដុតរោលឱ្យក្តៅក្រហាយ។

## ធម៌អាស្រ័យគ្នា

ព្រៃភ្នំក្រមថ្មលំនៅបក្សី ផ្ទះថ្មឡានថ្មីលំនៅអ្នកមាន
ផ្ទះស្បូវខ្ទមតូចដែលសង់កៀនៗ អ្នកក្រអត់ឃ្លានរស់យ៉ាងហ្នឹងហើយ។
ទឹកជ្រៅសែនថ្លាលំនៅពួកត្រី អារាមចាស់ថ្មីទីអ្នករកត្រើយ
គ្រែមុងកន្ទេលតុទុពូកខ្នើយ លំនៅអ្នកកើយជាគុកអ្នកដេក។
បាបកម្មទាំងឡាយព្រោះធ្វើអាក្រក់ លើក្បាលគ្មានសក់ព្រោះតែទំពេក
មើលអ្វីមិនឃើញព្រោះបញ្ហាភ្នែក ខិតខំពុនរែកព្រោះប្រាថ្នាទ្រព្យ។
មាគ៌ាទាំងឡាយសម្រាប់ទៅមក សប្បាយរីករាយព្រោះចិត្តនៅជាប់
ធ្វើអ្វីតគ្នាព្រោះតាមទម្លាប់ ទាស់ចិត្តឬគាប់ជារឿងស្រឡាញ់។
ការកើតហើយស្លាប់ជារឿងសង្ខារ ប្រកួតតវ៉ាព្រោះចង់ឈ្នះចាញ់
មិនហ៊ានធ្វើទានព្រោះចិត្តកំណាញ់ ចង់សុទ្ធចំរាញ់ទើបល្អឥតហ្មង។
អ្នកលក់ទាំងឡាយចង់បានចំណេញ ឯអ្នកទិញវិញតថ្លៃឆ្លើយឆ្លង
គឺចង់បានថោកទើបស្តីសារសង តពីរបីដងព្រោះមិនត្រូវគ្នា
ចង់បានចំណេះត្រូវតែសិក្សា ចង់ផុតទុក្ខាត្រូវស្តាប់ធម្មា

កងធម៌ទាំងឡាយនៃព្រះភគវា គឺអាស្រ័យគ្នារៀនស្ដាប់ចុះណ៎ា។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ១០.ថ្នាំរក្សាផ្លូវចិត្ត

ពេលដែលមនុស្សយើងកើតមក តែងតែជួបនូវឧបសគ្គគ្រប់បែបយ៉ាងទាំងអស់នេះ យើងមិនអាចជៀសផុតបានឡើយ មិនថាគេចទៅនៅទីណាទេ ទាំងនេះមកអំពីចិត្តបិសាច ដែលជាប់តាមខ្លួន ពោលគឺលោភៈ ទោសៈ មោហៈ ជាប្រធាននៃសេចក្តីអាក្រក់ពិសពុលជាងអ្វីៗទាំងអស់។

សូម្បីតែចង់គេច ឱ្យផុតអំពីសេចក្តីទុក្ខលំបាកនោះ ក៏មិនងាយដែរ ដោយសារតែរកដំណោះស្រាយ គេចឱ្យផុតមិនបាន ប្រសិនបើមានដំណោះស្រាយវិញ រមែងដោះស្រាយបានត្រឹមតែធ្វើឱ្យជីវិតយើងនឹងបានសុខត្រឹមតែមួយខណៈតែប៉ុណ្ណោះ មិនថាអ្នកជំនាញដោះស្រាយបញ្ហាយ៉ាងណានោះទេ គឺមិនអាចដោះស្រាយបានឡើយ បើមានវិធីដោះស្រាយវិញ ដោះស្រាយបានតែមួយជ្រុងតែប៉ុណ្ណោះ។ ចង់និយាយក្នុងទីនេះ ប្រាប់អ្នកអានឱ្យបានដឹងថា ទុកតែខំប្រឹងយ៉ាងណា ក៏មិនអាចដោះស្រាយ ឱ្យផុតពីសេចក្តីស្លាប់នេះបានដែរ សមដូចគាថាព្រះអង្គសម្តែងថា:

**ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា**
**អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា។**

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ។

**យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ**
**ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ**
**សព្វំ ភេទបរិយន្តំ ឯវំ មច្ចាន ជីវិតំ។**

ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណាមិញជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ។

បើមនុស្សយើងបានដឹងអំពី ដំណើរនៃការប្រព្រឹត្តរបស់សង្ខារធម៌ ហើយមិនប្រកាន់ខ្ជាប់ជាមួយតួខ្លួន ដែលកំពុងតែមានមេរោគ គឺសេចក្តីអាក្រក់ជាប់មកតាមខ្លួនរបស់យើងនោះ ត្រូវយកធម៌មកពិចារណាមួយកន្លែង ដើម្បីការពារនូវសត្រូវរបស់ខ្លួន ឬជាប្រដាប់ការពារដើម្បីទប់ទល់ជាមួយនឹងគ្រោះកំណាចរបស់ចិត្តគំនិត ដែលយើងបានគិតថាជារឿងធំនោះ។

ម្យ៉ាងវិញទៀត រឿងដែលកើតចំពោះមុខយើងបច្ចុប្បន្ននេះ វាមិនមែនកើត មកពីណាក្រៅអំពីខ្លួនរបស់យើងនោះទេ ដែលយើងគិតថាមានគេជាសត្រូវរបស់យើង មានអ្នកដទៃជាមនុស្សដែលគួរឱ្យស្អប់ គួរឱ្យខ្ពើមរអើមនោះទេ។ តែរឿងទាំងអស់នេះ បើយើងមិនបានគិតពិចារណាទេ វារមែងនាំមកនូវសត្រូវរបស់យើងរហូត ដូចមានរឿងរ៉ាវកាលពីសម័យពុទ្ធកាល នាងឧត្តរាឧបាសិកា មានចិត្ត ប្រសើរដ៏ខ្ពស់ក្នុងការឱ្យអភ័យ ចំពោះអ្នកដែលប្រទូស្តនឹងខ្លួន នាងជាអរិយ
សាវិកា និងជាកំពូលលើឧបាសិកាទាំងឡាយ ផ្នែកខាងការចូលឈាន។

នៅក្នុងអដ្ឋកថាធម្មបទ កោធវគ្គ បានសម្តែងប្រវត្តិរបស់នាង ដែលមានចំណុចល្អគួរឱ្យកត់សម្គាល់:

នាងជាធីតារបស់បុណ្ណសេដ្ឋីក្រុងរាជគ្រឹះ ជាស្ត្រីមានបុណ្យបានធ្វើទុកមកដ៏ច្រើន គិតតាំងពីក្នុងសាសនាព្រះសម្មាសម្ពុទ្ធបទុមុត្តរៈមក។

នាងបានស្វាមីមិច្ឆាទិដ្ឋិ ហើយនាងទៅនៅត្រកូលខាងប្តីក្នុងថ្ងៃ ១៥ កើត ខែអាសាឍ។ កន្លងទៅពីរខែកន្លះក្នុងវស្សានោះនាងពុំបានថ្វាយទាន ពុំបានស្តាប់ធម៌ឡើយ។ ដើម្បីដោះស្រាយបញ្ហាឱ្យកូនស្រី បុណ្ណសេដ្ឋី បានឱ្យប្រាក់មកជួលនាងសិរិមា ជាស្រីសោភិនីប្រចាំក្រុងរាជគ្រឹះក្នុងតម្លៃ

១៥.០០០ កហាបណៈ សម្រាប់កន្លះខែប៉ុណ្ណោះ យកមកឱ្យបម្រើប្តីរបស់នាង។ កាលដែលប្តីព្រមទទួលយកនាងសិរិមាហើយ ខ្លួនឯងដូចបានរួចពីទីឃុំឃាំង ឬពុំនោះសោត ដូចបានរួចពីទាសីគេ ហើយបាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាព្រះប្រធាន ១៥ ថ្ងៃថ្វាយចង្ហាន់បិណ្ឌបាត។

នាងសិរិមា បានមកនៅក្នុងផ្ទះកន្លះខែ វង្វេងភ្លេចខ្លួន គិតថាខ្លួនឯងជាស្ត្រីក្នុងផ្ទះ ហើយបានប្រច័ណ្ឌជាមួយនឹងនាងឧត្តរា ឧបាសិកា។

នាងសិរិមាបានប្រទូស្តនឹងនាងឧត្តរា ដោយការយកវែកធំដងទឹកដោះ ដែលកំពុងដាំពុះ ទៅចាក់លើនាងប៉ុន្តែនាងឧត្តរាបានផ្សាយមេត្តា ចិត្តទៅរកនាងសិរិមាទាន់ពេល។ នាងឧត្តរាបានគិតថា (ព្រោះអាស្រ័យនាងទើប យើងបានថ្វាយទាន សមាទានឧបោសថ និងបានស្តាប់ធម៌...)។ ដោយមេត្តានុភាពពិតៗ ទឹកដោះក្តៅនោះ ពុំបានរលាកនាងឡើយ ហាក់ដូចជាទឹកត្រជាក់។

នាងសិរិមាភ្ញាក់ខ្លួនហើយ បានសូមខមាទោសនឹងនាងឧត្តរា។ នាងឧត្តរាមានបំណងល្អ ចង់ឱ្យនាងសិរិមាបានគាល់ព្រះបរមសាស្តា ទើបឱ្យនាងទៅថ្វាយបង្គំព្រះអង្គ សូមព្រះអង្គទ្រង់អត់ទោសឱ្យដោយនាងឧត្តរាបញ្ជាក់ប្រាប់នាងសិរិមាថា (ព្រោះអាស្រ័យនាង ទើបយើងបានថ្វាយទានសមាទានឧបោសថ និងស្តាប់ធម៌...)។

នាងសិរិមាភ្ញាក់ខ្លួនហើយ បានសូមខមាទោសនឹងនាងឧត្តរា។ នាងឧត្តរាមានបំណងល្អ ចង់ឱ្យនាងសិរិមាបានគាល់ព្រះបរមសាស្តា ទើបឱ្យនាងទៅថ្វាយបង្គំព្រះអង្គ សូមព្រះអង្គទ្រង់អត់ទោសឱ្យដោយនាងឧត្តរាបញ្ជាក់ប្រាប់នាងសិរិមាថា (ខ្ញុំជាធីតាដែលមានបិតា បិតាវិវដ្តៈរបស់ខ្ញុំ គឺព្រះសម្មាសម្ពុទ្ធ កាលបើព្រះបិតាអត់ទោសឱ្យជាការស្រេច)។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សរសើរនាងឧត្តរាឧបាសិកាថា (សាធុ! សាធុ! ឧត្តរា ការឈ្នះសេចក្ដីក្រោធយ៉ាងនោះ ជាការសមគួរណាស់)។ រួចហើយព្រះអង្គទ្រង់ត្រាស់នូវព្រះគាថាៈ

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ។**

គប្បីឈ្នះមនុស្សក្រោធ ដោយការមិនក្រោធ គប្បីឈ្នះមនុស្សមិនល្អ ដោយសេចក្ដីល្អ គប្បីឈ្នះមនុស្សកំណាញ់ ដោយការឱ្យទាន គប្បីឈ្នះមនុស្សនិយាយទ្បេះទ្បោះដោយពាក្យពិត។ នាងសិរិមាបានសម្រេចសោតាបត្តិផល ដោយព្រះធម៌ទេសនានេះឯង។

## ប្រញាប់ធ្វើបុណ្យ

ហៃអស់ប្រុសស្រីជាទីស្នេហា ចូរខំឧស្សាហ៍ធ្វើបុណ្យដាក់ទាន
កុំខ្ជិលច្រអូសនាំអន្តរធាន ហើយចូរសាងស្ពានទៅកាន់ទីសុខ។
អ្នកកុំធ្វើបាបមានចិត្តឃោរឃៅ ស្ដាប់ធម៌រកផ្លូវបញ្ញាស្មាញស្មុគ

លះបាបធ្វើបុណ្យខិតខំសម្រុក ព្យាយាមរកសុខកុំបីខកខាន។
យប់ហើយនិងថ្ងៃកុំដាក់ភារៈ ខិតខំទម្លាក់មានះសាមាន្យ
កុំតម្កើងខ្លួននាំតែខកប្រាណ ស្លាប់ទៅថ្មើរម៉ានធ្លាក់អបាយជ្រៅ។
បុណ្យទានទាំងឡាយមិនភ្លេចអ្នកទេ ចូរអ្នករិះរេខំធ្វើទៀតទៅ
សម្អាតចិត្តខ្មៅធ្លាប់កាចអាស្រូវ គួរកែតម្រូវរកបុណ្យកុសល។
ប្រញាប់ធ្វើបុណ្យទុកស្រេចឱ្យហើយ ទើបជីវិតស្បើយបានច្បាស់មគ្គផល
បានឃើញសច្ចៈគឺផុតកង្វល់ នឹងបានចូលដល់ទីសុខក្សេមក្សាន្ត។
សូមមហាកុសលកើតមានដល់អ្នក កុំជាប់ជំពាក់បាបកម្មប៉ុន្មាន
កើតជាតិណាៗជួបព្រះកុំខាន គឺឆ្លងផុតស្ពានដល់និព្វានហោង។

**ដោយសាមណេរ សា ចាន់រ៉ាត់**

## ១១.ជុំវិញរឿងព្រះនិព្វាន

បើមានពាក្យអះអាងថា (មិនមានទេ ព្រះនិព្វាននោះ ព្រោះមិនមែនវត្ថុដែលគប្បីរកបាន ដូចស្នែងទន្សាយដូច្នោះ) យ៉ាងនេះ ចម្លើយគប្បីមាន ថា ព្រះនិព្វានមិនមាន ក៏មិនមែន ព្រោះព្រះនិព្វាននោះ ជាធម្មជាតិ ដែលគប្បី

រកបានដោយឧបាយ ពិតហើយ ព្រះនិព្វាននោះរមែងរកបានដោយ ឧបាយ ពោលគឺការបដិបត្តិ ដែលសមគួរដល់ព្រះនិព្វាននោះ ដូចលោកុត្តរចិត្តរបស់បុគ្គលដទៃៗ ព្រះអរិយៈរមែងដឹងបានដោយចេតោបរិយញ្ញាណ ដូច្នោះ ព្រោះហេតុនោះ (មិនគួរពោលថា ព្រះនិព្វានមិនមាន ព្រោះមិនមែនវត្ថុដែលគប្បីបាន) ដែលថាបុថុជ្ជនល្ងង់ខ្លៅ (មិនបានប្រសព្វវត្ថុណា ក៏ថាវត្ថុនោះមិនមាន) ដូច្នេះមិនគួរ ព្រោះអ្នកបានប្រសព្វមានហើយ។

ម្យ៉ាងទៀត មិនគួរពោលថា ព្រះនិព្វានមិនមាន ព្រោះហេតុអ្វី ព្រោះមិនជាមោឃៈនៃការបដិបត្តិពិតហើយ បើព្រះនិព្វានមិនមានការ បដិបត្តិត្រូវដែលសង្គ្រោះក្នុងខន្ធ ៣ មាន សីលក្ខន្ធជាដើម ដែលមាន សម្មាទិដ្ឋិជាប្រមុខ ក៏ត្រូវជាមោឃៈតែថា ការបដិបត្តិត្រូវនេះមិនជាមោឃៈ ព្រោះជាហេតុឱ្យដល់ព្រះនិព្វានបាន។

បើមានពាក្យជំទាស់ថា ការមិនជាមោឃៈ នៃការបដិបត្តិនោះ មិនមានទេ ព្រោះការបដិបត្តិនោះ ជាហេតុឱ្យការដល់មិនមាន ដូច្នេះសោត ពាក្យឆ្លើយគប្បីមានថា ការមិនមានជាព្រះនិព្វានក៏មិនមែន ព្រោះមិនមានការសម្រេចព្រះនិព្វានណាដោយសារមិនមានខន្ធអតីត និងអនាគត (ទោះមិនមានខន្ធអតីត អនាគត ក៏គង់សម្រេចព្រះនិព្វានបានដែរ)។

បើជំទាស់ទៀតថា មិនមែនតែខន្ធអតីត អនាគតនោះ ប៉ុណ្ណោះទេ សូម្បីការមិនវត្តមានខន្ធ គឺខន្ធបច្ចុប្បន្នទាំងឡាយ ក៏ជានិព្វានដែរ ដូច្នេះសោតគប្បីឆ្លើយថា មិនត្រូវព្រោះព្រះនិព្វានមាន មិនមែនដោយសារការមិនមានខន្ធទាំងឡាយនោះទេ» ម្យ៉ាងទៀត ព្រោះការវត្តមានខន្ធមិនមានព្រះនិព្វានក៏ដល់នូវការមិនមានដែរឬ មិនមែនមានវត្តមានខន្ធ ហើយព្រះនិព្វានមិនមាននោះទេ និងទោស គឺការមិនសម្រេចសឧបាទិសេសនិព្វាន

ធាតុ ក្នុងខណៈនៃមគ្គចិត្ត ក៏អាស្រ័យវត្ថុមានខន្ធដែរ (គឺថាក្នុងខណៈនៃមគ្គនឹងសម្រេចនិព្វានមិនបាន)។

បើជំទាស់ទៀតថា ទោសមិនមាន ព្រោះក្នុងខណៈនៃមគ្គនោះ កិលេសទាំងឡាយក៏មិនប្រព្រឹត្តទៅ ដូច្នេះសោត គប្បីឆ្លើយថា មិនបាន ព្រោះបើក្នុងខណៈនៃមគ្គ កិលេសមិនប្រព្រឹត្តទៅ អរិយមគ្គក៏គ្មានប្រយោជន៍ពិតហើយ កាលបើយ៉ាងនោះ កិលេសទាំងឡាយ មិនមានមកតាំងពីមុនខណៈនៃអរិយមគ្គ ព្រោះដូច្នោះអរិយមគ្គក៏គ្មានប្រយោជន៍។

ព្រោះហេតុដូចដែលពោលមកនោះ ប្រការដែលថាព្រះនិព្វានមិនមាន ព្រោះជាវត្ថុដែលគ្មានដូចស្នែងទន្សាយ និងថាការបដិបត្តិមិនជាមោឃៈ ព្រោះការបដិបត្តិនោះ ជាហេតុឱ្យដល់នូវការមិនមាន និងថាទោសគឺការសម្រេចព្រះនិព្វាន ក្នុងខណៈនៃមគ្គមិនបាននោះ មិនមានព្រោះក្នុងខណៈនៃអរិយមគ្គ កិលេសមិនប្រព្រឹត្តទៅហើយនោះ ទើបមិនមែនជាហេតុ គឺមិនត្រូវតាមហេតុ។

បើមានពាក្យជំទាស់ទៀតថា **ខយោ** ការអស់ទៅជានិព្វាន ដោយបាលីថា **យោ ខោ អាវុសោ រាគក្ខយោ** ម្នាលអាវុសោ ការអស់ទៅនៃរាគៈណាជាដើម ដូច្នេះសោត គប្បីឆ្លើយថា ព្រោះព្រះអរហត្តនោះ ទ្រង់សម្ដែងទុកដោយន័យថា **យោ ខោ អាវុសោ រាគក្ខយោ** ជាដើមដូចគ្នានៅមានអ្វីខុសទៀត គឺព្រះនិព្វានក្លាយជា ធម្មជាតិមានកាលវេលា ដែលខ្លីជាធម្មជាតិមានលក្ខណៈនៃសង្ខតធម៌ ព្រោះជាធម្មជាតិដែលសម្រេចបានដែលមិនគិតដល់សម្មាវាយាមៈទៅ ហើយ ឬម្យ៉ាងទៀត ព្រោះជាធម្មជាតិដែលមានលក្ខណៈ ជាសង្ខតធម៌ នោះ ព្រះនិព្វានក៏ដល់នូវភាវៈជាធម្មជាតិរាប់បញ្ចូលក្នុងសង្ខត ធម៌នោះឯង ក៏ដល់នូវភាវៈជាធម្មជាតិដែលត្រូវភ្លើង

មានរាគៈជាដើម ដុតរោលបាន កាលបើជាធម្មជាតិត្រូវដុត ក៏ដល់នូវភាវៈជាទុក្ខទៅហើយ។

បើមានពាក្យជំទាស់ទៀតថា « ទោសមិនមាន ព្រោះការប្រព្រឹត្តទៅ (នៃកិលេស) ឈ្មោះថា មិនមានតទៅទៀត ចាប់តាំងពីការអស់ (គ្រាចុងក្រោយ) ការអស់នោះជានិព្វាន» ដូច្នេះសោត គប្បីមានការអស់នោះ ក៏មិនកន្លងទោសមានប្រការដូចដែលពោលហើយ និងព្រោះអរិយមគ្គក្លាយ ជាព្រះនិព្វានទៅហើយ ពិតហើយ អរិយមគ្គ រមែងញ៉ាំងទោសទាំងឡាយ ឱ្យអស់ទៅ ព្រោះដូច្នោះ ទ្រង់ទើបហៅថា **ខយោ** ហើយបន្ទាប់ពីនោះទៅការប្រព្រឹត្តទៅ (នៃទោស) មិនមានទៀតឡើយ តែថាព្រោះព្រះនិព្វាននោះ ជាឧបនិស្ស័យ (ជាទីអាស្រ័យ) ដោយបរិយាយនៃ **ខយ** គឺមគ្គ បានដល់អនុប្បត្តិរោធ និរោធ គឺការមិនកើតឡើង ព្រះនិព្វាននោះ ទើបទ្រង់ ហៅថា ខយោ គឺជាឧបចារវោហារ (ទាក់ទងគ្នា) និងវត្ថុដែលមានព្រះនិព្វានជាឧបនិស្ស័យ។ បើមានពាក្យសួរថា «ព្រោះហេតុអ្វី ព្រះនិព្វាននោះ ព្រះមានព្រះភាគត្រាស់ទុកដោយសរុបតែមួយ? ដូច្នេះនោះ គប្បីឆ្លើយថា ព្រះនិព្វានជាធម៌ល្អិតសុខុម ការដែលព្រះនិព្វាននោះជធម៌ល្អិតសុខុម ជាការសម្រេចទូទៅ (ប្រាកដទូទៅ) ហើយ ព្រោះជាហេតុនាំមកនូវភាពជាអ្នកខ្វល់ខ្វាយតិចនៃព្រះមានព្រះភាគជាម្ចាស់ និងព្រោះជាធម៌ដែលត្រូវ ឃើញដោយអរិយចក្ខុ ព្រោះហេតុនោះ ព្រះនិព្វាននោះ ជាធម៌មិនទូទៅ ព្រោះជាធម៌ដែលបុគ្គលព្រមព្រៀងដោយ មគ្គទើបបានដល់ជាធម៌មិនមាន ដែនកើត ព្រោះមិនមានខាងដើមខាងចុង។

បើមានពាក្យជំទាស់ថា ព្រះនិព្វាន មិនមែនជាធម៌មិនមានកើត ព្រោះលុះត្រាតែមានមគ្គ ទើបសម្រេចបាន ដូច្នេះសោត គប្បីឆ្លើយថា មិន

ត្រូវ ព្រោះនិព្វានមិនមែនជាធម៌ដែលមគ្គគប្បីឱ្យកើតឡើងនោះ ឡើយ ការពិតព្រះនិព្វាននោះ ជាធម៌ដែលបុគ្គលអាចបានដោយមគ្គប៉ុណ្ណោះ មិនមែនមគ្គឱ្យកើតឡើយនោះទេ ព្រោះដូច្នោះ ព្រះនិព្វាននោះ ទើបឈ្មោះ ថាមិនមានដែនកើត ដោយសារមិនមានដែនកើតទើបមិនមានជរា មរណៈ ព្រោះមិនមានដើនកើត និងជរា មរណៈ ទើបទៀង។

បើមានពាក្យសួរទៀតថា កាលបើអណូជាដើម ដល់នូវភាវៈទៀងដូចព្រះនិព្វាន ដូច្នេះសោត គប្បីឆ្លើយថា អណូជាដើមនោះ ឈ្មោះថាទៀង មិនបាន ព្រោះមិនមានហេតុ (ឱ្យចូលដល់)។ បើមានពាក្យសួរទៀតថាព្រះនិព្វានទៀង វត្ថុទាំងនោះក៏ទៀង ដូច្នេះសោត គប្បីឆ្លើយថា មិនបាន ព្រោះវត្ថុទាំងអស់នោះ មិនចូលក្នុងលក្ខណៈនៃហេតុ (ដែលជរាធម៌គួរប្រាថ្នាបានជាដើម)។ បើមានពាក្យសួរថា វត្ថុទាំងឡាយនោះ ចាត់ថាទៀង ព្រោះមិនមានហេតុឱ្យកើតឡើងជាដើម ដូចព្រះនិព្វាន ដូច្នេះសោតគប្បីឆ្លើយថា មិនបាន ព្រោះអណូជាដើមមិនសម្រិតផល(មិនបរិសុទ្ធ)។

ព្រះនិព្វាននោះប៉ុណ្ណោះ ទៀតពិតព្រោះមានសភាវៈ គឺការពាល់ត្រូវ (ដោយហេតុផល) ដូចពោលមកហើយ ជាអរូប ព្រោះកន្លងនូវសភាវៈនៃរូប (មានការវិនាសជាដើម) មិនមែនជាវត្ថុដែលមិនមានដោយបរមត្ថ ព្រោះជាវត្ថុ ដែលគប្បីសម្រេចបានដោយញាណពិសេស សម្រេចដោយការព្យាយាម ដែលមិនធូរថយ ព្រោះជាព្រះតម្រាស់របស់ព្រះសព្វញ្ញូជាម្ចាស់ពិត ហើយព្រះសព្វញ្ញូជាម្ចាស់បានត្រាស់ពាក្យនេះទុកថា ម្នាលភិក្ខុទាំងឡាយធម្មជាតិ ដែលមិនកើត មិនមានហេតុណាៗ ធ្វើឱ្យកើតឡើង ដែលបច្ច័យទាំងឡាយ មិនបានតាក់តែងឡើង នេះជាពាក្យវិនិច្ឆ័យយ៉ាងសំខាន់ក្នុងទុក្ខនិរោធនិទ្ទេស ។

(ចាកក្នុងសៀវភៅ សតិប្បដ្ឋានភាវនា ព្រះពុទ្ធដីកា)

# អ្នកកុំជាប់ស្អិតនឹងលោកធម៌

ឆាកល្ខោនជីវិតក្លែងបន្លំ ទុក្ខសោកក្រៀមក្រំជូនសប្បាយ
ជូនក្រជូនមានឥតរសាយ គួរខ្ពើមជិនណាយណាស់លោកិយ។
លោកធម៌ព្រះពុទ្ធទ្រង់សម្តែង វិលវល់ដូចផ្សែងមានប្រាំបី
សុខទុក្ខនិន្ទាសរសើរក្តី លាភយសគ្មានន័យឥតខ្លឹមសារ។

ឥតលាភឥតយសរឿងមិនទៀង ជួនរាំងជួនភ្លៀងប្រាំងវស្សា
ជួបព្រាត់គឺជាអនត្តា គ្មានសត្វលោកណាឋិតថេរឡើយ។
រស់គ្មានធម៌ដូចផ្គរគ្មានភ្លៀង គិតថាអ្វីទៀងខំកៀកកើយ
អាងលាភអាងយសឫកតោះតើយ មិនស្តាប់ធម៌ឡើយចិត្តរឹងត្អឹង។
មួយថ្ងៃៗរវល់ណាស់ ភ្លេចគិតខ្លួនចាស់ហើយទេដឹង
ញៀននឹងបានទ្រព្យខិតខំប្រឹង កំណាញ់ដល់ឆ្អឹងមិនធ្វើទាន។
អ្នកកុំជាប់ស្អិតនឹងលោកធម៌ ប្រៀបដូចជាប់ជ័រលង់វិញ្ញាណ
មិនចេះគ្រប់ឡើយរឹតចង់មាន គឺសែនអត់ឃ្លានពេលស្លាប់ទៅ។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## ១២.សូមឱ្យមានធម៌ទាំង ៤ យ៉ាងនេះគ្រប់ៗគ្នា

ការរស់នៅ ត្រូវតែប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ កុំបីខានគឺៈ

**ទី ១ មេត្តា** សេចក្តីស្រឡាញ់ប្រាថ្នាឱ្យគេបានសុខ

**ទី ២ ករុណា** សេចក្តីអាណិតគិតជួយឱ្យគេរួចចាកទុក្ខ

**ទី ៣ មុទិតា** សេចក្តីត្រេកអរតាមក្នុងពេលវេលា ដែលគេបានល្អ

**ទី ៤ ឧបេក្ខា** សេចក្ដីតាំងចិត្តជាកណ្ដាល មិនឱ្យមានសោមនស្ស និងទោមនស្សក្នុងវេលា ដែលគេមានសេចក្ដីវិបត្តិ។

១.មនុស្សយើងកាលណាបើមិនបាន សិក្សារៀនសូត្រនូវព្រះធម៌ របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីធ្វើការអប់រំចិត្តនោះទេ គឺមានការច្រណែនគ្នា គ្រាន់តែឃើញគេធ្វើល្អ ក៏មិនចេះត្រេកអរក្នុងសេចក្ដីល្អរបស់អ្នកដទៃដែរ ដូច្នេះ មេត្តាធម៌ឮព្រះសម្មាសម្ពុទ្ធព្រះអង្គបានសម្ដែងឱ្យមនុស្សយើងចេះ ត្រេកអរក្នុងអំពើល្អរបស់អ្នកដទៃ។

២.នៅក្នុងធម៌ករុណានេះ ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់ សម្ដែងឱ្យមនុស្សយើងចេះអាណិតដល់អ្នកដទៃ ហើយចេះត្រេកអរក្នុង សេចក្ដីល្អរបស់អ្នកដទៃ ហើយមានការប្រាថ្នាឱ្យគេបាននូវសេចក្ដីសុខ បើ គេមានទុក្ខ ប្រាថ្នាឱ្យគេរួចផុតអំពីសេចក្ដីទុក្ខនោះ។

៣.ពេលដែលបានធ្វើអ្វីមួយជាមួយអ្នកដទៃ ប្រកបដោយកុសលធម៌ ដូចជាមានការចិញ្ចឹមបីបាច់ ថែរក្សា បង្ហាត់បង្រៀនប្រៀនប្រដៅដូចជា មាតាបិតា ដែលបានបរិច្ចាគទានជាច្រើន មិនចង់បានអ្វីអំពីកូនឡើយ មាន តែការ សប្បាយរីករាយ និងការត្រេកអរតាមជារៀងរហូត តែបើផ្ទុយ មក វិញមានការជួយអ្នកដទៃហើយ តែចង់បានការតបស្នងសងគុណ មក លើ ខ្លួនវិញនោះ មិនអាចមានឈ្មោះថាជាមុទិតាឡើយ។

៤.ធម្មតាមនុស្សយើងបានសាងនូវផលប្រយោជន៍ សម្រាប់ការពារ ខ្លួនរបស់យើងនោះ រមែងមានការលំបាកលំបិនខ្លាំងណាស់ បើសិនជា យើងបានធ្វើប្រយោជន៍ជាផលបុណ្យ តែមានការមិនបានសម្រេចដូច ប្រាថ្នានោះ រមែងក្ដៅក្រហាយជាមិនខានដូចជាឧបេក្ខាជាដើម ការតាំងចិត្ត ជា កណ្ដាលមិនងាយនឹងធ្វើបានទេ ប្រសិនបើយើងមិនបានពិចារណា ទៅ

តាមធម៌នោះទេ ការចង់ជួយឱ្យគេបានសេចក្តីសុខ ចង់ឱ្យគេមាន ចង់ឱ្យគេដូចយើង ទាំងនេះហើយបើគេធ្វើមិនដូចជា អ្វីដែលយើងប្រាថ្នាទេនោះ អ្នកខ្លះខូចចិត្តដោយសារតែរំពឹងចង់បានឱ្យគេតបស្នង ទាំងនេះហើយបាន ជាឧបេក្ខានេះមានចិត្តជាកណ្តាលៗ ពេលគេមិនដឹងគុណក៏មិនក្រវល់ ក្រវាយចិត្ត គេមិនធ្វើតាមយើងមិនបញ្ហាឡើយ។ នេះគឺមានទាំងអស់នៅ ក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធទាំងស្រុង តែសូមពិចារណាផង គឺមាន ចិត្តជាកណ្តាលកន្លែងនេះត្រូវពិចារណាដោយបញ្ញា។

## ១៣.ឆាកល្ខោនជីវិត

រឿងជីវិតដែលយើងបានដឹងក្នុងការរស់នៅបច្ចុប្បន្ននេះ វារមែងកើតឡើងហើយមានការសម្តែងនូវរឿងជីវិត ឆ្លុះបញ្ចាំងឱ្យយើងដឹងរឿងពិតដែលមានការលំបាកលំបិន ធ្វើឱ្យមនុស្សយើងមានសេចក្តីតស៊ូ ពុះពារ ធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីតម្រូវការរបស់ខ្លួនឯង ទាំងនេះហើយបានជាលើកយកមកជាប្រធានបទក្នុងការពិចារណា។

ពេលវេលាចេះតែកន្លងទៅមិនងាយនឹងបុគ្គលណា អាចដឹងអំពីជីវិតដែលមានសព្វថ្ងៃនេះ មិនងាយនរណាម្នាក់អាចដឹងបានទេពេលណាដែលយើងបានពិចារណារឿងរ៉ាវអំពីជីវិត ធ្វើឱ្យចិត្តបានសុខស្ងប់។

ពេលនោះងាយស្រួល សម្រាប់ជីវិតដែលត្រូវដើរតួសម្ដែងក្នុងឆាកជីវិតនេះ។

## ឆាកល្ខោនជីវិត

រឿងភាគសម្ដែងបង្ហាញឈុតឆាក សប្បាយលំបាកជួបព្រាត់រីងរៃ
ស្រេចលើអ្នកតែងលៃលកបំភ្លៃ រៀបចំអត្ថន័យហាក់ដូចរឿងពិត។
រឿងខ្លះសម្ដែងកម្សត់អន់ក្រ រស់ទាំងត្រដរព្រាត់ប្រាសស្នេហ៍ស្និទ្ធ
ខ្លះជាសេដ្ឋីជាស្ដេចយ៉ាងពិត ខ្លះក៏ជាមិត្តខ្លះបម្រើគេ។
ក្នុងរឿងមួយៗតែងមានវែងខ្លី មានប្រុសមានស្រីច្រើនគ្រប់កាំភ្លេ
ខ្លះដើរតួកាចត្រូវបានគេជេរ តួស្លូតទំនេរគេតែងអាណិត។
ឯអ្នកខ្លះទៀតឆ្លៀតដើរតួក្បត់ ខ្លះធ្វើកម្សត់ខំច្នៃប្រឌិត
ធ្វើក្លែងក្លាយសោះហាក់ដូចជាពិត អ្នកមើលខ្លោចចិត្តអ្នកខ្លះសោកា។
តួអ្នកសម្ដែងគេដឹងទាំងអស់ មិនមានចន្លោះយល់សព្វកិច្ចការ
ព្រោះមានអ្នកប្រាប់អ្នកតែងស្ដីថា សាកសមអស្ចារ្យដូចរឿងពិតៗ។
នេះគឺរឿងល្ខោនដែលគេតាក់តែង ហើយរៀបសម្ដែងប្រាប់ពីជីវិត
ត្រៀមហើយដើរតួមើលទៅជិតស្និទ្ធ ខ្លះគេឱបរឹតយ៉ាងសមសោភា។
យ៉ាងណាជីវិតទាំងអស់ប្រុសស្រី កើតក្នុងលោកិយក៏មានដូចគ្នា

មានជួបមានព្រាត់ខ្លះក៏កំព្រា លំបាកវេទនាគ្មានដែលលោះថ្ងៃ។
រឿងរ៉ាវឧបសគ្គមានគ្រប់កន្លែង វិលវល់ដូចផ្សេងទុក្ខសោកពេកក្រៃ
ទឹកភ្នែកស្រក់ហូរគ្មានដែលសំចៃ ឧបទ្រព្យចង្រៃគ្មានស្រាកម្តងណា។
នេះគឺបញ្ចក្ខន្ធនៃយើងគ្រប់ប្រាណ មិនយូរប៉ុន្មានត្រូវចោលឥតការ
រស់នៅសុខៗត្រូវស្លាប់មរណា ចោលស្រែចម្ការផ្ទះប្រពន្ធប្តី។
ជីវិតប្រៀបដូចជាការសម្តែង រៀបចំចាត់ចែងនៅក្នុងភពបី
អ្នកតែងគឺកម្មគ្មានត្រាប្រណី អ្នកក្រសេដ្ឋីចាត់មិនរើសមុខ។
ពេលខ្លះឱ្យធំមានបុណ្យសក្តិយស ឋានៈខ្ពង់ខ្ពស់ខ្លះដូចជាប់គុក
ពេលខ្លះឱ្យសុខខ្លះក៏ឱ្យទុក្ខ ខ្លះជួបឪពុកព្រាត់ប្រាសពីម៉ែ។
ខ្លះស្លាប់ពីក្មេងខ្លះរស់ដល់ចាស់ ខ្លះមានប្រាក់កាសចាយជាហូរហែ
ខ្លះនៅទីក្រុងអ្នកខ្លះនៅស្រែ ខ្លះទុក្ខឥតល្ហែអ្នកខ្លះសុខសាន្ត។
តាមពិតជីវិតបីដូចឆាកល្ខោន ប្រសើរអាប់ឱនមានគ្រប់សព្វប្រាណ
បើខ្លួនខ្ពង់ខ្ពស់សាងគុណកុំខាន រឿងចប់ថ្មើរម៉ានបានបុណ្យជាគ្នា។
បើខ្លួននៅក្រឱ្យក្រទៅចុះ ឱ្យតែចិត្តស្មោះព្រមស្តាប់ធម្មា
គង់មានថ្ងៃមួយអាចរួចចាកពៀរ ឡើងជិះនាវាផុតទុក្ខវិបរិត។
អស់លោកសប្បុរសជាទីស្នេហា ស្តាប់គិតចុះណាឆាកល្ខោនជីវិត
កុំលង់ចាញ់បោកកិលេសនៃបនិត្យ ចូរស្តាប់ធម៌ពិតនៃព្រះជិនស្រី។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ១៤.កំណាព្យផ្សេងៗ

# ឆ្នាំថ្មីមនុស្សចាស់[១]

(១)-ដោយសារតែស្នាក់នៅម្នាក់ឯងគត់ ឯវត្តពោធិ៍វាល ខេត្តបាត់ដំបង នៅថ្ងៃចូលឆ្នាំ ខ្មែរមានភាពអផ្សុកពេក **សា ចាន់រ៉ាត់** ខ្ញុំបានចាប់ផ្ដើមសរសេរកំណាព្យទាំងនេះ នៅថ្ងៃសុក្រ ៧ រោច ខែចេត្រ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៥ ត្រូវនឹងថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១២ ដែលជាថ្ងៃខួបកំណើត(ថ្ងៃពុធ ទី១២ ខែមេសា ឆ្នាំរោង ១៩៨៨) របស់ខ្ញុំ ហើយ

អរុណពណ៌មាសចាំងជះរស្មី មកលើផែនដីនាព្រឹកព្រលឹម
បញ្ចេញរូបឆោមយាត្រាសន្សឹម ទៅទិសបស្ចិមជារឿងធម្មតា។
រីអស់មនុស្សសត្វកើតក្នុងលោកិយ តែងជាចំណីនៃក្តីមរណា
ក្មេងចាស់ឈឺស្លាប់គ្មានអ្វីតវ៉ា នេះឯងសង្ខារកើតហើយវិនាស។
ឆ្នាំចាស់ផ្លាស់ទៅឆ្នាំថ្មីមកដល់ ចិត្តខ្វះកុសលខ្វល់ហើយរង្កៀស
អាយុត្រូវអស់គ្មានអ្វីយកឈ្នះ ស្លាប់គ្រប់តែផ្ទះរាល់ថ្ងៃខែឆ្នាំ។
ចូលដល់ឆ្នាំថ្មីភ្លេចថាវ័យចាស់ គិតអ្វីផ្តេសផ្តាស់ភ្លេចពាក្យព្រះផ្តាំ
ដើរហើរលេងល្បែងស្រីញីស្រាថ្នាំ បើកុសលកម្មនឹកមិនឃើញទេ។
មកវត្តស្តាប់ធម៌ថារវល់ណាស់ បើរាំផុងបាសទើបបានទំនេរ
បបួលទៅបុណ្យថាជាប់ការគេ ជិះម៉ូតូជ្រៃតែងខ្លួនទៅបា។
បបួលធ្វើបុណ្យថាគ្មានលុយទេ ផឹកស៊ីប៉ាវគេសុទ្ធតែដុល្លារ
ឆ្នាំមុនឆ្នាំនេះមិនទាន់ជ្រះថ្លា ចាំអាយុហាទើបចង់ទៅវត្ត។
ធម៌តាមវិទ្យុចេះតែច្រឡំ ល្បែងស្រីស្រាផ្សំចេះតែចាំស្ទាត់
បើសូត្រធម៌ព្រះចេះតែភ្លាត់មាត់ មិនដូចជាគាត់ម្នាក់ឯណោះសោះ។
បើសួរធម៌អាថ៌ថាខ្ញុំនៅឆៅ មើលកូនថៃចៅនៅចាំទាំងអស់
ទូរទស្សន៍រឿងភាគចាំគ្មានចន្លោះ ប្តូរផ្តាច់ស្ម័គ្រស្មោះគឺភ្លេចវត្តវ៉ា។
បើផ្លូវមកវត្តចេះតែវង្វេង តែបើផ្លូវផ្សេងគ្មានភ្លេចម្តងណា
អានសៀវភៅធម៌ទាល់តែវ៉ែនតា តែបើចូលបាភ្លឺច្បាស់ដូចថ្ងៃ។
ពីមុនថាក្រមិនចង់ធ្វើទាន ឥឡូវនេះមានមាសប្រាក់ក្នុងដៃ

---

នេះក៏ដើម្បីរំឭកខួបឆ្នាំរោង,២០១២ ដែលខួបឆ្នាំកំណើតរបស់ខ្ញុំ គ្រប់ជន្មាយុ ២៥ ឆ្នាំផង ដែរ៕

ធ្វើបុណ្យមិនកើតព្រោះខ្វះនិស្ស័យ ចិត្តបាបចង្រៃភ្លេចដល់ថ្ងៃចាស់។
មួយឆ្នាំកន្លងអាយុថយចុះ ចេះតែគិតខុសប្រព្រឹត្តផ្ដេសផ្ដាស
គិតថាខ្លួនធំសុខភាពមាំណាស់ គ្មានអ្វីប្ដូរផ្លាស់ដូចលោកទេសន៍ទេ។
គួរអនិច្ចាឆ្នាំថ្មីមនុស្សចាស់ អ្វីៗប្ដូរផ្លាស់គ្មានពេលទំនេរ
បើភ្លេចបុណ្យទានពិតធ្លាក់និរយេ អ្នកអើយរិះរេធ្វើបុណ្យដាក់ទាន។
សិរីសួស្ដីកើតពីធ្វើល្អ សន្សំធម៌សស្ដាប់ព្រះទូន្មាន
លះបង់ចិត្តបាបគំនិតឈ្លានពាន ចូរខំសាងស្ពានស្ដាប់ធម៌ព្រះពុទ្ធ។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## ជីវិតជាអ្វី?

ជីវិតបាលីថាដំណើរ ជីវិតប្រសើរដោយប្រាជ្ញា
ជីវិតជាធម៌អនិច្ចា ជីវិតទុក្ខាមិនមាំមួន។
ជីវិតជួបរឿងរ៉ាវទាំងអស់ ជីវិតសូន្យសោះមិនមែនខ្លួន

ជីវិតសុខទុក្ខលាយផ្សំគ្នា ជីវិតសមស្មួនមានតិចណាស់។
ជីវិតគឺត្រឹមជាសង្ខារ ជីវិតនេះណាតែងប្តូរផ្លាស់
ជីវិតនៅក្មេងគង់តែចាស់ ជីវិតគ្មានម្ចាស់ហួងហែងបាន។
ជីវិតអ្នកមានឬអ្នកក្រ ជីវិតបានល្អបុណ្យរុញច្រាន
ជីវិតមិនមែនតែសុខសាន្ត ជីវិតសាមាន្យគ្មានទំនេរ។
ជីវិតសរសើរសុខលាភយស ជីវិតនេះឈ្មោះសុខម្លេះទេ
ជីវិតនិន្ទាទុក្ខជាងគេ ជីវិតគ្មានទេសុខជានិច្ច។
ជីវិតបានមកដោយបុណ្យល្អ ជីវិតសែនក្រចាំកុំភ្លេច
ជីវិតគឺថ្លៃជាងមាសពេជ្រ ជីវិតមានតិចកុំប្រមាទ។
ជីវិតនៅរស់ធ្វើបុណ្យទាន ជីវិតនៅមានត្រូវសង្វាត
ជីវិតមានសីលទើបមិនខាត ជីវិតបានស្អាតព្រោះខន្តី។
ជីវិតត្រូវតែធ្វើការងារ ជីវិតវឌ្ឍនាដោយបារមី
ជីវិតសាងល្អកើតសិរី ជីវិតមានន័យព្រោះធ្វើល្អ។
ជីវិតត្រូវតែមានសាមគ្គី ជីវិតគ្មានពីរហៅសែនក្រ
ជីវិតសាងគុណទើបបវរ ជីវិតត្រាច់ចរទៅទីស្លាប់។
ជីវិតនៅមានរៀនធម៌ព្រះ ជីវិតត្រូវលះអ្វីគ្រប់សព្វ
ជីវិតតែងមានទីបញ្ចប់ ជីវិតសុខស្ងប់អស់កិលេស។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## សង្ខារមិនទៀង

សង្ខារតាក់តែងក្លែងបន្លំ ប្តូរសាច់រឿងផ្សំជួបហើយព្រាត់

កើតហើយស្លាប់វិញមិនទៀងទាត់ គឺមិនអាចឃាត់បានសោះឡើយ។

ជួនកាលតាក់តែងឱ្យខ្ពង់ខ្ពស់ មានយសឥតយសផ្លាស់ឥតស្បើយ
សរសើរនិន្ទាគ្មានកោះត្រើយ តួកម្មនេះហើយបែងចែកសត្វ។
គួរអនិច្ចាសត្វលោកិយ ស្លាប់កូនព្រាត់ប្តីតែងវិបត្តិ
ចោលផ្ទះសំបែងទ្រព្យសម្បត្តិ ពេលដាច់ខ្យល់បាត់ឥតខ្លឹមសារ។
មានក្រលួង់ខ្មៅល្អអាក្រក់ ត្រូវមច្ចុឆក់ស្លាប់មរណា
ខ្សឹកខ្សួលអួលណែនក្នុងឱរា ស្រក់ទឹកនេត្រាគ្មានពេលល្ហែ។
មនុស្សសត្វរស់នៅអួតម្យ៉ាងៗ អាងញាតិជិតខាងពុកនិងម៉ែ
អាងទ្រព្យសម្បត្តិចម្ការស្រែ កេរ្តិ៍ឈ្មោះហូរហែគ្មានដឹងខ្យល់។
បើប្រាប់ឱ្យខំរៀនធម៌អាថ៌ អាងរវល់ការគិតមិនដល់
ឱ្យខំធ្វើទានសាងកុសល ថាខ្ញុំមិនខ្វល់រឿងនេះទេ។
ឱះឱសត្វលោកងងឹតណាស់ យល់ធម៌មិនច្បាស់សីលទំនេរ
ចុងក្រោយត្រូវស្លាប់ទាំងយើងគេ ដូច្នេះរិះរេសាងបុណ្យណ៎ា។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ជីវិតមានន័យ

ជីវិតគឺជាដំណើរផ្លូវឆ្ងាយ សុខទុក្ខសប្បាយមិនទៀងទាត់ទេ
ប្រែប្រួលផ្លាស់ប្តូរឥតមានទំនេរ អ្នកគួររិះរេខិតខំធ្វើល្អ។
ជីវិតប្រសើរមិនដោយសារទ្រព្យ ធ្វើល្អឱ្យជាប់ទើបថ្លៃបវរ
បានធ្វើបុណ្យហើយគួរខំបន្ត ធ្វើដោយស្មោះសរទឹកចិត្តជ្រះថ្លា។

រស់នៅមានន័យលៃធ្វើបុណ្យទាន រស់មិនបំពានលើច្បាប់មាត្រា
រៀនច្បាប់ឱ្យច្បាស់ចម្រើនប្រាជ្ញា សិក្សាធម៌អាថ៌សាស្តាទូន្មាន។
ជីវិតមានន័យអាស្រ័យមានសីល ជម្រះមន្ទិលលះទ្រព្យធ្វើទាន
លះធម៌លាមកគំនិតឈ្លានពាន ប្រាថ្នានិព្វានទើបជួបសុខពិត។
ជីវិតបានសុខអាស្រ័យចិត្តស្ងប់ អ្នកគួរត្រឡប់អប់រំកាយចិត្ត
សេពគប់បណ្ឌិតស្តាប់ធម៌ហើយគិត ទើបបាននៃបនិត្យសម្បត្តិអស្ចារ្យ។
លទ្ធផលគុណធម៌គឺយសសិរី ធ្វើឱ្យប្រុសស្រីរីករាយជ្រះថ្លា
លះកម្មអាក្រក់កម្ចាត់តណ្ហា ទើបបានសុខាលែងវិលកើតស្លាប់។
ជីវិតនៅមានគួរឆ្លៀតសាងគុណ កុំសាងទារុណនាំឈឺចុកចាប់
ព្រះធម៌មានហើយអ្នកគួរប្រញាប់ សិក្សាហើយស្តាប់រកន័យជីវិត។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## អានិសង្សទាន

ទានជាប្រធាននៃបារមី ទានព្រះជិនស្រីសម្តែងច្បាស់
ទានតែងនាំសុខមកឱ្យម្ចាស់ ទានផលច្រើនណាស់ហួសគណនា។
ទានអាចកម្ចាត់ក្តីកំណាញ់ ទានតែងស្រឡាញ់ជនច្រើនគ្នា
ទាននាំឱ្យមនុស្សមានសទ្ធា ទាននាំសួគ៌ាឱ្យប្រុសស្រី។
ទានអាចជម្រះនូវផ្លូវចិត្ត ទានផលប្រណីតក្នុងលោកិយ

ទាននាំឱ្យផុតពីអវិចី ទាននាំសួស្តីសព្វទាំងអស់។
ទានគឺជាទ្រព្យមានខ្លឹមសារ ទានផ្តល់សុខាគ្មានចន្លោះ
ទាននាំឱ្យមនុស្សមានចិត្តស្មោះ ទាននាំសប្បុរសឱ្យសេពគប់។
ទាននាំឱ្យរួចចាកពីភ័យ ទានជាប់និស្ស័យក្នុងត្រៃភព
ទានសែនត្រជាក់លើសអស់ម្លប់ ទានអ្នកបញ្ឈប់បាបអប្រិយ។
ទានដែលបានធ្វើដោយសទ្ធា ទានផ្តាច់វេរាតូចធំក្តី
ទាននេះអ្នកប្រាជ្ញតែងពោលស្តី ទានជាបារមីផ្លូវនិព្វាន។
ទានអ្នកប្រហារធម៌វង្វេង ទានជាផ្លូវផ្សេងពោធិញាណ
ទានផ្តាច់កិលេសបាបរយលាន ទានបាត់ស្រេកឃ្លានសុខគ្រប់ថ្នាក់។
ទានគឺជាភូមិនៃព្រះពុទ្ធ ទានថ្លៃវិសុទ្ធផ្តល់យសសក្តិ
ទានធ្វើឱ្យឃើញនូវសច្ចៈ ទានកាច់បំបាក់គុកលោកិយ។
ទានផ្តាច់ចំណងវដ្តសង្សារ ទានធម៌ទេវតាអធិបតី
ទានធ្វើឱ្យមនុស្សមានស្មារតី ទានអ្នកគប្បីខំប្រិតប្រៀន។
ទានតែងនាំបុណ្យដ៏អស្ចារ្យ ទានផ្តល់ផលាសួគ៌និព្វាន
ទានជួយទាំងអស់អ្នកក្រមាន ទានគឺជាយានឆ្លងគ្រោះកាច។
ទានធ្វើឱ្យចិត្តរួចស្រឡះ ទានកាត់បាបក្រាសដ៏កំណាច
ទានធ្វើឱ្យចិត្តក្លាអង់អាច ទានពិតជាអាចឱ្យឧត្តម។
ទានគឺជាទ្រព្យជាប់តាមចិត្ត ទានធម៌ព្រះពិតគួរសន្សំ
ទានដុះក្នុងចិត្តគួរលត់ដំ ទានធ្វើបានសមបុណ្យច្រើនក្រៃ។
ទាននាំឱ្យចិត្តបានសប្បាយ ទាននាំចិត្តកាយមានតម្លៃ
ទានមានផលច្រើនធ្វើផ្ទាល់ដៃ ទានខ្ពស់ថ្លាថ្លៃសព្វទិវា។
ទានគឺជាធម៌សប្បុរស ទានជាមិត្តស្មោះរាល់វេលា

ទានធ្វើគោរពតាមធម្មា ទានធ្វើតាមគ្រាសែនបវរ។
ទានធ្វើឱ្យមនុស្សមានសាមគ្គី ទានថ្លៃគ្មានពីរសែនកម្រ
ទានធ្វើឱ្យមនុស្សមានចិត្តល្អ ទានជាធម៌សប្រដូចគ្មាន។
ទានផលវិសេសមិនងាយរក ទានជាជម្រកបញ្ញាញាណ
ទានជួយចម្លងល្អជាងយាន ទានគឺជាស្ពានឆ្លងអន្តរាយ។
ទានមានគុណច្រើនអ្នកគួរដឹង ទានអ្នកគួរប្រឹងគ្រប់រូបកាយ
ទាននាំឱ្យអ្នកផុតខ្វល់ខ្វាយ ទានផ្តាច់អបាយល្អគ្មានពីរ។
ទាននេះជាធម៌ពីបុរាណ ទានជាសន្តាននៃមុនី
ទានទោះតិចច្រើនគួរសំភី ទាននាំដល់ទីនិព្វានហោង។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## អានិសង្សសីល

សីលព្រះសម្តែងជាបាលី សីលជួយប្រុសស្រីទោះក្មេងចាស់
សីលជាទ្រព្យធនលើសប្រាក់កាស សីលព្រះទ្រង់ត្រាស់មានគុណក្រៃ។
សីលនាំឱ្យមានទ្រព្យសម្បត្តិ សីលប្រសើរក្តាត់កេរ្តិ៍ឈ្មោះថ្លៃ
សីលនាំភ្លៀវភ្លាទាំងយប់ថ្ងៃ សីលផ្តល់តម្លៃពេលមរណា។
សីលជាជំហានដ៏ប្រសើរ សីលជាជណ្តើរកើតទេវតា

សីលដូចគង្គាដ៏ស្រស់ថ្លា		សីលអ្នកប្រហារពូជទោសៈ។
សីលតែងកម្ចាត់នូវអន្តរាយ		សីលក្រអូបសាយគ្រប់ជាន់ថ្នាក់
សីលអាចកម្ចាត់នូវមោហៈ		សីលគ្មានវណ្ណៈប្រុសឬស្រី។
សីលនាំឱ្យកើតអភិញ្ញា		សីលផ្តាច់វេរាក្នុងលោកិយ
សីលជាកែវទិព្វនាំសិរី		សីលគឺទឹកដីនៃព្រះពុទ្ធ។
សីលគឺទីតាំងនៃកុសល		សីលផ្តាច់កង្វល់ថ្លៃវិសុទ្ធ
សីលមានភាពស្អាតបរិសុទ្ធ		សីលប្រៀបដូចមកុដនៃពួកក្សត្រ។
សីលនាំបុគ្គលដែលទ្រទ្រង់		សីលជាកំពង់នៃសម្បត្តិ
សីលនាំឱ្យមនុស្សរួចវិបត្តិ		សីលអាចកម្ចាត់កិលេសបាន។
សីលនាំឱ្យបានការសរសើរ		សីលអ្នកបម្រើសុខក្សេមក្សាន្ត
សីលប្រៀបដូចជាអ្នករុញច្រាន		សីលផ្តល់សួគ៌ឋានដល់អ្នកពិត។
សីលនាំឱ្យបាននូវសាមគ្គី		សីលនាំមូលមីរសម្បូណ៌មិត្ត
សីលតែងនាំគុណដ៏ស័ក្តិសិទ្ធិ		សីលនាំជីវិតឱ្យសប្បាយ។
សីលជាខាងដើមជាទីតាំង		សីលជួយប្រឆាំងធម៌អបាយ
សីលជាកល្យាណធម៌ទាំងឡាយ		សីលនាំចិត្តកាយឱ្យចេះគ្រប់។
សីលគឺរនាំងដ៏សែនខ្លាំង		សីលគឺជាច្រាំងជាទំនប់
សីលសែនត្រជាក់លើសអស់ម្លប់		សីលអាចជួយទប់បាបសាមាន្យ។
សីលជាអាវុធដ៏ឧត្តម		សីលកម្លាំងផ្សំផ្ទឹមពុំបាន
សីលជាគ្រឿងក្រោះដ៏ចំណាន		សីលនាំថ្កើងថ្កានសព្វទិវា។
សីលគឺជាស្ពានមានសក្តិធំ		សីលក្លិនឧត្តមហួសគន្ធា
សីលជាគ្រឿងលាបដ៏សោភា		សីលដូចភោជនាដ៏សែនឆ្ងាញ់។
សីលប្រៀបបីដូចកញ្ចប់បាយ		សីលស្បៀងរៀងអាយគួរស្រឡាញ់

សីលគឺជាយានគួរឱ្យខ្លាញ់ សីលជាសម្លាញ់មនុស្សផងគ្នា។
សីលនាំឱ្យឆ្ងាយអកុសល សីលជាផ្លូវថ្នល់ទៅសួគ៌ា
សីលនាំឱ្យឆ្លងផុតវេរា សីលផុតនិន្ទាក្នុងលោកា។
សីលតែងនាំមកជ័យជម្នះ សីលមានតេជះខ្លាំងណាស់ណា
សីលនាំឱ្យមនុស្សឆ្ងាយតណ្ហា សីលផ្តាច់ហិង្សារាល់ថ្ងៃខែ។
សីលសែនស្នេហ៍ត្រង់ជាងពួកញាតិ សីលថ្នៃមារយាទឱ្យល្អដែរ
សីលជាឱសថដ៏ពូកែ សីលជួយពុកម៉ែសុខឥតហ្មង។
សីលព្រះទាំងអស់អ្នកមានទេ សីលគួរវិះរេចុះប្អូនបង
សីលពិតជាអាចជួយចម្លង សីលល្អកន្លងត្រូវរក្សា។
សីលមានពួកប្រាំនិងប្រាំបី សីលអ្នកឃ្នាតខ្មីកុំភ្លេចណា
សីលដែលអ្នកមានជួយអាត្មា សីលឆ្លងលោកាលុះនិព្វាន។

**ដោយសាមណេរ សា ចាន់រ៉ាត់**

## គួររក្សាខន្តី

ខន្តីគឺជាធម៌បុរាណ ខន្តីព្រះបានសម្តែងច្បាស់
ខន្តីកម្ចាត់កិលេសក្រាស ខន្តីជួយផ្សះរោគក្នុងចិត្ត។
ខន្តីជាគ្រឿងអលង្ការ ខន្តីប្រហារធម៌អមិត្ត
ខន្តីជួយឱ្យមនុស្សល្អពិត ខន្តីស័ក្តិសិទ្ធិក្នុងលោកា។
ខន្តីជាទ្រព្យនៃអ្នកប្រាជ្ញ ខន្តីគឺអាចមានមេត្តា

ខន្តីឱ្យមនុស្សមានមេត្តា ខន្តីនេះណាមិត្តដ៏ល្អ។
ខន្តីជាញាតិដ៏រយឆ្នាំ ខន្តីជាថ្នាំសែនកម្រ
ខន្តីជួយមនុស្សឱ្យបវរ ខន្តីធម៌សនាំសុខសាន្ត។
ខន្តីនាំឱ្យមានលាភយស ខន្តីធម៌ខ្ពស់សព្វទីឋាន
ខន្តីជាទ្រព្យដ៏កល្យាណ ខន្តីជួយបានដល់ផ្លូវចិត្ត។
ខន្តីនាំឱ្យគេស្រឡាញ់ ខន្តីរសឆ្ងាញ់ក្រៃពេកពិត
ខន្តីនាំឱ្យសម្បូណ៌មិត្ត ខន្តីផ្លូវពិតទៅនិព្វាន។
ខន្តីជាយាននាំសុខា ខន្តីប្រហារបាបរយលាន
ខន្តីគឺជាបារមីញាណ ខន្តីជាស្ពានដ៏ឧត្តម។
ខន្តីនាំឱ្យផុតហិង្សា ខន្តីយាយតាគួរសន្សំ
ខន្តីនាំចិត្តផុតក្រៀមក្រំ ខន្តីអ្នកផ្សំសុខសួស្តី។
ខន្តីនាំឱ្យឆ្ងាយជម្លោះ ខន្តីផុតគ្រោះជ្រោះអវិចី
ខន្តីនាំឱ្យផុតព្រួយភ័យ ខន្តីមានន័យធម៌ទេវតា។
ខន្តីធ្វើឱ្យចិត្តត្រជាក់ ខន្តីជួយអ្នកឱ្យភ្លឺថ្លា
ខន្តីជាទ្រព្យក្នុងសង្សារ ខន្តីអស្ចារ្យក្នុងលោកិយ។
ខន្តីជាធម៌គួរអត់ទ្រាំ ខន្តីតែងនាំយសសិរី
ខន្តីជាធម៌ព្រះជិនស្រី ខន្តីប្រុសស្រីគួរប្រាថ្នា។
ខន្តីធ្វើឱ្យចិត្តចេះគ្រប់ ខន្តីជាម្លប់មនុស្សទេវតា
ខន្តីនេះមានដរាបណា ខន្តីកាប់ឆ្ការគ្រឿងសៅហ្មង។
ខន្តីធ្វើឱ្យជួបជុំញាតិ ខន្តីមិនឃ្លាតពីប្អូនបង
ខន្តីគឺធម៌ដ៏ចម្បង ខន្តីនាំឆ្លងសង្សារវដ្ត។

**ដោយសាមណេរ សា ចាន់រ៉ាត់**

## **អ្វីទៅជាលុយ** ?

លុយជួយឱ្យមនុស្សបានសុខសាន្ត លុយអ្នករុញច្រានឱ្យអាក្រក់
លុយធ្វើឱ្យមនុស្សចេះកុហក លុយចោរលួចឆក់យសសិរី។
លុយជួយឱ្យមនុស្សមានកេរ្តិ៍ឈ្មោះ លុយក៏នាំគ្រោះកាចអប្រិយ
លុយធ្វើឱ្យមនុស្សភ្លេចស្មារតី លុយក៏ជាក្តីកង្វល់ដែរ។
លុយចម្លងមនុស្សដូចទូកក្បូន លុយធ្វើឱ្យកូនភ្លេចពុកម៉ែ

លុយធ្វើឱ្យចិត្តមនុស្សប្រួលប្រែ លុយជាចៅកែប្រើមនុស្សបាន។
លុយគឺវត្ថុមានមុខពីរ លុយនាំវក់វីគ្រប់ទីឋាន
លុយនាំឱ្យមនុស្សរស់ថ្កើងថ្កាន លុយដូចតិរច្ឆានគ្មានស្គាល់ម្ចាស់។
លុយអាចទិញបានទ្រព្យកែវកង លុយជាចំណងចងមាំណាស់
លុយនាំឱ្យចិត្តគិតផ្តេសផ្តាស លុយនាំក្មេងចាស់ភ្លេចពុកម៉ែ។
លុយនាំឱ្យមានផ្ទះវីឡា លុយនាំហ៊ីហាឡានហូរហែ
លុយនាំឱ្យមានចម្ការស្រែ លុយក៏យ៉ាប់ដែរបើប្រើខុស។
លុយប្រៀបបីដូចជាអាវុធ លុយល្អមោះមុតចងចាំចុះ
លុយចាយត្រឹមត្រូវគឺសន្តោស លុយគឺអ្នកប្រោសដូចឥសី។
លុយគឺក្រដាសមានតម្លៃ លុយចាយរាល់ថ្ងៃទាំងប្រុសស្រី
លុយធ្វើឱ្យមនុស្សកើតសេដ្ឋី លុយធ្វើឱ្យប្តីបែកប្រពន្ធ។
លុយធ្វើឱ្យមនុស្សបានខ្ពង់ខ្ពស់ លុយគឺជាជ្រោះជ្រៅពេកពន់
លុយគឺដងរែកដ៏សែនធ្ងន់ លុយគេរិះគន់ព្រោះអ្នកប្រើ។
លុយអ្វីក៏ដោយរៀលដុល្លារ លុយសុចរិតាទើបប្រសើរ
លុយគឺជាអ្នកជូនដំណើរ លុយអ្នកបម្រើដ៏ល្អម្នាក់។
លុយប្រៀបបីដូចចៅហ្វាយដែរ លុយប្រើហូរហែមើលឱ្យជាក់
លុយជាក្តីសុខរង់ចាំអ្នក លុយជាអន្ទាក់ចងរាល់ថ្ងៃ។
លុយនាំឱ្យអ្នកកើតកុសល លុយនាំកង្វល់ដ៏ច្រើនក្រៃ
លុយជាគ្រោះកាចដ៏ព្រៃផ្សៃ លុយនៅក្នុងដៃអ្នកគួរគិត។
លុយៗក៏មានគុណសម្បត្តិ លុយនាំវិបត្តិដែរញាតិមិត្ត
លុយឋិតក្នុងដៃអ្នកឆ្លាតពិត លុយនោះប្រណីតតែងបានការ។
លុយនៅក្នុងដៃនៃជនពាល លុយក្តៅរោលរាលនាំបញ្ហា

លុយដែលខ្ញុំពោលមកនេះណា លុយប្រភេទណាដែលអ្នកមាន?

**ដោយសាមណេរ សា ចាន់រ៉ាត់**

## បុណ្យគឺក្តីសុខ

បុណ្យគឺជាឈ្មោះនៃកុសល បុណ្យតែងឱ្យផលសុខពិតៗ
បុណ្យរួចស្រឡះចាកងងឹត បុណ្យស្មោះជាងមិត្តប្រដូចគ្មាន។
បុណ្យគឺជាទ្រព្យដ៏ស្មោះស បុណ្យជាផលល្អបញ្ញាញាណ
បុណ្យឆ្លងចិត្តបាបក្រៃជាងស្ពាន បុណ្យផ្តល់និព្វានផុតទុក្ខា។

បុណ្យញ៉ាំងដួងចិត្តឱ្យផូរផង់ បុណ្យជាផ្លូវត្រង់ព្រះសម្មា
បុណ្យគឺជាទ្រព្យគួរប្រាថ្នា បុណ្យអ្នកប្រហារធម៌អបាយ។
បុណ្យគឺជាកែវដ៏សែនថ្លៃ បុណ្យជួយរាល់ថ្ងៃទើបសប្បាយ
បុណ្យមានក្នុងចិត្តទើបស្រស់ស្រាយ បុណ្យនាំចិត្តកាយបានសុខស្ងប់។
បុណ្យជាបារមីដ៏ខ្ពង់ខ្ពស់ បុណ្យផ្តល់លាភយសជាកំណាប់
បុណ្យគឺជាធម៌មានគ្រប់សព្វ បុណ្យអ្នកត្រឡប់ខ្មៅឱ្យស។
បុណ្យគឺជាភូមិនៃព្រះពុទ្ធ បុណ្យថ្លៃវិសុទ្ធសែនកម្រ
បុណ្យធ្វើឱ្យចិត្តបានត្រេកអរ បុណ្យអ្នកកំដរផ្លូវជីវិត។
បុណ្យគឺជាទីពឹងនៃសត្វ បុណ្យជាសម្បត្តិថ្លៃពេកពិត
បុណ្យជាឱសថដ៏ស័ក្តិសិទ្ធិ បុណ្យពួកបណ្ឌិតតែងសរសើរ។
បុណ្យគឺជាកែវដ៏រុងរោចន៍ បុណ្យប្រៀបបីដូចជាជណ្តើរ
បុណ្យគឺជាអ្នកជូនដំណើរ បុណ្យគឺអ្នកស្មើទៅសួគ៌ា។
បុណ្យគឺជាហេតុឱ្យរីករាយ បុណ្យជាសម្ពាយជនច្រើនគ្នា
បុណ្យល្អផុសចេញពីសទ្ធា បុណ្យផ្តល់សុខជាឱ្យស្រស់ថ្លា។
បុណ្យមួយសម្រេចមកពីទាន បុណ្យខ្លះកើតមានដោយសីលា
បុណ្យដោយភាវនាក៏អស្ចារ្យ បុណ្យឱនសិរសាក៏មានដែរ។
បុណ្យខ្លះបានដោយការខ្វល់ខ្វាយ បុណ្យចែករៀងអាយគេហូរហែ
បុណ្យដែលត្រេកអររាល់ថ្ងៃខែ បុណ្យនៃពុកម៉ែញាតិកា។
បុណ្យសម្រេចដោយការស្តាប់ធម៌ បុណ្យមិនញាក់ញ័រគឺទេសនា

បុណ្យយល់ឃើញត្រូវតាមសទ្ធា បុណ្យនេះព្រះថាប្រសើរណាស់។
បុណ្យអ្វីក៏ដោយគួរសន្សំ បុណ្យគួរលត់ដំទាំងក្មេងចាស់
បុណ្យមិនចាំបាច់តែប្រាក់កាស បុណ្យពិតច្រើនណាស់ដ៏សន្ធឹក។
បុណ្យដេកបុណ្យដើរបុណ្យលើផ្ទះ បុណ្យគួររូតរះទោះល្ងាចព្រឹក
បុណ្យល្អអស់យ៉ាងគួរតែនឹក បុណ្យអ្នកកុំស្ពឹកគួរប្រឹងប្រែង។
បុណ្យមិនប្រកាន់មានឬក្រ បុណ្យមានចិត្តល្អព្រះសម្តែង
បុណ្យគឺក្តីសុខដែលឃើញស្តែង បុណ្យគួរចាត់ចែងឆ្លៀតធ្វើចុះ។
បុណ្យគួរសន្សំគួរតែធ្វើ បុណ្យឡើងឋានលើទោះស្រីប្រុស
បុណ្យមិនដែលនាំទៅផ្លូវខុស បុណ្យគឺតែងប្រោសជួយអ្នកហោង។

ដោយសាមណេរ **សា ចាន់រ៉ាត់**

## បាបគឺក្តីទុក្ខ

បាបនេះប្រែថាផលអាក្រក់ បាបគ្រឿងកខ្វក់គួរជិនណាយ
បាបធ្វើឱ្យចិត្តមិនសប្បាយ បាបនាំចិត្តកាយខ្វល់ឥតឈប់។
បាបគ្រឿងដុតរោលនូវដួងចិត្ត បាបសាមាន្យពិតទុក្ខលើសលប់
បាបនាំវិលវល់ក្នុងត្រៃភព បាបដុតថ្ងៃយប់សែនចង្រៃ។
បាបជាប្រភពនៃបញ្ហា បាបកាចឫស្យាដ៏ព្រៃផ្សៃ

បាបជាឃាតកធ្វើផ្ទាល់ដៃ បាបមិនសំចៃសត្វលោកឡើយ។
បាបគឺជាគុកសង្សារវដ្ត បាបគឺជាមាត់ទុក្ខឥតស្បើយ
បាបផ្តល់ព្រួយភ័យគ្មានកោះត្រើយ បាបគឺជាខ្មើយពូជអបាយ។
បាបជារោងចក្រនៃក្តីទុក្ខ បាបជាប្រមុខក្តីអន្តរាយ
បាបផ្ទុយពីបុណ្យដ៏សែនឆ្ងាយ បាបជាសហាយនៃជនពាល។
បាបជាអន្លង់ដ៏សែនជ្រៅ បាបជាលំនៅក្តៅរោលរាល
បាបមិនអាសូរដុតរង្គាល បាបគឺទីវាលសែនតក់ស្លុត។
បាបជាអាវុធអ្នកប្រហារ បាបផ្តល់ឈើផ្សាធ្ងន់បំផុត
បាបជាមេភ្លើងអ្នករុកដុត បាបមិនស្រកស្រុតគួរឱ្យខ្លាច។
បាបតូចបាបធំគួររាងចាល បាបតែងបណ្តាលទុក្ខកំណាច
បាបធ្វើឱ្យចិត្តកើតបិសាច បាបគឺសែនកាចគួរជៀសវាង។

ដោយសាមណេរ **សា ចាន់រ៉ាត់**

# ម៉ែជានរណា?

ម៉ែគឺជាព្រះរបស់កូន
ម៉ែគឺជាក្បូននៃប្រុសស្រី
ម៉ែគឺជាព្រះក្នុងលោកិយ
ម៉ែប្រោសប្រណីចិញ្ចឹមបុត្រ។
ម៉ែជាព្រះព្រហ្មសែនកម្រ
ម៉ែមានចិត្តល្អថ្លៃវិសុទ្ធ
ម៉ែថ្នមរូបកូនលើសបានម្កុដ
ម៉ែស្មោះបំផុតមិនគេចកែ។
ម៉ែមិនឱ្យកូនធ្វើអាក្រក់
ម៉ែជូនមរតករាល់ថ្ងៃខែ
ម៉ែជាគ្រូពេទ្យនៅចាំថែ
ម៉ែបើកប្រាក់ខែឱ្យកូនចាយ។
ម៉ែប្រៀបបីដូចជានាវា
ម៉ែជូនពុំងាទៅត្រើយអាយ
ម៉ែស្នេហាបុត្រមិនជិនណាយ
ម៉ែមិនដែលស្ដាយទ្រព្យធនធាន។
ម៉ែគ្រូដំបូងដ៏ថ្លាថ្លៃ
ម៉ែជូនចរណៃឱ្យទៅរៀន
ម៉ែទីប្រឹក្សាល្អរកគ្មាន
ម៉ែគឺជាស្ពានកូនមាសស្ងួន។
ម៉ែផ្ដល់កំណើតរូបរាងកាយ
ម៉ែថៃឆោមឆាយចិត្តមាំមួន
ម៉ែមានធម៌ព្រហ្មនៅក្នុងខ្លួន
ម៉ែជួយផ្គួនៗរាប់ពុំបាន។
ម៉ែនៅថែកូនយូរខែថ្ងៃ
ម៉ែថ្នមថ្លើមថ្លៃសព្វអង្គប្រាណ
ម៉ែអ្នកមានគុណដ៏ចំណាន
ម៉ែផ្ដល់សុខសាន្តរាល់វេលា។
ម៉ែជាជម្រកទ្រនុំបុត្រ
ម៉ែចិត្តបរិសុទ្ធណាស់ពុំងា
ម៉ែអ្នករង់ចាំនៅការពារ
ម៉ែគ្រងស្ងួនភ្ងាលុះមរណា។
ម៉ែអ្នកវ៉ាប់រងមុខរបរ
ម៉ែឱ្យស្លៀកសទៅវត្តវ៉ា

ម៉ែស៊ូលំបាកនឿយកាយា ម៉ែមិនដែលថាឱ្យកូនខ្ពស់។
ម៉ែគឺជាអ្នកដ៏អស្ចារ្យ ម៉ែមានមេត្តាឱ្យកូនរស់
ម៉ែចម្លងកូនឱ្យផុតគ្រោះ ម៉ែពិតមានឈ្មោះឧត្តមក្រៃ។
ម៉ែជាប្រទីបបំភ្លឺផ្លូវ ម៉ែតែងនិត្យនៅថ្នមបុត្រថ្លៃ
ម៉ែហ៊ានលះបង់គ្មានសំចៃ ម៉ែថ្នមផ្ទាល់ដៃកូនគ្រប់គ្នា។
ម៉ែប្រាប់ឱ្យកូនខិតខំរៀន ម៉ែពិតជាមានព្រហ្មវិហារ
ម៉ែមានគុណធំហួសមេឃា ម៉ែចិត្តល្អជាលើត្រាណត្រើយ។
ម៉ែគឺជាម្លប់ដ៏ត្រជាក់ ម៉ែស្មោះវរលក្ខណ៍នៅកៀកកើយ
ម៉ែយកខ្លួនប្រាណធ្វើជាខ្នើយ ម៉ែមិនស្តាយឡើយចិត្តភក្តី។
ម៉ែគឺជាព្រះដ៏ចម្បង ម៉ែល្អឥតហ្មងក្នុងភពបី
ម៉ែជួយឱ្យកូនរស់មានន័យ ម៉ែចិត្តប្រពៃមិនងាយរក។
ម៉ែពិតមានគុណដ៏ជាក់ស្តែង ម៉ែព្រះសម្តែងល្អក្នុងលោក
ម៉ែហឫទ័យល្អកូនបានជ្រក ម៉ែព្រះមានជោគរស្មីកូន។
ម៉ែគឺទេវតាជួយការពារ ម៉ែចិត្តព្រហ្មាមិនដែលសូន្យ
ម៉ែប្រាប់ឱ្យកូនដឹងជីដូន ម៉ែប្រាប់ឱ្យកូនស្គាល់ជីតា។
ម៉ែគឺជាព្រះគួរវន្ទា ម៉ែគួរបូជាដោយជ្រះថ្លា
ម៉ែគួរគោរពក្នុងលោកា ម៉ែផ្តល់សុខាដល់កូនៗ។

ដោយសាមណេរ **សា ចាន់រ៉ាត់**

# ជីវិតគឺត្រៃលក្ខណ៍ធម៌

ឱពេលវេលា តែងតែទំពា ស៊ីសត្វទាំងឡាយ
ស៊ីទាំងខ្លួនឯង ក្រមុំមេម៉ាយ ស៊ីរាល់រូបកាយ
ឥតមានចន្លោះ។

វេលាកន្លង ព្រាត់ញាតិប្អូនបង គ្មាននឹកស្រណោះ
វេលាតែងញ៉ាំង អ្វីៗទាំងអស់ នារីកំលោះ
ក៏វាស៊ីដែរ។

គួរអនិច្ចា គ្រប់អស់សត្តា ផ្លាស់ប្ដូរប្រួលប្រែ
ជរាព្យាធិ ខិតជិតហូរហែ ទុក្ខរាល់ថ្ងៃខែ
គ្មានដំណោះស្រាយ។

ធម៌ឈ្មោះទុក្ខំ គ្មានអ្វីតតាំង មានតែអន្តរាយ
ជាចំណងមារ ចងមិនងាយស្រាយ សត្វគ្រប់រូបកាយ
តែងជួបប្រទះ។

ឱអនត្តា មិនមែនអាត្មា គួរឱ្យរង្កៀស
ប្រែប្រួលមិនទៀង ខ្លាំងជាងរន្ទះ មិនអាចយកឈ្នះ
ត្រៃលក្ខណ៍ធម៌ឡើយ។

ខ្លឹមសារជីវិត បើតាមធម៌ពិត គឺគុណនេះហើយ
បញ្ញាកើតឡើង ទើបអ្នកបានឡើយ រស់បានឃើញត្រើយ

គឺព្រះនិព្វាន។

រស់កុំប្រមាទ ឧស្សាហ៍សង្វាត ផ្តាច់បាបរយលាន
លះអវិជ្ជា សាងបញ្ញាញាណ ពិសេសសាងស្ពាន
គឺបុណ្យកុសល។

បើដឹងកើតស្លាប់ គួរតែប្រញាប់ លះគ្រឿងខ្វាយខ្វល់
ទិដ្ឋិមានះ តណ្ហាដូចខ្យល់ ដុតកុំឱ្យសល់
ប្រហារកុំឈប់។

រស់រយវស្សា ល្ងង់គ្មានប្រាជ្ញា ងងឹតដូចយប់
បានមិនចេះស្កប់ មានមិនចេះគ្រប់ វិលវល់ក្នុងភព
ឥតដែនកំណត់។

រស់សាងប្រាជ្ញា ដោះស្រាយបញ្ហា តាមធម៌ប្រាកដ
ទានសីលជាហេតុ ខន្តីអំណត់ មគ្គផលប្រាកដ
ទើបផុតទុក្ខា។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# សូមជួបតែល្អ

អ្វីៗមិនបានទៅតាមចិត្ត ប្រែប្រួលវិបរិតមិនទៀងទេ
ចង់ជួបតែល្អទាំងយើងគេ លើកហត្ថទាំងទ្វេប៉ងប្រាថ្នា។
រស់នៅសូមជួបតែមនុស្សល្អ មានចិត្តស្មោះសគឺមេត្តា
សន្តោសប្រណីចេះករុណា និងមុទិតារាល់វេលា។
ឧបេក្ខាធម៌ក៏ចង់បាន ចិត្តស្មោះល្អប្រាណដ៏សោភា
ចង់ជៀសឱ្យឆ្ងាយកម្មវេរា ផ្តាច់អវិជ្ជាកុំឱ្យក្បែរ។
ចង់ជួបតែសុខមិនឱ្យឃ្លាត ជួបជុំផៅញាតិកុំឱ្យប្រែ
ទោះរស់ទីក្រុងចម្ការស្រែ ចិញ្ចឹមឪម៉ែដោយជ្រះថ្លា។
រឿងចង់លុះត្រាតែចេះគិត សេពគប់ញាតិមិត្តត្រូវពិចារណ៍
បើមិនដូច្នោះលង់អាត្មា មិនស្គាល់នរណាអាក្រក់ល្អ។
ជនណាប្រព្រឹត្តតែកុសល គួរតែខ្វាយខ្វល់សួរមាត់ក
បើមិនបានធ្វើគួរត្រេកអរ ជ្រោមជ្រែងបន្តចូរសេពគប់។
ជនណាសាងតែអកុសល មានល្បិចកិច្ចកល់ទាំងថ្ងៃយប់
គួរតែប្រយ័ត្នកុំសេពគប់ កុំយកធ្វើម្លប់ទីពឹងណា។
បណ្ឌិតតែងជួយសុខកន្លង ពាលខ្មៅសៅហ្មងនាំបញ្ហា
លះបង់ធម៌ថោកធម៌ហីនា រៀនសូត្រធម៌អាថ៌មន្តព្រះពុទ្ធ។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ត្រឹមតែជាសង្ខារ

ឱ៖ឱសង្ខារអ្នកតាក់តែង វិនាសហួតហែងគ្រប់សត្តា
កើតហើយស្លាប់វិញជាធម្មតា គឺអនិច្ចាមិនទៀងទេ។
បញ្ចក្ខន្ធគឺរូបហើយនិងនាម គ្មានអ្វីនៅស្ងៀមឱ្យទំនេរ
វិលវល់ជាទុក្ខទាំងយើងគេ សុខសួគ៌និរយេគ្មានចន្លោះ។
ធម៌អនត្តាមិនមែនខ្លួន ក៏មិនមាំមួនសូន្យសុងស្មោះ
ត្រឹមតែជាធាតុត្រូវក្រៀមក្រោះ គឺវិនាសអស់គ្មានសល់ឡើយ។
ធម៌អាថ៌សាស្តាពោលសច្ចៈ សត្វងងឹតខ្វាក់ប្ញកតោះតើយ
ដឹងថាកើតស្លាប់មិនរកត្រើយ ការរស់នេះហើយស្អុយស្រស់ៗ។
មិនជឿធម៌ព្រះជឿតាមមារ តែងតែគ្រាំគ្រាស្លាប់ទាំងអស់
គុណមិនចម្រើនគឺទោសស្មោះ នេះហើយសប្បុរសគឺសង្ខារ។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# មរតកជីវិត

ជីវិតជាការធ្វើដំណើរ អាក្រក់ប្រសើរស្រេចលើអ្នក
គឺបាបទាំងឡាយប្រៀបដូចផ្ទាក់ ទាញសត្វទម្លាក់ក្នុងសង្សារ។
ឱត្រៃលក្ខណ៍ធម៌ទ្រព្យជីវិត ប្រែប្រួលវិបរិតគ្រប់សង្ខារ
មិនអាចឃាត់ឃាំងសូមតវ៉ា កើតចាស់មរណាទាំងប្រុសស្រី។
រីឯទុក្ខំមិនងាយទ្រាំ តែងតែដឹកនាំសត្វលោកិយ
ឱ្យសត្វសោកសៅក្នុងភពបី នរកអរិចីមនុស្សទេវតា។
ឱះឱអ្វីៗមិនមែនខ្លួន គ្មានអ្វីមាំមួនអនត្តា
មរតកជីវិតគ្មានខ្លឹមសារ ត្រឹមជាសង្ខារកើតនិងស្លាប់។
ធ្មេញបាក់សក់ស្កូវរូបជរា មិនអាចការពារទោះយូរឆាប់
គួរសាងបុណ្យទានឱ្យប្រញាប់ ឯពេលជិតស្លាប់ក៏ដល់ហើយ។
គ្មានអ្វីប្រសើរជាងធម៌ព្រះ គ្មានអ្វីយកឈ្នះមច្ចុឡើយ
គួរពឹងត្រៃរតន៍ទើបបានស្បើយ អាចនាំដល់ត្រើយផុតទុក្ខា។
ធម្មតាមានរូបតែងមានរោគ សប្បាយវិយោគជាធម្មតា
បើរស់ខ្វះសីលគ្មានប្រាជ្ញា បែបនេះគេថារស់ដូចស្លាប់។
ឥឡូវសាសនាតែងមាននៅ គួរស្វែងរកផ្លូវឱ្យប្រញាប់
ធម៌អាថ៌នៅមានចូរខំស្ដាប់ បាលីសារសព្វលោកបរិយាយ។
រស់ហើយមិនសាងបុណ្យកុសល ច្បាស់ជាខ្វាយខ្វល់ក្នុងអបាយ

រមែងទុក្ខសោកក្តៅក្រហាយ ព្រោះតែសោកស្តាយភ្លេចស្មារតី។
នរជនណាមានគំនិត រៀនសូត្រធម៌ពិតព្រះជិនស្រី
រមែងឆ្លងផុតភពទាំងបី ដល់ព្រះបរិនិព្វានជាក់។
ព្រះធម៌ប្រៀបដូចជាអន្លូង សម្រាប់ទូងឱ្យសត្វភ្ញាក់
កុំឱ្យកិលេសទាញទម្លាក់ ធម៌ប្រាប់ជ្រៅរាក់ឱ្យដឹងច្បាស់។
ស្តាប់ធម៌រាល់ថ្ងៃកុំវង្វេង កុំអាងថាក្មេងមិនទាន់ចាស់
ព្រោះពេលឥឡូវស្លាប់ច្រើនណាស់ ក្មេងច្រើនជាងចាស់ក៏មានដែរ។
រៀបរាប់មកនេះចង់ឱ្យល្អ ខ្មៅប្រែជាសណាពុកម៉ែ
មរតកជីវិតស្លាប់ហូរហែ ដូច្នេះគួរតែសាងសុចរិត។
ប្លង់ផ្លូវព្រះមានរៀនគិតចុះ បើពោលទៅខុសសូមអាណិត
បើយល់ថាត្រូវកុំបែកចិត្ត មរតកជីវិតយ៉ាងនេះឯង។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ត្រឹមតែជាខ្យល់មាត់

ពពកសខ្មៅស្ថិតលើវេហាស៍ ដួងព្រះសូរិយាដួងព្រះចន្ទ្រា
ទឹកដីភ្លើងខ្យល់អស់សត្វនានា ត្រូវមនុស្សនិន្ទាសរសើរធម្មតា។
រឿងពាក្យសម្ដីមិនអាចប្រាកដ គ្មានដែនកំណត់ឱ្យត្រូវចិន្តា
កុហកបោកប្រាសខុសពីសច្ចា ត្រូវចងចាំថាត្រឹមជាខ្យល់មាត់។
គេថាគេស្ដីតាមតែគំនិត ស្ដាប់ឮហើយគិតកុំឱ្យមានភ្លាត់
ធ្វើគថ្លង់ខ្វាក់អប់រំហាមឃាត់ កុំខឹងតាមមាត់អ្នកពោលស្ដីថា។
សរសើរនិន្ទាមានពីបុរាណ ហាមឃាត់មិនបានត្រូវចង់ចាំណា
ម្នាក់ថាម្នាក់ខឹងអ្នកណាអស្ចារ្យ តាមពិតលោកថាបាបដូចតែគ្នា។
គេថាកុំខឹងត្រូវប្រឹងខំអត់ ខន្តីប្រាកដផ្ដាច់ពៀរវេរា
បើពាក្យណាល្អសឹមយកជាគ្នា ពោលតាមធម្មាថាសុភាសិត។
កំណើតជាមនុស្សគួរតែសាងល្អ សន្សំធម៌សគឺពោលពាក្យពិត
កុំញុះញង់គ្នានាំបែកញាតិមិត្ត គួរសាងសុចរិតទៅសួគ៌ាឋាន។
រីពាក្យសម្ដីមានទាបមានខ្ពស់ កុំពោលទ្រគោះគឺនាំថោកប្រាណ
ស្លាប់ទៅរងទុក្ខពេកពន់ប្រមាណ ចងចាំកុំខានគួរពោលតែពិត។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ស្រឡាញ់ប៉ុនណា គឺទុក្ខប៉ុណ្ណឹង

រីការប្រកួតតែងមានឈ្នះចាញ់ ឯក្ដីស្រឡាញ់តែងមានសោកសៅ
កើតស្នេហ៍ជាប់ស្និទ្ធជិតដាមផ្សាក្ដៅ ស្នេហ៍ធ្លាក់រណ្ដៅនៃក្ដីវង្វេង។
ចិត្តប៉ងចងកម្មបង្កើតស្នេហា ដោយសង្ឃឹមថាសុខស្រួលផ្សេងៗ
តាមពិតតណ្ហាបោកប្រាសមិនលែង បំភ័ន្តចាស់ក្មេងឱ្យទុក្ខខ្វល់ខ្វាយ។
មមាចឃើញភ្លើងស្មានថាសួគ៌ា ហើរចូលម្នីម្នាឆេះក្ដៅក្រហាយ
ធម្មតាស្នេហាតែងភ័យសោកស្ដាយ ឈឺចិត្តក្ដៅកាយស្ទើររស់ស្ទើរស្លាប់។
ចំណងតណ្ហាចាររឿងស្រឡាញ់ បង្កើតខ្នក់ខ្នាញ់ពើតឈឺចុកចាប់
ម្ដងសើចម្ដងយំមិនអាចរ៉ាយរ៉ាប់ ស្នេហ៍ខុសក្បួនច្បាប់ហៅក្បត់មេបា។
ស្រឡាញ់ប៉ុនណាគឺទុក្ខប៉ុណ្ណឹង រឿងនេះត្រូវដឹងគ្រប់ៗអាត្មា
បើស្នេហ៍កើតឡើងកុំភ្លេចមេត្តា កុំយកតណ្ហាដឹកមុខឱ្យសោះ។
មានស្នេហ៍មានទុក្ខធ្ងន់ជាងសម្ពាយ គ្មានអ្វីរីករាយចុងក្រោយក្រៀមក្រោះ
កាមជាគ្រឿងពុលបំផ្លាញទាំងអស់ គ្មានក្ដីស្រណោះនរណាម្នាក់ឡើយ។
អ្នកណារួចផុតពីក្ដីស្នេហា លះបង់តណ្ហារស់បានធូរស្បើយ
មិនខកបំណងឈ្មោះថាឃើញត្រើយ ការរស់នេះហើយឈ្មោះឧត្តមក្រៃ។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ប្រយ័ត្នសម្តី

សម្តីក្នុងលោកច្រើនអនេក
សម្តីប្លែកៗឆ្ងាយពីគ្នា
សម្តីជនពាលនាំវេរា
សម្តីល្អជានាំសុខសាន្ត។
សម្តីអាចឱ្យមានសាមគ្គី
សម្តីមុខពីរក៏ថាបាន
សម្តីអាចឱ្យទុក្ខដល់ប្រាណ
សម្តីរុញច្រានឱ្យសុខដែរ។
សម្តីកុហកនាំវិនាស
សម្តីយកឈ្នះនាំប្រួលប្រែ
សម្តីអាចឱ្យមនុស្សពូកែ
សម្តីក៏ប្រែឱ្យអាប់យស។
សម្តីផុសចេញពីខ្យល់មាត់
សម្តីពោលភ្លាត់មិនងាយជួស
សម្តីអាចជួយឱ្យបានខ្ពស់
សម្តីនាំគ្រោះសែនអប្រិយ។
សម្តីញុះញង់នាំបែកបាក់
សម្តីហួសថ្នាក់អាប់សិរី
សម្តីទ្រគោះបណ្តាលភ័យ
សម្តីឥតន័យខាតប្រយោជន៍។
សម្តីអាចឱ្យកើតជាមនុស្ស
សម្តីប្រទុស្តនាំកើតខ្មោច
សម្តីអាចឱ្យមនុស្សហិនហោច
សម្តីអាចស្រោចចិត្តឱ្យស្ងប់។
សម្តីអាចឱ្យមនុស្សវៃឆ្លាត
សម្តីហួសខ្នាតឱ្យមនុស្សឡប់
សម្តីឱ្យមនុស្សមានគ្រប់សព្វ
សម្តីត្រឡប់មនុស្សឱ្យក្រ។
សម្តីអាចឱ្យមនុស្សចេះគិត
សម្តីជាមិត្តដ៏បវរ
សម្តីជួយមនុស្សឱ្យបានល្អ
សម្តីរណ្តៅកក៏មានដែរ។
សម្តីធ្វើឱ្យចិត្តត្រជាក់
សម្តីជាផ្ទាក់មនុស្សហូរហែ
សម្តីឱ្យកូនខឹងនិងម៉ែ
សម្តីកើតស្នេហ៍មនុស្សប្រុសស្រី។
សម្តីអាចឱ្យមនុស្សចេះដឹង
សម្តីរឹងប៉ឹងជួយស្មារតី
សម្តីមាយាញាតិជេស្តី
សម្តីវែងខ្លីគេមើលងាយ។

សម្តីវិនាសគឺកុហក សម្តីអាក្រក់តែងរលាយ
សម្តីឌឺដងចិត្តទន់ជ្រាយ សម្តីវាយមាយគ្មានបានការ។
សម្តីអាចឱ្យគេស្រឡាញ់ សម្តីឱ្យចាញ់ដាច់សីលា
សម្តីឱ្យមនុស្សកើតទេវតា សម្តីប្រហារធ្លាក់អបាយ។
សម្តីអាចឱ្យមនុស្សមានទុក្ខ សម្តីនាំមុខឱ្យសប្បាយ
សម្តីធ្វើឱ្យមនុស្សខ្វល់ខ្វាយ សម្តីចៅហ្វាយបញ្ជាគេ។
សម្តីជាទ្រព្យគឺមាសប្រាក់ សម្តីជាប់ឆ្វាក់មាំម្ល៉េះទេ
សម្តីនាំមនុស្សធ្លាក់និរយេ សម្តីដៀលគេខ្វះពិចារណ៍។
សម្តីប្រភពនៃសុខទុក្ខ សម្តីឈានមុខនាំបញ្ហា
សម្តីរៀបរយនាំសុខា សម្តីហីនានាំអន្តរាយ។
សម្តីនាំអ្នកឱ្យបានរស់ សម្តីនាំយសសុខសប្បាយ
សម្តីឱ្យកូនឈ្លោះនិងម្តាយ សម្តីនាំកាយសុខកន្លង។
សម្តីមានគុណលើអ្នកប្រើ សម្តីប្រសើរផុតសៅហ្មង
សម្តីជាយានអាចចម្លង សម្តីស្ពានឆ្លងគ្រោះសាមាន្យ។
សម្តីអ្នកពោលត្រូវប្រយ័ត្ន សម្តីជាក្បត្រជួយអ្នកបាន
សម្តីនាំយើងសុខក្សេមក្សាន្ត សម្តីកល្យាណព្រោះប្រយ័ត្ន។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# វិជ្ជាល្អណាស់[១]

វិជ្ជាបានពីការសិក្សា
វិជ្ជាប្រហារក្តីងងឹត
វិជ្ជាជួយមនុស្សឱ្យល្អពិត
វិជ្ជាជាមិត្តដ៏ស្មោះស។
វិជ្ជានាំឱ្យបានខ្ពង់ខ្ពស់
វិជ្ជានាំយសថ្លៃបវរ
វិជ្ជាជួយមនុស្សផុតក្រីក្រ
វិជ្ជាសែនល្អក្នុងលោកិយ។
វិជ្ជាកើតមានព្រោះឧស្សាហ៍
វិជ្ជាអស្ចារ្យណាស់ប្រុសស្រី
វិជ្ជាអ្នកគួរតែឃ្មាតខ្មី
វិជ្ជាសួស្តីគួរប្រាថ្នា។
វិជ្ជាជាទ្រព្យចាយមិនអស់
វិជ្ជាឥតខ្ចោះគឺពិចារណ៍
វិជ្ជានាំឱ្យរស់ថ្លៃថ្លា
វិជ្ជាជួយស្ពាភាពល្ងង់ខ្លៅ។
វិជ្ជាតែងនាំឱ្យក្លាហាន
វិជ្ជាជួយបានប្រាប់គោលដៅ
វិជ្ជានាំឱ្យផុតហ្មងសៅ
វិជ្ជាលោកហៅទ្រព្យក្នុងខ្លួន។
វិជ្ជាចម្រើនតែងភ្លឺច្បាស់
វិជ្ជាជួយដាស់ចិត្តមាំមួន
វិជ្ជាកើតឡើងពីហេតុបួន
វិជ្ជាជួយផ្ដូនអ្នកគួរគិត។
វិជ្ជានាំឱ្យមានសាមគ្គី
វិជ្ជាញាំញីធម៌អមិត្ត
វិជ្ជានាំឱ្យដឹងរឿងពិត
វិជ្ជាប្រណីតគួរឃ្មាតខ្មី។
វិជ្ជាប្រៀបដូចជាអំណោយ
វិជ្ជានាំឱ្យមានទ្រឹស្តី

(១)-កំណាព្យមួយនេះ ខ្ញុំបានតែងនៅលើរថយន្តក្រុងពេលចេញពីខេត្តបាត់ដំបង ឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ កាលពីថ្ងៃព្រហស្បតិ៍ ៨ កើត ខែផល្គុន ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥ ត្រូវនឹងថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១២។

វិជ្ជាតែងជួយមនុស្សប្រុសស្រី វិជ្ជាលោកិយគួរពិនិត្យ។
វិជ្ជានាំអ្នកឱ្យរុងរឿង វិជ្ជាជាគ្រឿងនៃជីវិត
វិជ្ជានាំឱ្យចេះប្រឌិត វិជ្ជាញាតិមិត្តគួរប្រឹងប្រែង។
វិជ្ជានាំឱ្យកើតធនធាន វិជ្ជាជាស្ពានពិតជាក់ស្ដែង
វិជ្ជាតែងភ្លឺគ្រប់កន្លែង វិជ្ជានេះឯងពិតជួយអ្នក។
វិជ្ជាគឺផ្លូវដែលគួរដើរ វិជ្ជាប្រសើរគួរពឹងពាក់
វិជ្ជាជួយដាសអ្នកឱ្យភ្ញាក់ វិជ្ជាជាផ្នាក់យសសិរី។
វិជ្ជាតែងផ្ដល់ក្ដីសម្រេច វិជ្ជាតែងផ្ដាច់បាបអប្រិយ
វិជ្ជាជំនួយដល់ស្មារតី វិជ្ជានៅខ្ចីគួរខ្វល់ខ្វាយ។
វិជ្ជានាំឱ្យអ្នកចេះគិត វិជ្ជាញាតិមិត្តដ៏វែងឆ្ងាយ
វិជ្ជាតែងផ្ដល់សុខសប្បាយ វិជ្ជាអ្នកចាយមិនចេះអស់។
វិជ្ជាជាគ្រូដ៏ស្មោះស វិជ្ជាគុណល្អសែនសប្បុរស
វិជ្ជាជួយស្រាយគ្រឿងក្រៀមក្រោះ វិជ្ជាផុតខ្មោះគុកជីវិត។
វិជ្ជាកាត់ផ្ដាច់សង្សារវដ្ដ វិជ្ជាចេះស្ទាត់សែនស័ក្ដិសិទ្ធិ
វិជ្ជាអ្នកគួរតែនៃបនិត្យ វិជ្ជាពិតៗធម៌ព្រះពុទ្ធ។

**ដោយសាមណេរ សា ចាន់រ៉ាត់**

# ស្ថានីយដែលកំពុងសម្ដែងព្រះធម៌ដោយៈ

«ក្រុមយុវសមណអ្នកនិពន្ធ(ខេត្តបាត់ដំបង)»

| ខេត្ត/ក្រុង | ឈ្មោះស្ថានីយវិទ្យុ | ករម្រិតផ្សាយ | ពេលាផ្សាយ |
|---|---|---|---|
| បាត់ដំបង | សុវណ្ណអង្គរ | FM ១០៦ MHz | ០៩-១០ យប់ |
| | សំឡេងជនពិការ | FM១០៧.២៥MHz | ០៦-០៧ យប់ |
| | ដំបងក្រញូង | FM ១០០ MHz | ០៩-១០ ព្រឹក |
| សៀមរាប | សុវណ្ណអង្គរ | FM ៨៩.៥ MHz | ០៩-១០ យប់ |
| កំពង់ចាម | នាគព័ន្ធ | FM១០១.៧៥MHz | ០៩-១០ យប់ |

ពុទ្ធបរិស័ទអាចស្ដាប់ព្រះធម៌បាន តាមរយៈគេហទំព័ររៀងរាល់ម៉ោងផ្សាយបន្តផ្ទាល់ដូចខាងក្រោមៈ

-www.sovannangkorfm106.com

-www.vodfm.com

# នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅនេះ

-ព្រះអង្គគ្រូ កោសលប្បញ្ញោ ផាន សុទ្បា(កំពង់ឆ្នាំង)................២៣៥.០០០៛
-ប្រាក់បូជាព្រះធម៌ (សា ចាន់រ៉ាត់+ធី ចាន់ណា) .......................២០០.០០០៛
-បងស្រី ជា លីណា និងក្រុមគ្រួសារ(ខេត្តកំពង់ចាម)............... ១៥០.០០០៛
-ញោម សោម សារិទ្ធ......................................................... ១០០.០០០៛
-លោក ឈុំ មុនីរ៉ា និងភរិយា អ៊ឹង គឹមឈុន ព្រមទាំងបុត្រ........... ៨០.០០០៛

| | |
|---|---|
| -ឧ.សិ. ឡុក សាយគីម....៦០.០០០៛ | -ឧ.សិ. ជុង សុជា .......... ៥០.០០០៛ |
| -លោក ប៉ាត ជ័យ ..........៤៥.០០០៛ | -លោក ទិត ទុំ.............. ៤០.០០០៛ |
| -ឧ.សិ. ឈូក ចាន់ពៅ.....៤០.០០០៛ | -ពុទ្ធបរិស័ទព្រៃកូនខ្លា.....៣៥.០០០៛ |
| -ឧ.សិ. តាន់ គីមគ្រុយ.... ៣០.០០០៛ | -ឧ.សិ.លៀង សំណាង...៣០.០០០៛ |
| -លោក លន់................. ៣០.០០០៛ | -គ្រូ ប៉ូច សុខ តេង.........៣០.០០០៛ |
| -ឧ.សិ. ម៉ៅ វណ្ណី ........... ៣០.០០០៛ | -ឧ.សិ. មាស ផល្លី .........៣០.០០០៛ |
| -ឧ.សិ. អ៊ឹង មួយ ........... ៣០.០០០៛ | -ឧ.សិ.ទេព្យ ធៀប ........៣០.០០០៛ |
| -ឧ.សិ.អែម ណៃ........... ៣០.០០០៛ | -ទី ឡេងហុង................៣០.០០០៛ |
| -លោក លឹម លីសិរី....... ៣០.០០០៛ | -ឧ.សិ. ស៊ុន សោភា.......៣០.០០០៛ |
| -ឧ.សិ. ឡុក សាយគីម... ៣០.០០០៛ | -អ្នកម្តាយ ហួយ ...........៣០.០០០៛ |
| -ឧ.សិ. ថូ ចម្រើន.......... ៣០.០០០៛ | -ឧ.សិ. យ៉ាន់ ផារី ..........៣០.០០០៛ |
| -ឧ.សិ. ឃាង ស៊ីផល..... ២៥.០០០៛ | -លោក បៀង ជី ............២០.០០០៛ |
| -ឧ.សិ. ស៊ី.................... ២០.០០០៛ | -ប្អូនប្រុស ប៊ុន សារ៉ន .....២០.០០០៛ |
| -អ្នកស្រី ឃាង ស៊ីផាន ... ២០.០០០៛ | -លោកមាច អ្នកស្រីអូន ..២០.០០០៛ |
| -លោក មឿក ចាន់តូ...... ២០.០០០៛ | -ឧ.សិ.ភ័ក្ត្រ និងឆរិន ......២០.០០០៛ |
| -ប៉ែន សុវណ្ណតារា ......... ២០.០០០៛ | -ឧ.សិ.ភិម សេត ...........២០.០០០៛ |
| -ឡុង សុវណ្ណៈពេជ្រ........១៥.០០០៛ | -ឧ.សិ.គួ ធារី ............... ១៥.០០០៛ |

-ឧ.សិ. ចាន់ សារ៉ុម ........១៥.០០០រ
-ដួនជី ជា សុភី .............១៥.០០០រ
-ដួនជី ពេជ្រ សារឿន......១៥.០០០រ
-ឧ.សិ. សៀង ហេង .......១៥.០០០រ
-អ្នកស្រី សឿន ថាវី........១៥.០០០រ
-ឧ សិ.ឡឹង ហន ...........១៥.០០០រ
-ហុង សិុម ...................១៥.០០០រ
-ឈៀង មន្ត្រី ................១៥.០០០រ
-ឧ.សិ. លី គឹមធី ...........១៥.០០០រ
-ឧ.សិ.ម៉ៃ និងឧ.ស.ហ៊ុល ១៥.០០០រ
-យុវជន ឡុង នីតា .........១៥.០០០រ
-អ្នកស្រី ឡាង ម៉ាទិន......១៥.០០០រ
-អ្នកស្រី ប៊ិត រដ្ឋាដារី.......១៥.០០០រ
-ឧ.សិ.មុំ ស្រីទូច...........១៥.០០០រ
-ឧ.ស. យន្ត ឧ.សិ. អុន...១០.០០០រ
-ឧ.សិ. ឃាង ស៊ីផាត......១០.០០០រ
-ឧ.សិ. ស៊ុន រឿម..........១០.០០០រ
-បង មេធាវី ស៊ុំ ចំរុង.......១០.០០០រ
-ឧ.សិ. ចាប ស៊ីម៉ន ........១០.០០០រ
-ឧ.សិ. បែន សាយីវ .......១០.០០០រ
-លោក ប៊ីវ ឈូកឃន......១០.០០០រ
-លោក បៀម សុផល......១០.០០០រ
-សីលវតី ជា សុភី ..........១០.០០០រ
-ឧ.សិ. អាប អង ...........១០.០០០រ

ស៊ឹម ណារី ..................១៥.០០០រ
-ឧ.សិ. ជុំ នី និងបុត្រ......១៥.០០០រ
-ចំរើន សុខា ................១៥.០០០រ
-ឧ.សិ.យ៉ែម រ៉ាឌី ..........១៥.០០០រ
-ឧ.សិ. ណៃម ជុំ...........១៥.០០០រ
-ឧ.សិ. លិម កើត .........១៥.០០០រ
-មុក សឹម.....................១៥.០០០រ
-ឧ.សិ. មាស ផល្លី .........១៥.០០០រ
-ឧ.សិ. គឹម សុបញ្ញារ៉ា ....១៥.០០០រ
-ម៉ាច ស្រីម៉ុច................១៥.០០០រ
-ស៊ុន យ៉ាណា..............១៥.០០០រ
-សោភ័ណនារតី............១៥.០០០រ
-ឧ.សិ. ម៉ៅ វណ្ណី...........១៥.០០០រ
-ឧ.សិ. ភឿក បាន .........១០.០០០រ
-ឧ.សិ. ផាន់ សុវណ្ណ.......១០.០០០រ
-ឧ.សិ. ឱ ជាលី............១០.០០០រ
-ឧ.សិ. ណៃម ជុំ...........១០.០០០រ
-ឧ.សិ. លាត ...............១០.០០០រ
-អ្នកគ្រូ រិន វន្ថារី ..........១០.០០០រ
-ឧ.សិ. ជា សុខ............១០.០០០រ
-ឧ.សិ.ភិម យ៉ាង ..........១០.០០០រ
-ឧ.សិ. ស៊ុន រឿប .........១០.០០០រ
-ឧ.សិ.ព្រុំ ទន់...............១០.០០០រ
-ឧ.ស. ស៊ុំ រៀម............១០.០០០រ

| | |
|---|---|
| -ឧ.សិ. សំ សានី...........១០.០០០៛ | -បងស្រី ស៊ុំ រចនា......... ១០.០០០៛ |
| -បងស្រី ស៊ុំ នារ៉ា...........១០.០០០៛ | -បងវេជ្ជបណ្ឌិត ស៊ុំ រដ្ឋា .. ១០.០០០៛ |
| -បងប្រុស ស៊ុំ ចំរើន........១០.០០០៛ | -បងស្រី ស៊ុំ វិច្ឆិកា......... ១០.០០០៛ |
| -ឧ.សិ. កុង ហឿង..........១០.០០០៛ | -ឧ.សិ. មាន នួន........... ១០.០០០៛ |
| -ឧ.សិ. លី សារើយ ........១០.០០០៛ | -ឧ.សិ. សឿត.............. ១០.០០០៛ |
| -ឆាន់ គឹមឃី.................១០.០០០៛ | -ឧ.សិ. អៀម អៀ ......... ១០.០០០៛ |
| -ឧ.សិ. ដែន កល្យាណី....១០.០០០៛ | -កញ្ញា វណ្ណៈ....................៩.០០០៛ |
| -អ្នកស្រី លីណា.............. ៩.០០០៛ | -អ្នកស្រី គង់ សង្វា...........៩.០០០៛ |
| -លោក គង់ ពេជ្រ ........... ៩.០០០៛ | -លោក ខល់ លី ..............៩.០០០៛ |
| -លួន គាវ ...................... ៦.០០០៛ | ស្រី ទួន ទីណា ...............៦.០០០៛ |
| -នូវ ញឹម........................ ៦.០០០៛ | -ឧ.សិ.អ៊ុំ ធឿន................៥.០០០៛ |
| -ឧ.សិ. ពក គ្រី................ ៥.០០០៛ | -ឧ.ស. គួង.....................៥.០០០៛ |
| -ឧ.សិ. អោក ស៊ីនួន ......... ៥.០០០៛ | -កញ្ញា វ៉ង ស្រីម៉ៅ............៥.០០០៛ |
| -កញ្ញា វ៉ង ស្រីពៅ ........... ៥.០០០៛ | -ឧ.សិ. លី ស៊ីម...............៥.០០០៛ |
| -ឧ.សិ. រឿម................... ៥.០០០៛ | -ឧ.សិ. សុន ...................៥.០០០៛ |
| -ឧ.សិ.បៀង ថាវរី............ ៥.០០០៛ | -ឧ.សិ. ហ៊ុត ហម .............៥.០០០៛ |
| -ឧ.សិ. វេត ណុំ .............. ៥.០០០៛ | -ឧ.សិ. រើន.....................៥.០០០៛ |
| -ចៅតាទូង..................... ៥.០០០៛ | -បង ចម្រើន(លក់ផ្លែឈើ)..៥.០០០៛ |
| -ឧ.សិ. វ៉ាន .................... ៥.០០០៛ | -ឧ.សិ. អេង .................. ៣.០០០៛ |
| -ឧ.សិ. ប៉ាង..................៣.០០០៛ | -គឹម ធឿ....................... ៣.០០០៛ |
| -សួន ឈួ ......................៣.០០០៛ | -ឧ.សិ. អ៊ួច..................... ៣.០០០៛ |
| -ឧ.សិ. ស៊ុង អឹង .............២.៥០០៛ | -អ្នកស្រី គង់ សង្វា.................១០$ |
| -ឧ.សិ.អៀង វណ្ណី..................១០$ | -លោក ជា វណ្ណី និងគ្រួសារ .....១០$ |
| -លោក លឹមសេរី ..................១០$ | -កញ្ញា គង់ វណ្ណៈ...................... ៥$ |

| | |
|---|---|
| -សីលវតី ម៉ាន់ លីតា.................៥$ | -គីង សូរិយា និងស្វាមី.............. ៥$ |
| -ឧ.សិ. លឹម ចាន់ថន.................៥$ | -លោក គង់ ពេជ្រ.....................៣$ |
| -លោក ទឹត ខល្លីន .................. ៣$ | -អ្នកស្រី លីណា.......................៣$ |

(ពុទ្ធបរិស័ទខេត្តកំពង់ចាម ត្បូងឃ្មុំ តាមរយៈឧបាសិកា **ខែក វិបុល**)

| | |
|---|---|
| -លោក ឡាង សាលី...... ៣០.០០០៛ | -លោក ងួន ពុទ្ធារ៉ា......... ១៥.០០០៛ |
| -ឧ.សិ. ខែក វិបុល .........១៥.០០០៛ | -អ្នកស្រី អ៊ាង ពិសី......... ១៥.០០០៛ |
| -អ្នកស្រី សុខ ដាវី ..........១៥.០០០៛ | -អ្នកស្រី នួន រឿន ......... ១៥.០០០៛ |
| -អ្នកស្រី ណម សុភ័ក្ត្រ ....១៥.០០០៛ | -អ្នកស្រី គឹម ទិព្វសិរី ...... ១៥.០០០៛ |
| -ឧ.សិ វ៉ា គឹមលុយ និង .... ៩.០០០៛ | -លោក ម៉ក់ គឹមជាន .........៩.០០០៛ |
| -ឧ.សិ. តែ មួយឡេង......... ៩.០០០៛ | -ឧ.សិ. ង៉ សុខភឿន .........៦.០០០៛ |
| -ឧ.សិ. សយ សារ៉ាន់ ....... ៦.០០០៛ | -ឧ.ស. តុង ហេង .............៦.០០០៛ |
| -លោក ផាន់ រ៉ាឌី............. ៦.០០០៛ | -អ្នកស្រី ស៊ុន ណារី ..........៦.០០០៛ |
| -អ្នកស្រី ជាន យ៉ូត ........... ៦.០០០៛ | -លោក កែវ ថារី ...............៦.០០០៛ |
| -ឧ.សិ. ស៊ូ ឡុន .............. ៦.០០០៛ | -ឧ.សិ. មី ម៉ាង.................៦.០០០៛ |
| -ឧ.សិ. វ៉ែន រឿន ............. ៦.០០០៛ | -ឧ.សិ. ហុង ឡៃ...............៦.០០០៛ |
| -ឧ.សិ. ថូ ម៉េងហ៊ាង ......... ៦.០០០៛ | -ឧ.សិ. ថូ ម៉េងហុន ..........៦.០០០៛ |
| -ឧ.សិ. លី ហ៊ាង .............៣.០០០៛ | -ឧ.ស. ឡាង សារ៉េត ....... ៣.០០០៛ |
| -អ្នកស្រី សុខ ដាវីន..........៣.០០០៛ | -ឧ.សិ. អេន ................... ៣.០០០៛ |
| -លោក ម៉េង ហាក់...........៣.០០០៛ | -អ្នកស្រី កៅ សុយាន....... ៣.០០០៛ |
| -យុវជន ផេង សម្ផស្ស .....៣.០០០៛ | -អ្នកស្រី ហេង គឹមលាង ... ៣.០០០៛ |
| -អ្នកស្រី យ៉ង់ រតនា..........៣.០០០៛ | -អ្នកស្រី ដួង មាសចិន្តា .... ៣.០០០៛ |
| -យុវជន ដួង សុប៊ុណ្ណា ......៣.០០០៛ | -យុវជន វ៉ាន់ ដាវ័ន្ត........... ៣.០០០៛ |
| -យុវតី ដួង សុរីវីយ៉ា..........៣.០០០៛ | -នាង សត យ៉េង.............. ៣.០០០៛ |
| -កញ្ញា ផារី ចន្ទវិមានភួង....៣.០០០៛ | -យុវជន ផារី ដារ៉ាវុទ្ធ ........ ៣.០០០៛ |

-កុមារី ផារី សិរីពេជ្រ.........៣.០០០រ

ខ្ញុំសូមអភ័យទោស ចំពោះការបាត់បង់ឈ្មោះ ឬសរសេរឈ្មោះមិនត្រូវទៅតាមអក្ខរាវិរុទ្ធ តែទោះបីជាយ៉ាងណា ថវិកាទាំងអស់ខ្ញុំបានបញ្ចូលទៅក្នុងការ បោះពុម្ពសៀវភៅនេះទាំងអស់ហើយ។ *សូមអនុមោទនា!*

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះពុទ្ធបរិស័ទដែលបាន បរិច្ចាគថវិកា ដើម្បីឧបត្ថម្ភក្នុងការបោះពុម្ពសៀវភៅនេះ និងសៀវភៅ ក្រោយៗទៀតដែលត្រៀមនឹងចេញផ្សាយដោយ «ក្រុមយុវសមណអ្នកនិពន្ធ» ក្នុងពេលខាងមុខនេះ សូមប្រសិទ្ធនូវពុទ្ធពរទាំងឡាយ ៤ ប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្បត្តិទាំងឡាយ ៣ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ និងសម្បត្តិព្រះនិព្វាន ១ ចូរកើតមានដល់ពុទ្ធបរិស័ទ កុំបីប្រែក្លាយទៅជាប្រការដទៃឡើយ។

Filename: ២០១២ ក្រោមម្លប់ព្រះធម៌.docx
Directory: D:\BOOk1
Template: C:\Users\SACHANRAT\AppData\Roaming\Microsoft\Templates\Normal.dotm
Title:
Subject:
Author: ismail - [2010]
Keywords:
Comments:
Creation Date: 4/29/2012 10:37:00 AM
Change Number: 1,852
Last Saved On: 5/11/2012 9:34:00 PM
Last Saved By: SACHANRAT
Total Editing Time: 1,006 Minutes
Last Printed On: 5/16/2012 5:20:00 AM
As of Last Complete Printing
Number of Pages: 136
Number of Words: 18,712 (approx.)
Number of Characters: 106,659 (approx.)







